**មេរៀនទី១:** **អ្នកដំណើរដំបូង**

**កំណើតពិភពលោក ១-៣**

**គំនិតសំខាន់:** **ដើម្បីណែនាំពីខ្លឹមសារមេរៀនទៅតាមលំដាប់លំដោយ ដើម្បីបង្ហាញថាមានព្រះគ្រីស្ទតែមួយអង្គគត់ដែលអាចផ្តល់ការគ្របបាំងអំពើបាបយើង**

ថ្ងៃនេះយើងនឹងចាប់ផ្តើមការធ្វើដំណើរមួយ ។ ចូរយើងតាំងខ្លួនថាជាអ្នកដំណើរដែលកំពុងដើរតាមបណ្តោយផ្លូវដ៏វែងឆ្ងាយដែលហៅថា: *"មាគ៌ានៃជីវិត"*។ មាគ៌ានៃជីវិតនេះចាប់ផ្តើមឡើងនៅសួនច្បារ *អេដែន* ជាកន្លែងដែលជីវិតមនុស្សជាតិបានចាប់កំណើតឡើងនៅលើផែនដីនេះ ហើយវានឹងត្រូវបានបញ្ចប់ នៅពេលដែលរាជាណាចក្រនៃព្រះជាម្ចាស់នឹងត្រូវបានបង្កើតឡើងនៅលើផែនដីនេះ ។

អស់អ្នកដែលធ្វើដំណើរលើផ្លូវនេះត្រូវការផែនទី ឬសៀវភៅមគ្គុទេសក៍ (សៀវភៅណែនាំផ្លូវ)។ ព្រះជាម្ចាស់បានប្រទានដល់យើងនូវព្រះបន្ទូលរបស់ទ្រង់គឺ *"ព្រះគម្ពីរ"* សំរាប់បង្ហាញផ្លូវដល់យើង។ *ទំនុកតំកើង ១០៩:១០៥. ទំនុកតំកើង ៤៨:១៤* យើងត្រូវការសៀវភៅណែនាំរបស់ព្រះជាម្ចាស់ ហើយយើងនឹងប្រើវាលើគ្រប់មាគ៌ាទាំងអស់។ យើងនឹងជួបអ្នកធ្វើដំណើរជាច្រើន នៅពេលយើងបានធ្វើដំណើរតាម *មាគ៌ានៃជីវិត* នេះ។

យើងនឹងឃើញថា មានអ្នកដំណើរជាច្រើនដែលធ្វើដំណើរតាមផ្លូវផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែគ្រប់គ្នានឹងធ្វើដំណើរមួយដំណាក់កាលម្តងៗរហូតដល់ការវិនិច្ឆ័យមកដល់។ *ព្រះគម្ពីរបានប្រាប់យើងថា*: មានមនុស្សខ្លះយល់ថាផ្លូវដែលខ្លួនដើរជាផ្លូវត្រឹមត្រូវ ក៏ប៉ុន្តែនៅទីបំផុតផ្លូវនោះក៏នាំទៅរកសេចក្តីស្លាប់ *សុភាសិត: ១៤:១២។ គ្រប់ៗគ្នាដែលធ្វើដំណើរលើមាគ៌ានេះត្រូវតែជ្រើសរើសពីរបៀបដែលពួកគេនឹងត្រូវទៅ។* អ្នកធ្វើដំណើរត្រូវតែដឹងផងដែរនូវច្បាប់ធ្វើដំណើរ។ យើងនឹងឃើញថាច្បាប់ធ្វើដំណើររបស់ព្រះជាម្ចាស់មានលក្ខណៈខុសប្លែកគ្នាពីពេលវេលាមួយទៅពេលវេលាមួយទៀត និងពីទីកន្លែងមួយទៅកន្លែងមួយទៀតនៃសម័យកាលព្រមទាំងទីកន្លែងដែលគេរស់នៅ។ ក្នុងសម័យកាលដែលយើងរស់នៅសព្វថ្ងៃគឺមានលក្ខណៈខុសប្លែកពីគ្នាយ៉ាងខ្លាំងពីសម័យកាល *អាដាំ និងអេវ៉ា* ដែលជាមនុស្សដំបូងបង្អស់។ ការគោរពច្បាប់នៃការធ្វើដំណើរនៅលើ *មាគ៌ានៃជីវិត* មានន័យថាជាភាពខុសគ្នារវាងការរស់ និងការស្លាប់ ។

នៅក្នុងសម័យកាលដែលយើងរស់នៅសព្វថ្ងៃ នៅលើផែនទីតំណាងឱ្យ *អាកាសយានដ្ឋានព្រះគុណ*។ អ្នកនឹងដឹងថាហេតុអ្វីបានជាគេហៅថា *អាកាសយានដ្ឋានព្រះគុណ* នៅពេលដែលយើងបន្តដំណើរតទៅមុខទៀត។

យើងនឹងត្រលប់ចូលទៅក្នុងអតីតកាលរយៈពេលប្រហែល៦០០០ឆ្នាំមុន ដើម្បីជាការចាប់ផ្តើមធ្វើដំណើរដំបូងរបស់យើងនៅសួនច្បារដ៏ស្រស់ស្អាតមួយគឺ*សួនអេដែន* ។ ទីនោះយើងឃើញមាន *អាដាំ* និង*អេវ៉ា* ហើយប្រសិនយើងមើលនៅក្នុងសៀវភៅណែនាំរបស់យើងគឺ *ព្រះគម្ពីរ* យើងអាចអានពីដំណើររឿងដែលកើតឡើងចំពោះអ្នកធ្វើដំណើរដំបូងនៅលើ *"មាគ៌ានៃជីវិត"* ។

សំរាប់លោក*អាដាំ* និង*អេវ៉ា* ត្រូវបានផ្តល់ឱ្យនូវច្បាប់ធ្វើដំណើរយ៉ាងពិសេស ដែលយើងអាចអានអំពីពួកគេក្នុង *កំណើតពិភពលោក ២:១៦-១៧*។ ជាពិសេសពួកគេត្រូវបានហាមឃាត់មិន អោយបរិភោគផ្លែពីដើមឈើដ៏ពិសេសមួយ

នៅក្នុងសួនដែលហៅថា " ផ្លែឈើដឹងខុសត្រូវ "។ អ្វីៗគឺមានលក្ខណៈល្អប្រសើរ រហូតដល់ថ្ងៃដែលមេល្បួងដែលជាសត្រូវរបស់ព្រះជាម្ចាស់ និងជាសត្រូវរបស់មនុស្សបានចូលមកក្នុងសួនច្បារ។ មេល្បួងបានសួរ *អេវ៉ា* នូវព្រះបន្ទូលរបស់ព្រះ ហើយវាបាន កុហក ឯ*អេវ៉ា* ក៏បានជឿវាជំនួសអោយព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អេវ៉ាបានមើល និងបេះ រួចក៏ហូបផ្លែឈើដែលបានហាមឃាត់ ហើយក៏អោយទៅអាដាំបរិភោគដែរ។ រំពេចនោះភ្នែករបស់ពួកគេបានភ្លឺឡើង ហើយឃើញអំពើបាប ដែលពីមុនពួកគេជាមនុស្សបរិសុទ្ធគ្មានទោសសោះ។ ឥឡូវពួកគេមើលឃើញថាគេមានទោស និងនៅអាក្រាត ហើយពួកគេមានការភ័យខ្លាចយ៉ាងខ្លាំង។ *អាដាំ* និង*អេវ៉ា* បានជ្រើសរើសផ្លូវនៃសេចក្ដីស្លាប់។ ត្បិត "លទ្ធផលនៃអំពើបាបគឺសេចក្ដីស្លាប់" *រ៉ូម ៦:២៣* ។

សេចក្ដីស្លាប់មានន័យថា "*ការដាច់ចេញពីព្រះជាម្ចាស់* "មិនគ្រាន់តែនៅក្នុងជីវិតនេះប៉ុណ្ណោះទេ ប៉ុន្តែជារៀងរហូតតទៅ។ *អាដាំ* និង*អេវ៉ា* បានព្យាយាមគ្របបាំងអំពើបាបរបស់ខ្លួនដោយដៃរបស់ពួកគេផ្ទាល់ ដោយពួកគេបានដេរស្លឹកល្វារួមគ្នាដើម្បីធ្វើការគ្របបាំងរាងកាយ។

បន្ទាប់មកពួកគេព្យាយាមពួនពីព្រះជាម្ចាស់ក្នុងចំណោមរុក្ខជាតិ ព្រះអង្គបានយាងមក ដើម្បីស្វែងរកពួកគេ។ ទ្រង់បានយាងមកពីព្រោះទ្រង់ស្រលាញ់ពួកគេ ហើយក៏ព្រោះតែទ្រង់ត្រូវប្រកាសអំពីការវិនិច្ឆ័យចំពោះអំពើបាបរបស់ពួកគេ។ ព្រះទ្រង់បានដាក់បណ្ដាសារលើសត្វ*ពស់ ស្ត្រី បុរស* ហើយនិង *ផែនដី* ។ តើបណ្ដាសារទាំងនោះមានអ្វីខ្លះ? *កំណើតពិភពលោក៣:១៤-១៩* ប្រាប់យើងពីការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ចំពោះពួកគេគ្រប់ៗគ្នា។ ទ្រង់ធ្វើកិច្ចការទាំងនេះ ព្រោះតែជា ប្រយោជន៍សំរាប់*អាដាំ*។

ជាមួយនឹងបណ្ដាសារព្រះ ដែលពោរពេញដោយព្រះគុណសេចក្ដីស្រលាញ់ និងសេចក្ដីមេត្តាករុណាក៏បានប្រទានការសន្យាអំពីអ្នករំដោះដ៏អស្ចារ្យ ដែលនឹងមកនៅថ្ងៃណាមួយ ដើម្បីយកជ័យជំនះលើ*អំពើបាប និងសេចក្ដីស្លាប់* ហើយជាន់ក្បាលរបស់*ពស់ កំណើតពិភពលោក ៣:១៥*។ នៅក្នុង *១កូរិនថូស ១៥:៤៥* អង្គដែលនឹងមករំដោះនោះត្រូវបានគេហៅថា "*លោកអាដាំចុងក្រោយបង្អស់*" ទ្រង់គឺជា *ព្រះអម្ចាស់យេស៊ូគ្រិស្ត* ជាអង្គដែលលះព្រះជន្មរបស់ទ្រង់លើឈើឆ្កាងនៅភ្នំ *កាល់វ៉ារី* ជាព្រះដែលមានជ័យជំនះលើអំពើបាប និងសេចក្ដីស្លាប់ ហើយយកឈ្នះលើវិញ្ញាណអាក្រក់ (សាតាំង) ផងដែរ។

ព្រះជាម្ចាស់បានសំលាប់សត្វមួយនៅក្នុងសួនច្បារ ឈាមរបស់សត្វនោះត្រូវបានបង្ហូរ ហើយសត្វដែលគ្មានកំហុសនោះត្រូវបានស្លាប់ស្បែករបស់វាត្រូវបានផ្ដល់អោយទៅ *អាដាំ* និង*អេវ៉ា* សំរាប់បិទបាំងភាពអាម៉ាស់ និងភាពអាក្រាតរបស់ពួកគេ។ មានតែព្រះជាម្ចាស់មួយអង្គគត់ ដែលអាចផ្ដល់ការគ្របបាំងអំពើបាបរបស់ពួកយើង ហើយវាជាស្រមោលនៃ*ព្រះអម្ចាស់យេស៊ូគ្រិស្ត* ដែលមិនគ្រាន់តែជាការគ្របបាំងអំពើបាបរបស់មនុស្សប៉ុណ្ណោះទេ ថែមទាំងជាការដកនូវអំពើបាបចេញដោយ ការសុគតរបស់ទ្រង់លើឈើឆ្កាង។

រឿងរ៉ាវរបស់អ្នកដំណើរដំបូងគឺស្ដីអំពី*មនុស្សបាបដំបូង*។ លោក*អាដាំ* ដំបូងបានប្រព្រឹត្តអំពើបាប ហើយគ្រប់គ្នាដែលកើតមកពីលោកក៏មានអំពើបាបជាប់មកជាមួយ និងប្រព្រឹត្តអំពើបាបថែមទៀតផង។ ពួកគេទាំងអស់គ្នាមានលក្ខណៈនៃអំពើបាបដូចអ្នកដែលបង្កើតពួកគេដែរ *រ៉ូម៥:១២-១៤ "លទ្ធផលនៃអំពើបាបគឺសេចក្ដីស្លាប់* " ដូច្នេះគ្រប់ៗគ្នាត្រូវស្លាប់

ទោះបីអ្នកដែលរស់នៅក្នុង សម័យនៃព្រះគុណនេះក៏ដោយក៏ដូចអ្នកពីអតីតកាលដែរគឺត្រូវស្លាប់ ។ *"ការប្រទានរបស់ព្រះជាម្ចាស់គឺជីវិតអស់កល្បជានិច្ចដោយរួមជាមួយអង្គ ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង"* ការប្រព្រឹត្តរបស់ *អាដាំ* និង *អេវ៉ា* មិនអាចធ្វើអោយព្រះជាម្ចាស់ទទួលយកបានទេ ក៏ដូចជាការប្រព្រឹត្តរបស់មនុស្សសព្វថ្ងៃដែរ ។ ដោយស្បែកសត្វគឺអាចផ្តល់នូវការគ្របបាំងដល់*អាដាំ* និង*អេវ៉ា* ផ្នែកសាច់ឈាម ដូច្នេះព្រះយេស៊ូគ្រិស្តបានប្រទានការគ្របបាំងដ៏ចាំបាច់បំផុតនៃភាពសុចរិតដល់អស់អ្នកដែលទទួលទ្រង់ជាព្រះសង្គ្រោះ ។

តើជំរើសអ្វីដែលអ្នកបានជ្រើសរើស? តើអ្នកស្ថិតនៅលើផ្លូវដែលមើលទៅហាក់ដូចជានាំទៅ រកភាពត្រឹមត្រូវតែជាផ្លូវនាំទៅរកសេចក្តីស្លាប់ឬ? ឬក៏អ្នកបានទទួលព្រះអម្ចាស់យេស៊ូគ្រិស្តជាព្រះសង្គ្រោះផ្ទាល់ខ្លួនសំរាប់អំពើបាបរបស់អ្នក ហើយអ្នកស្ថិតនៅលើផ្លូវដែលនាំទៅរកជីវិតអស់កល្បជានិច្ចឬ?

**ខគម្ពីរចងចាំ** : *រ៉ូម៦:២៣" ត្បិតលទ្ធផលនៃអំពើបាបគឺសេចក្តីស្លាប់ រីឯព្រះអំណោយ ទានរបស់ព្រះជាម្ចាស់វិញគឺជីវិតអស់កល្បជានិច្ចរួមជាមួយព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង ។"*

## <u>សំនួររំឭករំលឹក មេរៀនទី១</u>

១.តើនៅលើផែនដីនេះ"មាគ៌ានៃជីវិត"ចាប់ផ្តើមនូវឯណា? កំណើតពិភពលោក២:៨....................................

....................................................................................................................................... ។

២.តើនៅលើផែនដីនេះ"មាគ៌ានៃជីវិត" នឹងត្រូវបានបញ្ចប់នៅកន្លែងណា? វិវរណៈ២១:១...........................

....................................................................................................................................... ។

៣.ចូរសរសេរបទគម្ពីរ សុភាសិត ១៤:១២:.......................................................................................

.........................................................................................................................................

....................................................................................................................................... ។

៤.តើអ្វីដែលជាច្បាប់ធ្វើដំណើរនៅក្នុងសួនច្បារ"អេដែន"? កំណើតពិភពលោក ២:១៥-១៧

ក).......................................................................................... ។

ខ).......................................................................................... ។

គ).......................................................................................... ។

៥.តើអ្វីដែលជាបណ្តាសារដែលព្រះជាម្ចាស់បានដាក់ចំពោះសត្វពស់? កំណើតពិភពលោក៣:១៤-១៥.................

......................................................................................................................................... ។

៦.ចុះអេវ៉ាវិញ? កំណើតពិភពលោក ៣:១៦ .......................................................................................

....................................................................................................................................... ។

៧.ចុះលោកអាដាំវិញ? កំណើតពិភពលោក ៣:១៧-១៩..........................................................................

....................................................................................................................................... ។

៨.ចូរសរសេរពីទំនាយដំបូងនៅក្នុងព្រះគម្ពីរ អំពីព្រះអម្ចាស់យេស៊ូគ្រិស្ត កំណើតពិភពលោក ៣:១៥...............

.................................................................................................................................................................

.................................................................................................................................................................។

៩.យើងគឺដូចអាដាំនិងអេវ៉ានៅក្នុងបីចំនុច។ ចូរមើលក្នុងខគម្ពីរហើយបំពេញនៅឃ្លាខាង ក្រោម:

ក).រ៉ូម ៣:២៣ យើងទាំងអស់គ្នាមាន...................................................................................................

..................................................................................................។

ខ).រ៉ូម ៥:១២ យើងទាំងអស់គ្នានឹង.....................................................................................................

..................................................................................................។

គ)រ៉ូម ៦:២៣ យើងទាំងអស់គ្នាអាចមាន..............................................................................................

............................................................ តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះរបស់យើង។

១០.ចូរសរសេរខព្រះគម្ពីរចងចាំ រ៉ូម ៦:២៣

..........................................................................................................................................................................

..........................................................................................................................................................................

..............................................................................................................................................................។

## មេរៀនទី២ : កុមារដំបូងលើមាគ៌ានៃជីវិត

**កំណើតពិភពលោក ៤:១-១៦**

**គំនិតសំខាន់: ដើម្បីបង្ហាញថាបើគ្មានជំនឿគ្មាននរណាម្នាក់អាចគាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ។**

តើអ្នកអាចទាយបានទេថា តើអ្វីដែលជាអំណោយដ៏អស្ចារ្យបំផុតដែលព្រះជាម្ចាស់ប្រទានដល់គ្រួសារមួយ? វាមិនមែនជាផ្ទះថ្មី ហើយក៏មិនមែនជាយានជំនិះដែរ *"ប៉ុន្តែអំណោយនោះគឺជាទារកមួយ"* វិញ។ គ្មាននរណាម្នាក់អាចធ្វើកិច្ចការនេះបានទេ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចធ្វើការអស្ចារ្យនេះបាន ហើយក៏មានតែទ្រង់មួយប៉ុណ្ណោះដែលអាចប្រទានអោយបាន។

ពេលដែលយើងធ្វើដំណើរលើ "មាគ៌ានៃជីវិត" ដ៏វែងឆ្ងាយនេះយើងនឹងឃើញទារកជាច្រើន ប៉ុន្តែនៅក្នុងមេរៀននេះយើងនឹងផ្តោតសំខាន់ទៅលើទារកដែលកើតដំបូងបង្អស់នៅលើ ពិភពលោកនេះ។ អ្នកដឹងហើយថា *អាដាំ* និង*អេវ៉ា* មិនធ្លាប់បានកើតជាទារកទេ ព្រោះព្រះជាម្ចាស់បានបង្កើតពួកគេក្នុងភាពជាបុរស និងស្ត្រីតែម្តង។

បន្ទាប់ពី*អាដាំ* និង*អេវ៉ា* បានប្រព្រឹត្តអំពើបាបពួកគេត្រូវបានព្រះជាម្ចាស់បណ្តេញចេញពីសួនច្បារអេដែន ដែលជាកន្លែងព្រះជាម្ចាស់បានដាក់ពួកគេនៅទីនោះ។ ពួកគេត្រូវតែចាប់ផ្តើមជីវិតថ្មី *កំណើតពិភពលោក ៣:២៣-២៤*។ ថ្ងៃមួយព្រះជាម្ចាស់បានប្រទានអំណោយដ៏អស្ចារ្យ គឺជាទារកមួយអោយកើតឡើងនៅក្នុងគ្រួសារថ្មីមួយនោះ។ អេវ៉ាបានពោលថា*: "ខ្ញុំបានបង្កើតមនុស្សម្នាក់ព្រោះព្រះជាម្ចាស់បានប្រទានអោយ" កំណើតពិភពលោក ៤:១។* ប្រហែលជានាងគិតថាទារកនោះ គឺជាការសន្យាមួយនៅក្នុង *កំណើតពិភពលោក ៣:១៥* ជាអ្នកដែលច្បាំងនឹងសាតាំង។ នាងបានដាក់ឈ្មោះកូនប្រុសដំបូងនោះថា *កាអ៊ីន*។

ក្រោយមកទៀត នាងក៏មានកូនប្រុសម្នាក់ទៀត ហើយនាងបានហៅគាត់ថា: *អេបិល* ។ ឥឡូវមានក្មេងប្រុសពីរនាក់នៅលើ *"មាគ៌ានៃជីវិត"*។

តើអ្នកចងចាំខគម្ពីរនៅមេរៀនទី១ទេ "មានមនុស្សខ្លះយល់ថាផ្លូវដែលខ្លួនដើរជាផ្លូវត្រឹមត្រូវ..."។ តើអ្នកគិតថាផ្លូវមួយណាដែលក្មេងប្រុសទាំងពីរនេះជ្រើសរើសយក? *អាដាំ* និង*អេវ៉ា* បានបង្ហាញដល់កូនរបស់ពួកគេនូវរបៀបនៃការថ្វាយយញ្ញបូជាជាឈាមដោយជំនឿ និងការស្តាប់បង្គាប់ព្រះជាម្ចាស់ដែលត្រូវបានបង្ហាញតាមរយៈទ្រង់។ មិនមានច្បាប់ថ្មីនាមួយបានដាក់លើក្មេងប្រុសទាំងពីរ ហើយក៏ដូចជាលោកអាដាំនិងអេវ៉ាដែរ។ ការតំរូវតែមួយនោះគឺពួកគេត្រូវថ្វាយបង្គំព្រះជាម្ចាស់តាមរបៀបដែលព្រះជាម្ចាស់បានកំណត់។

លោកអេបិលបានក្លាយជាអ្នកគង្វាលជាអ្នកថែរក្សាសត្វចៀម រីឯកាអ៊ីនបានក្លាយជាកសិករម្នាក់គឺជាអ្នកកាប់គាស់ភ្ជួររាស់ដី។ ពេលវេលាបានមកដល់នៅពេលដែលពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការសំរេចចិត្ត ជ្រើសរើសផ្លូវផ្ទាល់ខ្លួនរបស់ពួកគេគឺផ្លូវដែលពួកគេនឹងដើរ។ រីឯយើងរាល់គ្នាវិញក៏ដូច្នោះដែរ។ គ្មាននរណាម្នាក់អាចធ្វើការជ្រើសរើសសំរាប់យើងបានទេគឺមានតែខ្លួនយើងប៉ុណ្ណោះ។

កាអ៊ីនរៀបចំការថ្វាយដង្វាយរបស់គាត់ដែលជា *"ផ្លែឈើដ៏ស្រស់ល្អបានមកពីចំការ ដែលគាត់បានធ្វើការយ៉ាងលំបាកក្នុងការដាំដុះគាត់រំពឹងថាព្រះជាម្ចាស់ពិតជាសព្វព្រះហឫទ័យចំពោះ ដង្វាយរបស់គាត់មិនខាន" (ប៉ុន្តែដង្វាយរបស់គាត់មិនស្របតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ទេ)*។ គាត់បានដាក់ដង្វាយរបស់គាត់លើអាសនៈ(កន្លែងថ្វាយយញ្ញបូជា)មួយ។ តើព្រះសព្វព្រះហឫទ័យជាមួយកិច្ចការដែលអាដាំ និងអេវ៉ាធ្វើឬទេ? ទេ! ទ្រង់មិនសព្វព្រះហឫទ័យនឹងកិច្ចការរបស់មនុស្សសោះ សូម្បីតែស្លឹកល្វាសំរាប់គ្របបាំងរាងកាយរបស់ពួកគេ។ ក៏ដូចជាដង្វាយជាច្រើនទៀតដែលព្រះគម្ពីរហៅថា *"ការប្រព្រឹត្ត"*។

ខុសពីកាអ៊ីន អេបិលបានយកកូនចៀមរបស់គាត់មួយ ហើយបានសំលាប់វា និងដាក់នៅ លើអាសនៈជាដង្វាយមួយសំរាប់ព្រះជាម្ចាស់។ គាត់បានយកឈាមនៃយញ្ញបូជា ដូចព្រះអង្គបាន បង្ហាញ ដល់លោកអាដាំ និងអេវ៉ា។

តើកាអ៊ីន និងអេបិលជាមនុស្សមានអំពើបាបរឺ? ពិតមែនហើយ! ពួកគេបានកើត មកជាមនុស្សដែលមានអំពើបាប ហើយពួកគេក៏នៅតែជាមនុស្សជាប់អំពើបាបដដែល។ អញ្ចឹង! តើមានអ្វីកើតឡើង? ព្រះជាម្ចាស់បានគាប់ព្រះហឫទ័យនឹងដង្វាយរបស់អេបិល ប៉ុន្តែទ្រង់មិនគាប់ព្រះហឫទ័យនឹងដង្វាយរបស់កាអ៊ីនទេ។ កាអ៊ីនបានខឹងសំបារជាខ្លាំងហើយបានសំលាប់អេបិលដែល ជាប្អូនប្រុសរបស់គាត់។ តើព្រះជាម្ចាស់គាប់ព្រះហឫទ័យលើឃាតកម្មដែលកើតឡើងដំបូងលើផែនដីនេះដែររឺទេ? ទេ! ទ្រង់មិនគាប់ព្រះហឫទ័យចំពោះកិច្ចការនេះទេ។ ព្រះជាម្ចាស់បានដាក់ទោសកាអ៊ីនដោយបណ្តេញគាត់ចេញឆ្ងាយពីទឹកដីកំណើតរបស់គាត់អោយទៅកាន់ទឹកដីដទៃទៀត ព្រោះតែអំពើបាបដែលគាត់បានប្រព្រឹត្ត *កំណើតពិភពលោក ៤:៦-១៦* ក្មេងប្រុសទាំងពីរនេះត្រូវបានចិញ្ចឹមក្នុងផ្ទះតែមួយ ហើយត្រូវបានបង្រៀនពីសេចក្តីពិតដូចៗគ្នា។ ប៉ុន្តែចំនុចដែលខុសគ្នានោះគឺអេបិលបានជឿ ឬមានសេចក្តីជំនឿទៅលើអ្វីដែលគាត់បានរៀន ឯ*កាអ៊ីន* វិញមិនបានជឿទៅលើអ្វីដែលគាត់បានរៀនឡើយ។ សកម្មភាពរបស់ពួកគេបានបង្ហាញពីអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេ។

ការមិនជឿគឺជាការមួយដ៏អាក្រក់ ដែលវានឹងដឹកនាំមនុស្សទៅកាន់កំហឹង ការបោក ប្រាស់ ឃាតកម្ម ការកុហក ហើយចុងបញ្ចប់នាំទៅរកការដាក់ពិន័យដ៏ធ្ងន់ធ្ងរគឺការដាច់ចេញ ពីព្រះជាម្ចាស់ *កំណើតពិភពលោក ៤:៨-១២*។ ការជឿ និងសេចក្តីជំនឿបាននាំមកនូវសន្តិភាព និងភាពសុចរិតដល់លោកអេបិល ហើយព្រះជាម្ចាស់មានបន្ទូលថា *"ទោះបីអេបិលស្លាប់ទៅហើយក្តីគាត់នូវតែមានប្រសាសន៏នៅឡើយ" ហេប្រឺ:១១:៤*។ ព្រះទ្រង់មានព្រះបន្ទូលទៀតថា: *"បើគ្មានជំនឿគ្មាននរណាអាចគាប់ព្រះហឫទ័យទ្រង់បានឡើយ"*។

តាមផែនទីមិនថាយើងរស់នៅក្នុងសម័យព្រះគុណ ឬនៅសម័យកាលណាក៏ដោយសេចក្តីជំនឿមានសារៈសំខាន់ណាស់ ដើម្បីអោយព្រះជាម្ចាស់គាប់ព្រះហឫទ័យ។ ព្រះជាម្ចាស់បានទតមើលដង្វាយរបស់អេបិល ហើយតាមរយៈឈាមរបស់ចៀមទ្រង់បានទតឃើញព្រះអម្ចាស់ព្រះយេស៊ូគ្រីស្តដែលជាកូនចៀមដ៏ពិតប្រាកដមុនកំណើតពិភពលោកទៅទៀត។ *១ពេត្រុស១:១៩-២០*។ សព្វថ្ងៃនេះយើងមិនបង្ហាញសេចក្តីជំនឿរបស់យើងដោយការយកចៀមទៅថ្វាយនៅលើអាសនៈនោះទេ តែដោយយើងចូលមកឯឈើឆ្កាងរបស់ព្រះយេស៊ូគ្រីស្ត ហើយទទួលទ្រង់ជាព្រះសង្គ្រោះបេស់យើង។

ជាថ្មីម្តងទៀត យើងបានឃើញសេចក្តីពិតនៅក្នុងខគម្ពីរថា "មានមនុស្សខ្លះយល់ថាផ្លូវ ដែលខ្លួនដើរជាផ្លូវត្រឹមត្រូវ...." កូនប្រុសម្នាក់បានដើរលើផ្លូវត្រឹមត្រូវ រីឯម្នាក់ទៀតបានដើរលើផ្លូវមិនត្រឹមត្រូវលើ "មាគ៌ានៃជីវិត"។ ព្រះគម្ពីរ

បានចែងថាមានមនុស្សជាច្រើននាក់ សព្វថ្ងៃនេះដែលកំពុងដើរលើផ្លូវរបស់កាអ៊ីន *យូដាស ខ ១១* ។ ពួកគេទាំងនោះជាអ្នកដែលងាកចេញពីព្រះជាម្ចាស់ ហើយពួកគេជាអ្នកដែលពឹងផ្អែកទៅលើកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីទទួលសេចក្តីសង្គ្រោះ។ គ្មានអ្វីដែលយើងអាចធ្វើដោយដៃ ឬដោយខ្លួនយើងដែលអាចនាំអោយមានការសង្គ្រោះសំរាប់ខ្លួនយើងបានឡើយ។

សព្វថ្ងៃនេះបើសិនជាយើងចង់បង្ហាញសេចក្តីជំនឿរបស់យើង យើងត្រូវចូលមកឯព្រះអម្ចាស់យេស៊ូនិងទូលទ្រង់ថា "ខ្ញុំជឿថាទ្រង់បានសុគតសំរាប់អំពើបាបខ្ញុំ។ ទូលបង្គំអរព្រះគុណទ្រង់សំរាប់ការបូជារបស់ព្រះអង្គ ហើយខ្ញុំជឿថាទ្រង់នឹងប្រទានដល់ខ្ញុំនូវភាពសុចរិតដ៏អស្ចារ្យរបស់ទ្រង់ព្រោះទ្រង់បានសន្យា។

**ខគម្ពីរចងចាំ** : ហេប្រឺ១១:៦ "បើគ្មានជំនឿគ្មាននរណាអាចគាប់ព្រះហឫទ័យទ្រង់បានឡើយ។ អ្នកចូលមកជិតព្រះជាម្ចាស់ត្រូវតែជឿថាពិតជាមានព្រះមែន ហើយជឿថាព្រះអង្គនឹងប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរក ព្រះអង្គ" ។

## សំនួររំឭកមេរៀនទី២

១.សរសេរឈ្មោះកុមារដំបូងទាំងពីរលើ"មាគ៌ានៃជីវិត" *កំណើតពិភពលោក៤:១-២.* ....................................

...........................................ហើយនិង.................................................................................។

២.តើអេបិលមានមុខរបរអ្វី? *កំណើតពិភពលោក ៤:២*.................................................... ............។

៣.តើកាអ៊ីនមានមុខរបរអ្វី? *កំណើតពិភពលោក ៤:២*.................... ................. ...............................។

៤.ហេតុអ្វីបានជាព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងដង្វាយដែល កាអ៊ីនបានថ្វាយ? *ហេប្រឺ ១១:៦*................

.......................................................................................................................................................។

៥.ហេតុអ្វីបានជាព្រះជាម្ចាស់សព្វហឫទ័យនឹងដង្វាយដែលអេបិលបានថ្វាយ? *ហេប្រឺ ១១:៤*.........................

............................................................................................................ .........................................។

៦.ហេតុអ្វីបានជាដង្វាយរបស់អេបិលមានលក្ខណៈល្អប្រសើរជាងដង្វាយរបស់កាអ៊ីន? ហេប្រឺ ៩:២២...............

....................................................................................................................................................

.................................................................................................... .....................................................។

៧.អេបិលបានបង្ហាញភស្តុតាងនៃសេចក្តីជំនឿរបស់គាត់ ដោយសារការដាក់ដង្វាយដែលគាត់បាននាំយក ហើយលោកត្រូវបានព្រះជាម្ចាស់ផ្តល់សក្ខីភាពថាលោកជា...........................................................................................

........................................................................................................................ ......... *ហេប្រឺ១១:៤*។

៨.ដង្វាយរបស់អេបិលជាឧទាហរណ៍នៃ.......................................................................................................

.....................................................................................................................................យ៉ូហាន១:២៩។

៩. សព្វថ្ងៃនេះយើងទទួលភាពសុចរិតដោយមានជំនឿលើ..................................................................

............................................................................................................................................................................១យ៉ូហាន ១:៧។

១០.ចូរគូររូបភាពនៃដង្វាយរបស់អេបិល និងរូបភាពនៃឈើឆ្កាងដែលព្រះយេស៊ូគ្រីស្ទក្លាយជាដង្វាយនៃអំពើបាបសំរាប់យើង។

## មេរៀនទី៣: អ្នកបើកយានដំបូង

**កំណើតពិភពលោក ៥:១-៣២**

**គំនិតសំខាន់ : ដើម្បីដាស់តឿនដល់អស់អ្នកមិនជឿ និងដើម្បី រៀបចំអ្នកដែលមានជំនឿសំរាប់ការលើកឡើងទៅឋានសួគ៌។**

តើអ្នកចូលចិត្តធ្វើដំណើរតាមផ្លូវណា? មានមនុស្សជាច្រើនចូលចិត្តប្រើប្រាស់យន្តហោះ ប៉ុន្តែតើយើងអាចធ្វើដំណើរក្នុងលំហអាកាសបានដោយរបៀបណាបើសិនយើងមិនប្រើយន្តហោះ? ដោយការហោះឡើងទៅលើឬ? នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានបុរសម្នាក់ដែលធ្វើដំណើរលើ "*មាគ៌ានៃជីវិត* " ហើយជាអ្នកដែលធ្វើដំណើរក្នុងលំហអាកាសដោយមិនប្រើយន្តហោះ។

បន្ទាប់ពីកាអ៊ីនបានសំលាប់អេបិលមក ព្រះជាម្ចាស់បានប្រទានកូនប្រុសមួយទៀតដល់អេវ៉ាហើយនាងបានដាក់ឈ្មោះគាត់ថា"*សេថ* "។ ព្រះទ្រង់បានសន្យាប្រទានអង្គប្រោសលោះមួយអង្គដែលជាអ្នកដែលកើតចេញពីខ្សែបន្ទាត់នៃមនុស្សកោតខ្លាចព្រះជាម្ចាស់។ ប៉ុន្តែជាច្រើនឆ្នាំបានកន្លងទៅមនុស្សកាន់តែកើនចំនួនច្រើនឡើងបន្តបន្ទាប់ ហើយអំពើទុច្ចរិតក៏ចេះតែកើនឡើងឥតឈប់ឈរ។ មនុស្សម្នាក់ៗត្រូវតែធ្វើការជ្រើសរើសផ្លូវដែលគេត្រូវទៅ។ មនុស្សភាគច្រើនបានជ្រើសរើសផ្លូវដែលខ្លួនយល់ថាហាក់ដូចជាត្រឹមត្រូវមានតែមនុស្សមួយចំនួនប៉ុណ្ណោះ ដែលជ្រើសរើសផ្លូវនៃសេចក្តីជំនឿ។

មនុស្សនៅជំនាន់នោះមានអាយុវែង។ យើងអាចអានអំពីអាយុរបស់ពួកគេដែលនៅជំនាន់លោក "*សេថ* " បាននៅ *កំណើតពិភពលោក ៥:៦-៣២*។ អ្នកមានអាយុចំណាស់ជាងគេគឺ "*ម៉ាធូសាឡឹម* " ដែលបានរស់ដល់អាយុ ៩៦៩ ឆ្នាំ *កំណើតពិភពលោក៥:២៧*។ *ម៉ាធូសាឡឹម* គឺជាកូនរបស់លោក*ហេណុក* ជាអ្នកដែលយើងហៅថា "*អ្នកបើកយានដំបូង* "។

តើអ្នកបានកត់ចំណាំទេពេលដែលអ្នកអានព្រះគម្ពីរប្រវត្តិសាស្រ្ត ដែលបានបញ្ចប់ដោយពាក្យនោះគឺថា "*ហើយគាត់ក៏ទទួលមរណៈភាព* " លើកលែងតែបុរសម្នាក់ហេតុអ្វី? ពីព្រោះលទ្ធផលនៃអំពើបាបគឺសេចក្តីស្លាប់។ តើវាធ្វើអោយយើងរីករាយ ឬនៅពេលមានបុណ្យសពនោះ? នៅក្នុងមេរៀននេះ យើងនឹងសិក្សាពីផ្លូវមួយដែលអាចយកឈ្នះលើការភ័យខ្លាចនៃសេចក្តីស្លាប់ហើយវាក៏អាចដែរ ដែលថាក្នុងចំណោមយើងរាល់គ្នា អ្នកខ្លះនឹងមិនស្លាប់ខាងសាច់ឈាមឡើយ។

លោកហេណុកបានដើរតាមមាគ៌ានៃព្រះជាម្ចាស់ *កំណើតពិភពលោក៥:២៤*។ លោកមានការប្រកបជាមួយព្រះជាម្ចាស់ដែលមានន័យថាគាត់ដើរដោយជំនឿ។ វាក៏មានន័យថាលោកបាននាំយកដង្វាយសុចរិតមកថ្វាយព្រះជាម្ចាស់ផងដែរ។ មនុស្សពីរនាក់មិនអាចធ្វើដំណើរជាមួយគ្នាបាន ទេ បើសិនជាពួកគេមិនបានព្រមព្រៀងគ្នា *អម៉ូស ៣:៣*។ ដូច្នេះសេចក្តីជំនឿរបស់លោកហេណុក គឺជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់។

លោកហេណុកតែងតែចែកចាយ និងធ្វើជាស្មបន្ទាល់អំពីព្រះជាម្ចាស់ *យូដាស ១៤-១៥*។ មនុស្សកាន់តែឃ្លាតឆ្ងាយពីព្រះជាម្ចាស់។ ពួកគេកំពុងដើរទៅក្នុងផ្លូវផ្ទាល់ខ្លួនរបស់ពួកគេ ដោយពោលពាក្យសរសើរមនុស្សលោក ហើយត្អូញត្អែរអំពីព្រះ។ លោកហេណុកបានព្រមានពួកគេថាព្រះអម្ចាស់នឹងយាងមកនៅថ្ងៃណាមួយ ប៉ុន្តែពួកគេបែរជាចំអកឡកឡឺយដាក់លោកទៅវិញ។

ថ្ងៃមួយនៅពេលដែលលោកមានអាយុ ៣៦៥ឆ្នាំ គាត់ក៏បាត់ខ្លួនពីផែនដីគ្មាននរណា ឃើញគាត់ទៀតឡើយ។ ដោយសារជំនឿគាត់ត្រូវបានព្រះជាម្ចាស់លើកឡើងទៅឋានសួគ៌ *ហេព្រើ ១១:៥-៦*។

យើងមិនអាចយល់ពីរបៀបដែលលោកហេណុកប្ដូរទ្រង់ទ្រាយ ហើយត្រូវព្រះអង្គលើកទៅស្ថានសួគ៌នោះបានឡើយ។ កិច្ចការដ៏អស្ចារ្យអំពីហេតុការណ៍នេះគឺវាធ្វើអោយយើងដឹងប្រាកដនូវអ្វីដែលនឹងកើតឡើងដល់អស់អ្នកជឿនៅក្នុង*អាកាសយានព្រះគុណ* នៅថ្ងៃណាមួយ។ ព្រះជាម្ចាស់បានបង្ហាញគំរោងការលាក់កំបាំងដល់សាវ័កប៉ូលដែលថាថ្ងៃណាមួយព្រះអម្ចាស់យេស៊ូគ្រីស្ទនឹងយាងមកពីស្ថានបរមសុខជាមួយសំលេងត្រែ។ ផ្នូរទាំងឡាយនឹងបើកចំហឡើង ហើយអស់អ្នកដែលមានសេចក្ដីជំនឿនឹងចេញមកខាងក្រៅ។

អស់អ្នកដែលមានជីវិតរស់នៅក្នុងពេលនោះ នឹងត្រូវលើកឡើងជាមួយអស់អ្នកដែលស្លាប់ ដើម្បីទៅជួបព្រះជាម្ចាស់នៅក្នុងលំហអាកាស *១ថេស្សាឡូនិក ៤:១៣-១៧*។ ដែលយើងហៅថា "*ការលើកឡើង*" មានន័យថា *ការលើកអស់អ្នកដែលជឿទៅស្ថានសួគ៌* ដោយព្រះជាម្ចាស់នៅក្នុងក្រុមជំនុំរបស់ព្រះអង្គដែលជា "រូបកាយនៃព្រះគ្រីស្ទ"។ អ្នកជឿនៅក្នុងក្រុមជំនុំនេះគឺជា រូបភាពនៅក្នុងផែនទីនៃ "អាកាសយាននៃការសង្គ្រោះ"។

សាវ័កប៉ូលបានហៅព្រឹត្តការណ៍ដ៏អស្ចារ្យនេះថា: "*សេចក្ដីសង្ឃឹមរបស់យើង*" *ទីតុស ២:១៣*។ យើងមិនត្រូវភ័យខ្លាចចំពោះសេចក្ដីស្លាប់ឡើយ ព្រោះយើងមានសេចក្ដីសង្ឃឹម។ អ្នកខ្លះនិយាយថា "*ខ្ញុំកំពុងរង់ចាំព្រះអម្ចាស់យាងមក*" ហើយនេះគឺជាសេចក្ដីពិតមួយ។ យើងនឹងមិនត្រូវការសោកសង្វេគនៅពេលដែលនរណាម្នាក់ស្លាប់ (*ប្រសិនបើគាត់ពិតជាបានសង្គ្រោះមែន*) ព្រោះយើងដឹងថាយើងនឹងត្រូវបានលើកឡើងទៅជាមួយអ្នកដែលស្លាប់រួមជាមួយព្រះគ្រីស្ទ។ វាដូចជាមានសេចក្ដីសុខមួយដែលដឹងអំពីសេចក្ដីពិតនេះ។ ព្រះជាម្ចាស់ចង់អោយយើងក្លាយជាស្មបន្ទាល់សំរាប់ពិភពលោកពេលដែលយើងរង់ចាំសំរាប់ "*ការលើកឡើង*"។ ទ្រង់ចង់អោយយើងព្រមានពួកគេពីលទ្ធផលនៃអំពើបាប ហើយប្រាប់ពួកគេអំពីជីវិតអស់កល្បក្នុងអង្គព្រះយេស៊ូគ្រីស្ទ។

បន្ទាប់ពីអ្នកជឿត្រូវបានលើកឡើងចេញពីពិភពលោកនេះ បន្ទាប់មកជាពេលវេលាដែលឈឺចាប់នៃការវិនិច្ឆ័យនឹងមកដល់។ តើនឹងមានភាពក្រៀមក្រំដូចម្ដេចទៅ បើអ្នកត្រូវបានលើកឡើងជាមួយព្រះជាម្ចាស់ ប៉ុន្តែឪពុកម្ដាយរបស់អ្នកត្រូវបានទុកចោលនោះ? តើអ្នកបានប្រាប់ពួកគាត់ដោយស្មោះត្រង់អំពីសេចក្ដីជំនឿលើព្រះយេស៊ូគ្រីស្ទ ដែលបានសុគតជំនួសបាបរបស់ពួកគាត់ហើយ រឺនៅ? តើអ្នកមានភាពអាម៉ាស់ដូចម្ដេចទៅប្រសិនបើអ្នកធ្វើអ្វីមួយមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់ នៅពេលដែលព្រះគ្រីស្ទយាងមកហើយហៅយើងទៅឯទ្រង់? វិធីល្អបំផុតគឺដោយការរស់នៅក្នុងជីវិតមួយដែលស្អាត និងជីវិតសុទ្ធគ្រប់ពេលវេលា។

ក្នុងមេរៀនទី៤ អ្នកនឹងរៀនអំពីការវិនិច្ឆ័យដ៏អស្ចារ្យដែលកើតឡើង លើពិភពលោកបន្ទាប់ពីលោក *ហេណុក* ត្រូវបានព្រះជាម្ចាស់លើកឡើង។ តើអ្នកប្រាកដទេថាអ្នកមានសុវត្ថិភាពនៅក្នុង "*អាកាសយាននៃការសង្គ្រោះ*" ដែលទន្ទឹងរង់ចាំព្រះគ្រីស្ទយាងត្រលប់មកហើយនាំយើងទៅជាមួយទ្រង់ដែរ រឺទេ? តើអ្នកបានទទួលព្រះយេស៊ូគ្រីស្ទជាព្រះសង្គ្រោះរបស់អ្នកហើយឬនៅ?

**ខព្រះគម្ពីរចងចាំ:** *១ថែស្សាឡូនិក៤:១៧* បន្ទាប់មកទើបព្រះអម្ចាស់លើក យើងដែលនៅរស់នៅឡើយអោយឡើង ទៅក្នុងពពកជាមួយបងប្អូនទាំងនោះ ដើម្បីជួបព្រះអង្គក្នុងអាកាសវេហាស៍ ហើយយើងនឹងស្ថិតនៅជាមួយព្រះអម្ចាស់រហូតតទៅ ។

## សំនួររំឭកៈ មេរៀនទី៣

ចូរគូសបន្ទាត់ពីក្រោមពាក្យដែលត្រឹមត្រូវ ដើម្បីបំពេញល្បះខាង ក្រោមៈ

១. អាដាំរស់បាន (១០០ឆ្នាំ ៥៣០ឆ្នាំ ៩៣០ឆ្នាំ) *កំណើតពិភពលោក ៥:៥* ។

២. ម៉ាធូសាឡឹមរស់បាន (៥៥៩ឆ្នាំ ៩៦៩ឆ្នាំ ៩៣០ឆ្នាំ) *កំណើតពិភពលោក ៥:២៧*។

៣. ឪពុករបស់ម៉ាធូសាឡឹមគឺ (ណូអេ ហេណុក ម៉ូសេ) *កំណើតពិភពលោក ៥:២១*។

៤. ហេណុកបានដើរតាមមាគ៌ាព្រះជាម្ចាស់ហើយថ្ងៃមួយ (គាត់បានស្លាប់ ហើយនិងបានទៅស្ថានសួគ៌ / គាត់បានទៅស្ថានសួគ៌ដោយគ្មានការស្លាប់) *ហេព្រឺ ១១:៥* ។

៥. ប៉ូលបានប្រាប់អស់អ្នកជឿ នៅឯទីក្រុងថែស្សាឡូនិកថា (គ្រប់គ្នានឹងស្លាប់ / ខ្លះនឹងមិនស្លាប់) *១ថែស្សាឡូនិក ៤:១៦-១៧* ។

៦. ប៉ូលបានហៅព្រឹត្តការណ៍នេះថា: (រឿងដ៏គួរអោយភ័យខ្លាច / សេចក្ដីសង្ឃឹមមួយ) *ទីតុស២:១៣*។

៧. យើងអាចដឹងយ៉ាងច្បាស់ថា យើងនឹងត្រូវបានព្រះអម្ចាស់ហៅទៅជាមួយនៅពេទ្រង់យាងមក (ប្រសិនជាយើងអធិដ្ឋានជារៀងរាល់ថ្ងៃ / បើសិនយើងខិតខំប្រព្រឹត្តអំពើល្អ / បើសិនយើងមានជំនឿលើព្រះគ្រីស្ទយេស៊ូដែលបានសុគតសំរាប់អំពើបាបយើងហើយបានរស់ឡើងវិញ) *១ថែស្សាឡូនិក ៤:១៤* ។

៨. យើងនឹងជួបព្រះគ្រីស្ទ (លើផែនដីលើភ្នំ / ក្នុងអាកាសវេហាស៍) *១ថែស្សឡូនិក ៤:១៧*។

៩. ធ្វើតារាងពីរខាងក្រោម ។ តារាងទីមួយគឺអ្វីដែលអ្នកចង់ធ្វើពេលដែលព្រះគ្រីស្ទយាងមក ហើយតារាងបន្ទាប់គឺអ្វីដែលអ្នកមិនចង់ធ្វើពេលដែលព្រះគ្រីស្ទយាងមកៈ

| ☞ ខ្ញុំចង់ | ☞ ខ្ញុំមិនចង់ |
|---|---|
| ក. ........................................................ | ក. ........................................................ |
| ខ......................................................... | ខ. ........................................................ |
| គ. ........................................................ | គ. ........................................................ |
| ឃ. ........................................................ | ឃ......................................................... |

១០. សរសេរខគម្ពីរចងចាំ ១ថែស្សាឡូនិក ៤:១៧:

........................................................................................................................................................

........................................................................................................................................................

........................................................ ។

| | |
|---|---|
| **មេរៀនទី៤:** | **ទឹកជំនន់ដ៏ធំនៅលើមាគ៌ានៃជីវិត** |
| | **កំណើតពិភពលោក ៦-៨** |
| **គំនិតសំខាន់ :** | **ដើម្បីបង្ហាញពីសុវត្ថិភាពរបស់អ្នកជឿក្នុងអង្គព្រះគ្រីស្ទ** |

តើអ្នកធ្លាប់មានបទពិសោធន៍ជួបនឹងទឹកជំនន់ឬទេ? នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ហើយទឹកទន្លេហូរឡើងជន់លិចដែលយើងហៅថាទឹកជំនន់។ ពេលដែលយើងឮពីទឹកជំនន់ យើងដឹងថាវាជាពេលវេលាមួយដ៏គួរឱ្យខ្លាចសំរាប់ប្រជាជនដែលត្រូវតែអត់ធ្មត់ទ្រាំទ្រនឹងវា ។

ក្នុងមេរៀនរបស់យើងអំពីលោក *ហេណុក* យើងបានរកឃើញមាគ៌ារបស់ព្រះជាម្ចាស់ គឺទៅឋានលើ។ ឥឡូវនេះយើងនឹងឃើញមាគ៌ារបស់ព្រះជាម្ចាស់គឺនៅក្នុងទឹកដ៏ធំមហិមា *ទំនុកតម្កើង ៧៧:១៩* ។ ផ្លូវរបស់ព្រះជាម្ចាស់ នឹងប្តូរនៅពេលដែលយើងទៅដល់ផ្លូវបត់មួយ ដូច្នេះយើងត្រូវតែថែរក្សាភាពស្និទ្ធស្នាលជាមួយទ្រង់ និងព្រះបន្ទូលរបស់ព្រះអង្គពេលយើងស្ថិតនៅលើមាគ៌ានៃជីវិត។

បទបន្ទរចំរៀងមួយពោលឡើងថា: "ខ្លះតាមរយៈទឹក ខ្លះតាមរយៈទឹកជំនន់ ខ្លះតាមរយៈភ្លើង ប៉ុន្តែទាំងអស់តាមរយៈឈាម ខ្លះតាមរយៈទុក្ខសោកធំ ប៉ុន្តែព្រះជាម្ចាស់ប្រទានចំរៀងមួយ បទនៅពេលរាត្រី និងគ្រប់ទាំងថ្ងៃដែលគេរស់នៅ" ។ ឥឡូវនេះយើងនឹងទៅកាន់ទឹកជំនន់ដ៏ធំអស្ចារ្យ ដែលជន់លិចលើមាគ៌ានៃជីវិត។

បន្ទាប់ពីលោក*ហេណុក* ត្រូវបានលើកឡើងទៅស្ថានសួគ៌មនុស្សទាំងអស់បានប្រព្រឹត្តអំពើបាបកាន់តែខ្លាំងទៅៗ។ សាតាំងជាប់រវល់ក្នុងការនាំមនុស្សអោយដើរក្នុងផ្លូវរបស់វា ហើយព្យាយាមរារាំងព្រះជាម្ចាស់ក្នុងការបញ្ជូនព្រះសង្គ្រោះដែលទ្រង់បានសន្យានៅក្នុង *កំណើតពិភពលោក៣:១៥។* អំពើល្អ និងអំពើអាក្រក់បានឡូកឡំគ្នា ប៉ុន្តែមានតែការអាក្រក់ប៉ុណ្ណោះដែល ចេះតែកើនឡើង។

ព្រះជាម្ចាស់មានព្រះបន្ទូលថា : "យើងនឹងលុបបំបាត់មនុស្សលោកដែលយើងបានបង្កើតមក" *កំណើតពិភពលោក ៦:៧*។

ព្រះគម្ពីរចែងមកថា ក្នុងចំណោមមនុស្សជាប់បាបទាំងអស់ គឺមានបុរសម្នាក់ដែលបានដើរតាមព្រះជាម្ចាស់។ ឈ្មោះរបស់គាត់គឺណូអេ។ គាត់មិនបានពាក់ព័ន្ធជាមួយមនុស្សបាបណាម្នាក់ ឡើយក៏ដូចជាកូនៗរបស់គាត់ដែរ។ គាត់បានដើរនៅលើមាគ៌ានៃសេចក្តីជំនឿនិងស្វែងរកព្រះគុណរបស់ព្រះជាម្ចាស់ *កំណើតពិភពលោក ៦:៨ ។*

*ណូអេ* គឺជាមនុស្សល្អ ហើយព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់គាត់ឱ្យសង់ទូកធំមួយ គឺជាទូកដែលអណ្តែតលើផ្ទៃទឹក។ *ណូអេ* បានស្តាប់បង្គាប់ព្រះជាម្ចាស់ ទោះបីជាគាត់មិនដែលបានឃើញមានភ្លៀងធ្លាក់ ឬក៏ទឹកជំនន់ពិមុនសោះក្តី។ ដោយយោងទៅតាម *កំណើតពិភពលោក ២:៦* គឺមានតែសន្សើមអ័ព្ទប៉ុណ្ណោះដែលធ្លាប់ធ្លាក់មកលើផែនដីរហូតដល់ខណៈពេលនោះ។ ឥឡូវលោកណូអេជាបុរសចំណាស់អាយុ៤៨០ឆ្នាំ ចាប់ផ្តើមសង់ទុកធំមួយដែលនៅឆ្ងាយពីសមុទ្រ។ គាត់បានប្រកាសពីភាពសុចរិតដល់មនុស្សអាក្រក់ទាំងអស់នៅពេលដែលគាត់កំពុងសាងសង់ទូក។ យើងមិនបាច់មានការ

សង្ស័យទេ សូម្បីតែជាងឈើដែលជួយលោកណូអេក៏និយាយចំអកចំពោះការចែកចាយរបស់គាត់អំពីការមកដល់នៃទឹកជំនន់នៅពេលដែលពួកគេមិនធ្លាប់ឃើញមានភ្លៀងសោះ!

នៅពេលដែលទូកធំបានធ្វើរួចរាល់ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅ *ណូអេ* ថា " មក! អ្នក និងក្រុមគ្រួសារអ្នកទាំងអស់ចូលក្នុងទូកធំទៅ " បន្ទាប់មកព្រះអង្គបិទពួកគេទៅខាងក្នុង *កំណើតពិភពលោក ៧:១៦* ។ ទ្វារតែមួយបានបិទណូអេ និងក្រុមគ្រួសាររបស់គាត់ទាំងអស់អោយមានសុវត្ថិភាពនៅក្នុងទូកធំ ។ ពេលនោះភ្លៀងបានបង្អុរចុះមកយ៉ាងខ្លាំង *កំណើតពិភពលោក ៧:១៧-២៤*។ ព្រះជាម្ចាស់មិនបានភ្លេចពីលោកណូអេឡើយ *កំណើតពិភពលោក ៨:១-១៤*។ អស់អ្នកនៅខាងក្រៅទូកធំត្រូវវិនាសអន្តរាយ ឯអ្នកដែលនៅក្នុងទូកធំវិញបានទទួលនូវសុវត្ថិភាព ។ ទូកធំអណ្តែតយ៉ាងមានសុវត្ថិភាពនៅលើផ្ទៃទឹកនោះ ។ ភ្លៀងនៅតែបន្តធ្លាក់មករហូតសែសិបយប់ សែសិបថ្ងៃតែទូកធំនៅតែមានសុវត្ថិភាពដដែល ។

មួយឆ្នាំមុនព្រះជាម្ចាស់បានមានព្រះបន្ទូលថា "*ចូលក្នុងមក*" តែឥលូវនេះ ទ្រង់មាន ព្រះបន្ទូលថា "*ចេញក្រៅមក*" តើលោក *ណូអេ* ធ្វើអ្វីបន្ទាប់ពីពេលដែលពួកគាត់ចេញមកខាងក្រៅ ទូកធំនៅលើដីស្ងួត? គាត់បានសង់អាសនៈ ហើយក៏ថ្វាយបង្គំព្រះជាម្ចាស់ ។ យើងឃើញថាគាត់មិនថ្វាយបង្គំទូកធំនោះទេ *កំណើតពិភពលោក ៨:២០* ។ នៅខណៈពេលនោះព្រះជាម្ចាស់បានបង្កើតឥន្ទធនូជាសញ្ញាសំគាល់នៃសម្ព័ន្ធមេត្រីថា ទ្រង់នឹងមិនបំផ្លាញផែនដីនេះម្តងទៀត ដោយសារទឹកជំនន់ឡើយ *កំណើតពិភពលោក ៩:៩-១៧* ។ យើងអាចឃើញមានទឹកជំនន់នៅក្នុងប្រទេសជាច្រើននៅ លើពិភពលោកសព្វថ្ងៃតែព្រះជាម្ចាស់នឹងមិនបំផ្លាញផែនដីទាំងមូល ដោយទឹកជំនន់ធំដូចដែលទ្រង់ បានធ្វើនៅសម័យលោកណូអេឡើយ ។

លោកណូអេ និងទូកធំបង្ហាញប្រាប់យើងពីអត្ថន័យរបស់ព្រះគម្ពីរនៃការសង្គ្រោះ និង ការបាត់បង់:

១- ប្រសិនបើលោកណូអេនៅខាងក្រៅទូកធំ លោកនឹងបាត់បង់ជីវិត តែនៅខាងក្នុងទូកធំគាត់នឹងបានទទួលការសង្គ្រោះ ។
២- ទូកធំបានបង្កើតឡើងដោយឈើស្រឡៅហើយហុំព័ទ្ធទៅដោយជ័រម្រ័ក្សណ៍ ដើម្បីផ្ជិតទូកនោះ ។ ជ័រនោះបានការពារកុំឱ្យទឹកជ្រាបចូល និងបានការពារលោកណូអេឱ្យមានសុវត្ថិភាព ។ វាជារូបភាពមួយដែលបង្ហាញពីព្រះយេស៊ូគ្រីស្ទ ។
៣- ដើមឈើជាច្រើនបានផ្តល់ជីវិតវាដើម្បីសង់ទូកធំ រីឯព្រះគ្រីស្ទបានប្រទានរូបកាយរបស់ទ្រង់ដោយសុគតនៅលើឈើឆ្កាងដើម្បីសង្គ្រោះយើងរាល់គ្នាពីការវិនិច្ឆ័យទោសនៃអំពើបាប ។
៤- ទូកធំមានទ្វារតែមួយប៉ុណ្ណោះ ដើម្បីគ្រប់គ្នាបានចូលតាមរយៈវានោះ ។ រូបកាយរបស់ព្រះគ្រីស្ទត្រូវបានចាក់ទំលុះ ដើម្បីគ្រប់គ្នាអាចទៅកាន់ជីវិតអស់កល្បក្នុងព្រះអង្គបាន ។
៥- ទូកត្រូវបានជ្រមុជក្នុងទឹកនៃការវិនិច្ឆ័យទោស ដូចព្រះគ្រីស្ទបានជ្រមុជជំនួសបាបយើងដោយការសុគតរបស់ទ្រង់ *១ពេត្រុស ៣:១៨-២១* ។

យើងបានរៀនពីទឹកជំនន់ធំដែលបានយកមនុស្សឃោរឃៅទាំងអស់ចេញដោយការវិនិច្ឆ័យទោស ។ ព្រះគម្ពីរបានចែងថានឹងមានការវិនិច្ឆ័យទោសផ្សេងទៀត ដែលនឹងមកដល់លើផែនដីនេះ ។ តើសព្វថ្ងៃនេះអ្នកទទួលការសង្គ្រោះក្នុង

អង្គព្រះគ្រីស្ទហើយឬនៅ? ព្រះយេស៊ូមានព្រះបន្ទូលថា: "មកឯខ្ញុំ ខ្ញុំនឹងការពារអ្នកឱ្យមានសុវត្ថិភាព ខ្ញុំស្រលាញ់អ្នក ហើយបានសុគតសំរាប់បាបរបស់អ្នក។ ខ្ញុំនឹងការពារអ្នកគ្រប់ទាំងផ្លូវទាំងអស់នៅលើមាគ៌ានៃជីវិត ហើយយកអ្នកឱ្យទៅរស់នៅជាមួយខ្ញុំជារៀងរហូតអស់កល្បក្នុងសិរីរុងរឿង"។

ព្រះយេស៊ូគ្រីស្ទជាទូកធំ ហើយទ្រង់ក៏ជាទ្វារតែមួយព្រះអង្គមានព្រះបន្ទូលថា: *"ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ" យ៉ូហាន ១០:៩*។ តើអ្នកនឹងចូលរឺ? តើអ្នកនឹងមកឯព្រះអង្គថ្ងៃនេះរឺ?

**ខគម្ពីរចងចាំ:** យ៉ូហាន ១០:៩ ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំព្រះជាម្ចាស់ នឹងសង្គ្រោះអ្នកនោះ អ្នកនោះនឹងចេញចូលព្រមទាំងរកឃើញចំណីអាហារថែមទៀតផង ។

## សំនួររំលឹក មេរៀនទី៤

ចូរបំពេញក្នុងចន្លោះនៅក្នុងប្រយោគខាងក្រោមនេះ:

១- ព្រះជាម្ចាស់បានទតឃើញថា............................របស់មនុស្សកាន់តែច្រើនឡើងៗ *កំណើតពិភពលោក៦:៥* ។

២- ព្រះជាម្ចាស់បានមានព្រះបន្ទូលថា "យើងនឹង........................................................ ....................អ្នកដែលយើងបានបង្កើតឡើងមក" *កំណើតពិភពលោក ៦:៧* ។

៣- ប៉ុន្តែលោក*ណូអេ* បានទៅជាមនុស្ស......................................................................................... ................នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ *កំណើតពិភពលោក ៦:៨*។

៤- លោក ណូអេជាមនុស្ស.......................................និង................................... នៅក្នុងជំនាន់ របស់លោក *កំណើតពិភពលោក ៦:៩*។

៥- ព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់លោកណូអេឱ្យសង់...................................................ពីឈើស្រឡៅ *កំណើតពិភពលោក៦:១៤*។

៦- ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅលោកណូអេឱ្យនាំសត្វដ៏វិសុទ្ធចំនួន...........................................ក្នុងចំណោមប្រភេទសត្វទាំងអស់ ហើយនាំសត្វដែលមិនដ៏វិសុទ្ធចំនួន ..................................................ក្នុងចំណោមប្រភេទសត្វទាំងអស់ដែលមានឈ្មោល និងញី *កំណើតពិភពលោក ៧:២-៣* ។

៧- ពេលលោកណូអេ និងក្រុមគ្រួសារគាត់មានសុវត្ថិភាពក្នុងទូកធំព្រះជាម្ចាស់បាន........................................ .................................................................. *កំណើតពិភពលោក ៧:១៦* ។

៨- បន្ទាប់ពីទឹកជំនន់លោកណូអេបានសង់.................................................និងបានថ្វាយ................................ ....... .......................................... ដល់ព្រះជាម្ចាស់ *កំណើតពិភពលោក៨:២០* ។

៩- ការវិនិច្ឆ័យទោសចំពោះអំពើបាបគឺនឹងមកដល់លើភពផែនដីយើងនៅថ្ងៃណាមួយ តែយើងមិនភ័យខ្លាចឡើយ បើជីវិតរបស់យើងបាន......................................... .................................................. *កូឡុស ៣:៣* ។

១០- ទូកធំមានទ្វារតែមួយដែលណូអេ និងគ្រួសាររបស់គាត់អាចចូលដោយសុវត្ថិភាព។ មានតែទ្វារមួយដែលយើងអាចចូលទៅចំពោះព្រះភ័ក្រព្រះជាម្ចាស់បាន។ ព្រះយេស៊ូនេះហើយគឺជាទ្វារនោះ។ ចូរគូសរូបទ្វារហើយសរសេរខព្រះគម្ពីរចងចាំ *យូហាន ១០:៩* ។

## មេរៀនទី៥: មាគ៌ាដែលត្រូវបែកនៅកាច់ជ្រុងនៃការគោរពទ្រនុំ

**កំណើតពិភពលោក ១១**

**គំនិតសំខាន់: ដើម្បីបង្ហាញពីកន្លែងសំរាប់ការសារភាពអំពើបាប និងការធ្វើឱ្យ ការប្រកបដូចដើមវិញ។**

តើអ្នកចូលចិត្តពេលយប់ ឬពេលថ្ងៃ? ហេតុអ្វីបានជាភាគច្រើនយើងចូលចិត្តពេលថ្ងៃជាង? យើងចង់ឃើញថា យើងទៅណាយើងកំពុងធ្វើអ្វី? តើអ្នកដទៃកំពុងធ្វើអ្វី? សំរាប់អ្នកដែលចូលចិត្តពេលយប់ តើអ្នកនៅតែចូលចិត្តពេលយប់ ទៀតទេ បើសិនគ្មានព្រះច័ន្ទ ឬក៏ផ្កាយនោះ? ទេ! វាមិនស្អាតឡើយសំរាប់ពេលយប់ដែលមិនមានពន្លឺនៅលើមេឃ ហើយក៏មិនស្អាតដែរសំរាប់ពេលថ្ងៃ ដែលគ្មានពន្លឺព្រះអាទិត្យ។

ព្រះគម្ពីរចែងថាព្រះជាម្ចាស់ជាពន្លឺ ហើយគ្មានភាពងងឹតនៅក្នុងអង្គទ្រង់ទាល់តែសោះ *១យ៉ូហាន១:៥*។ ពន្លឺតែង តែបង្ហាញដល់យើងពីព្រះជាម្ចាស់ និងភាពសុចរិត ឯភាពងងឹតវិញបង្ហាញយើងអំពីសាតាំង និងការអាក្រក់។ ព្រះជាម្ចាស់ មានព្រះហឫទ័យចង់ឱ្យបុត្រធីតារបស់ទ្រង់ដើរនៅក្នុងពន្លឺរបស់ព្រះអង្គ ។

ឥលូវយើងនឹងសិក្សាថា តើបុត្រធីតារបស់ព្រះជាម្ចាស់បានដើរនៅក្នុងពន្លឺ ឬភាពងងឹតបន្ទាប់ពីទឹកជំនន់ធំរួច។ ទឹកជំនន់បានបំផ្លាញមនុស្សដែលពោរពេញដោយអំពើបាបទាំងអស់ ដូច្នេះព្រះជាម្ចាស់បានប្រទានច្បាប់ធ្វើដំណើរថ្មីខ្លះៗ ដល់លោកណូអេ ដើម្បីចាប់ផ្តើមមាគ៌ានៃជីវិតម្តងទៀត *កំណើតពិភពលោក៩:១-១៩*។ ព្រះជាម្ចាស់មានព្រះបន្ទូលទៅ *ណូអេ* អោយបង្កើតកូនចៅពាសពេញផែនដីបង្កើតផលផ្លែ និងកើនចំនួនច្រើនឡើង *កំណើតពិភពលោក ៩:១,៧*។ គាត់ត្រូវបាន អនុញ្ញាតឱ្យហូបសាច់ជាអាហារប្រចាំថ្ងៃរបស់គាត់ ដែលខុសពីមុនដែលគេអាចហូបបានតែផ្លែឈើ និងបន្លែ ប៉ុណ្ណោះ *កំណើតពិភពលោក ៩:៣* ។ ការដាក់ទោសសំរាប់ការសំលាប់គ្នា គឺសេចក្តីស្លាប់ *កំណើតពិភព លោក ៩:៦* ។

បន្ទាប់មកព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយណូអេដែលទ្រង់នឹងមិនបញ្ជូនទឹកជំនន់ម្តងទៀត ដើម្បីបំផ្លាញជីវិត មនុស្សលោកទាំងអស់នៅលើផែនដីឡើយ ហើយទ្រង់ប្រទានឥន្ទធនូជាសញ្ញាសំគាល់នៃការសន្យា។

ណូអេ និងកូនរបស់គាត់ *សិម ហាំ* និង *យ៉ាផេត* ត្រូវបានអនុញ្ញាតឱ្យដើរនៅលើមាគ៌ានៃជីវិត។ មនុស្សបាន កើនឡើងយ៉ាងឆាប់រហ័ស គេទាំងអស់គ្នានិយាយភាសាតែមួយប៉ុណ្ណោះ *កំណើតពិភពលោក ១១:១* ។

ប្រហែល១000ឆ្នាំក្រោយមកក៏មានមនុស្សជាច្រើននៅលើផែនដី។ យើងបានរៀនរួចហើយពីអតីតកាល ពេល ដែលមានមនុស្សកាន់តែច្រើននោះជាធម្មតាមានមនុស្សកាន់តែប្រព្រឹត្តអំពើទុច្ចរិតច្រើនផងដែរ ដូច្នេះវាក៏កើតឡើងនៅ ពេលនោះ។ ពួកគេមិនគោរពច្បាប់ទំលាប់ដែលព្រះជាម្ចាស់ប្រទានអោយ។ ពួកគេបានធ្វើដំណើរពីតំបន់ភាគខាងកើត ទៅវាលរាបមួយនៅក្នុងទឹកដី *ស៊ីណើរ*។ ពួកគេនិយាយថា "ចូរយើងធ្វើឥដ្ឋ ហើយដុតវា ចូរយើងសង់ទីក្រុងមួយ និង ប៉មមួយ" *កំណើតពិភពលោក ១១:៤*។ យើងដឹងថានេះជា *ប៉ម* នៃការថ្វាយបង្គំរូបចំលាក់ពីព្រោះពួកគេបានដាក់ សញ្ញានៃរូបផ្កាយជាច្រើន (រាជសីហ៍) នៅលើកំពូលនៃប៉ម។ ពួកគេបានថ្វាយបង្គំវត្ថុដែលគេបានបង្កើតជំនួសអ្នកដែល បង្កើតពួកគេមក *រ៉ូម១:១៩-២៥*។

ពេលដែលព្រះជាម្ចាស់យាងចុះមកហើយទតឃើញប៉ម និងទីក្រុងនោះទ្រង់មិនសព្វព្រះហប្ញទ័យឡើយ *កំណើតពិភពលោក ១១:៥-៩*។ ព្រះអង្គបានពង្រាយមនុស្សនៅទូទាំងផែនដី ហើយបានបំបែកភាសារបស់ពួកគេ។ ទីកន្លែងនោះត្រូវបានគេហៅឈ្មោះថា *បាបិល* ដែលមានន័យថា *ការភាន់ច្រឡំ*។ នៅលើផែនទីចំណុចនៃផ្លូវបំបែកយើងហៅថាជ្រុងនៃការភាន់ច្រឡំ។

តើអ្វីទៅដែលព្រះជាម្ចាស់គួរធ្វើឥលូវនេះ? មនុស្សជាតិត្រូវបានផ្ដល់ឱកាសជាច្រើន តែពួកគេបង្កើតកំហុសតាមឱកាសនីមួយៗ ដូច្នោះព្រះជាម្ចាស់បានបណ្ដោយពួកគេឱ្យទៅក្នុងអំពើបាប និងអំពើទុច្ចរិតរបស់ពួកគេ *រ៉ូម ១: ២៤-២៨*។ មនុស្សទាំងនោះត្រូវបានគេហៅថាជាតិសាសន៍ ឬសាសន៍ដទៃ គ្រប់គ្នាបានដើរទៅក្នុង *មាគ៌ានៃសាសន៍ដទៃ* នៅលើផែនទី។ មនុស្សជាតិទាំងអស់បានជ្រើសរើសផ្លូវដែលគេគិតថាត្រឹមត្រូវនៅក្នុងភ្នែករបស់ពួកគេ ប៉ុន្តែជាផ្លូវដែលបាននាំទៅរកសេចក្ដីស្លាប់វិញ។

ហេតុអ្វីបានជាផ្លូវនេះជាផ្លូវនៃសេចក្ដីស្លាប់? ពីព្រោះមនុស្សមិនបានស្ដាប់បង្គាប់មាគ៌ានៃជំនឿរបស់ព្រះជាម្ចាស់។ នៅពេលដែលពួកគេនិយាយថា "ចូរយើងធ្វើឥដ្ឋហើយសង់ប៉ម" ពួកគេធ្វើកិច្ចការនេះសំរាប់តែភាពរុងរឿងរបស់ពួកគេផ្ទាល់ខ្លួនតែប៉ុណ្ណោះ មិនមែនសំរាប់សិរីរុងរឿងរបស់ព្រះជាម្ចាស់ទេ។ មនុស្សជាច្រើនសព្វថ្ងៃនេះបានសង់ប៉មរបស់គេជាមួយនឹងថ្មនៃការប្រព្រឹត្តអំពើល្អ និងការពឹងផ្អែកលើកិច្ចការទាំងនោះដើម្បីនាំពួកគេទៅឋានសួគ៌បាន។ ព្រះជាម្ចាស់ទ្រង់សព្វព្រះហប្ញទ័យ តែជាមួយការប្រព្រឹត្តនៃសេចក្ដីជំនឿ តែប៉ុណ្ណោះ។

ពេលដែលពួកគេនិយាយថា "ចូរយើងបង្កើតឈ្មោះរបស់យើង" ពួកគេបានបង្ហាញថាពួកគេមិនចង់ថ្វាយកិត្តិយសទៅព្រះនាមរបស់ព្រះជាម្ចាស់ឡើយ។ ពេលដែលមនុស្សនាំគ្នាថ្វាយបង្គំខ្លួនគេផ្ទាល់ វាបាននាំមកនូវភាពច្របូកច្របល់ និងបំផ្លាញភាពរួបរួមរបស់ព្រះវិញ្ញាណ។ ពេលពួកគេនិយាយថា "............ក្រែងលោយើងបែកខ្ញែកគ្នា" ពួកគេបានបះបោរប្រឆាំងនឹងបទបញ្ជារបស់ព្រះជាម្ចាស់។ ការមិនស្ដាប់បង្គាប់នាំមកនូវការភាន់ច្រឡំ និងការដាក់ទោសដល់មនុស្សជាតិ។

នៅក្នុងការធ្វើដំណើរបន្ទាប់ទៀត យើងនឹងងាកទៅខាងឆ្វេងនៃ *ជ្រុងនៃការភាន់ច្រឡំ* ហើយយើងនឹងឃើញថាព្រះជាម្ចាស់បានត្រាស់ហៅមនុស្សម្នាក់ ដើម្បីធ្វើការចាប់ផ្ដើមជាថ្មីនៅលើ *ផ្លូវនៃការសន្យា*។

<u>តើអ្នកធ្លាប់ដើរនៅក្នុងពន្លឺឬទេ?</u> បើសិនជាអ្នកមិនដែលទទួលព្រះយេស៊ូគ្រីស្ដជាព្រះសង្គ្រោះ នោះសូមទទួលព្រះអង្គថ្ងៃនេះ។ ព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់បានសំអាតយើងចេញពីអំពើបាបទាំងអស់។ បើសិនអ្នកជាអ្នកជឿរួចហើយ ប៉ុន្តែអ្នកបានធ្លាក់ចុះក្នុងការប្រព្រឹត្តអំពើបាប ចូរទូលទៅព្រះជាម្ចាស់ដោយការអធិដ្ឋាននោះទ្រង់នឹងអត់ទោសដល់អ្នក និងធ្វើឱ្យអ្នកបានប្រកបដោយភាពស្និទ្ធស្នាលជាមួយព្រះជាម្ចាស់វិញ។

**ខព្រះគម្ពីរចងចាំ:** ១យ៉ូហាន ១:៧ "ប៉ុន្តែប្រសិនបើយើងរស់ក្នុងពន្លឺដូចព្រះអង្គផ្ទាល់ ដែលគង់នៅក្នុងពន្លឺនោះយើងនឹងបានរួមរស់ជាមួយគ្នាទៅវិញទៅមក ហើយព្រះលោហិតរបស់ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះអង្គជំរះយើងអោយបានដ៏វិសុទ្ធរួចពីគ្រប់អំពើបាបទាំងអស់" ។

# សំនួររត្រិះរិះ មេរៀនទី៥

១. ចូរសរសេរច្បាប់ថ្មីដែលព្រះជាម្ចាស់ប្រទានទៅណូអេអោយបានចំនួនបី *កំណើតពិភពលោក ៩:១-៧*

ក.............................................................................................។

ខ ............................................................................................។

គ ............................................................................................។

២. យ៉ាងរហ័សផែនដីបានពេញដោយមនុស្សម្តងទៀត។ តើមានភាសាប៉ុន្មាន ដែលពួកគេបាននិយាយ? *កំណើតពិភពលោក ១១:១*.........................................................................................................។

៣. តើមនុស្សបានធ្វើអ្វីពេលដែលពួកគេបានមកដល់វាលរាបនៅក្នុងទឹកដីស៊ីណើរ? *កំណើតពិភពលោក១១:២-៤*

.......................................................................................................................................។

៤. តើព្រះជាម្ចាស់បានធ្វើអ្វីពេលដែលទ្រង់យាងមកឃើញទីក្រុង និងប៉ម?

*កំណើតពិភពលោក ១១:៥-៨* ..........................................................................................

.......................................................................................................................... *។*

៥. ហេតុអ្វីបានជាព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យពេលដែលមនុស្សនិយាយថា "ចូរយើង សង់ទីក្រុង និងប៉ម"? *កំណើតពិភពលោក ១១:៤*

.........................................................................................................................

........................................................................................................................ *។*

៦. ពួកគេក៏និយាយផងដែរថា "ចូរយើងសង់.........................................................................."

*កំណើតពិភពលោក ១១:៤* ។

៧. ប៉មនោះមានឈ្មោះថា.........................................................................ដែលមានន័យថាការភាន់ច្រឡំ

*កំណើតពិភពលោក១១:៩* ។

៨. មនុស្សមិនបានដើរនៅក្នុងពន្លឺរបស់ព្រះជាម្ចាស់ ដូចនេះហើយបានជាគេមិនមាន.............................

...........................................................ជាមួយព្រះជាម្ចាស់ ឬអ្នក ផ្សេងទៀត *១យ៉ូហាន១:៧* ។

៩. អាននៅខគម្ពីរ *រ៉ូម ១:២៤* ហើយសរសេរអ្វីដែលព្រះជាម្ចាស់បានធ្វើដល់សាសន៍ដទៃ បន្ទាប់ពីការបះបោរដ៏ធំនេះ.........................................................................................................................

...............................................................។

១០. សរសេរខគម្ពីរចងចាំ *១យ៉ូហាន ១:៧*

.......................................................................................................................

.......................................................................................................................

......................................... *។*

## មេរៀនទី៦: ការធ្វើដំណើរលើផ្លូវនៃការសន្យា

**កំណើតពិភពលោក ១២ — ២២**

**គំនិតសំខាន់: ដើម្បីបង្ហាញនូវភាពស្មោះត្រង់របស់ព្រះជាម្ចាស់ និង រង្វាន់នៃការជឿលើព្រះបន្ទូលសន្យារបស់ព្រះអង្គ។**

តើអ្នកនឹងឆ្លើយសំនួរនេះយ៉ាងណា: "តើអ្នកតែងតែរក្សានូវពាក្យសន្យារបស់អ្នកដែរ ឬទេ?" ប្រហែលជាអ្នកមិនអាចធ្វើបាននោះទេ ប៉ុន្តែព្រះជាម្ចាស់តែងតែរក្សានូវការសន្យារបស់ទ្រង់ជានិច្ច។ តាមការពិតមានកិច្ចការមួយដែលព្រះអង្គធ្វើមិនបានគឺព្រះអង្គមិនអាចកុហកឡើយ។ ជាច្រើនរយឆ្នាំបានកន្លងផុតទៅ ព្រះបន្ទូលសន្យារបស់ព្រះអង្គត្រូវបានបំពេញប្រសិនបើអ្វីដែលទ្រង់បានសន្យាហើយនោះវានឹងត្រូវបានបំពេញ *ហេព្រើ ៦:១៣-១៨* ។

តើអ្នកចងចាំនូវការចាប់ផ្តើមនូវ *មាគ៌ានៃជីវិត* ដែលព្រះជាម្ចាស់បានសន្យាទៅលោក អាដាំ និង នាងអេវ៉ានៅក្នុង *កំណើតពិភពលោក ៣:១៥* ទេ ? ព្រះអង្គនឹងចាត់អ្នកសង្គ្រោះ ម្នាក់នៅថ្ងៃណាមួយដើម្បីយកជ័យជំនះទៅលើអារក្សសាតាំង។ ប៉ុន្តែឥលូវនេះមនុស្សជាតិបានធ្លាក់ទៅក្នុងអំពើបាប ហើយគ្មានមនុស្សណាម្នាក់បានជឿលើព្រះជាម្ចាស់ដែលទ្រង់អាចធ្វើការតាមរយៈគេបានឡើយ។ បើមើលទៅវាហាក់ដូចជាសាតាំងបានទទួលជ័យជំនះ ប៉ុន្តែតើវាអាចឈ្នះទេ? ដោយការត្រលប់ទៅខាងឆ្វេងទៅ ឯជ្រុងនៃការភាន់ច្រឡំទៅលើផែនទីនោះយើងអាចឃើញអ្វីដែលបានកើតឡើង។

ព្រះជាម្ចាស់បានទតមើលទៅលើជាតិសាសន៍ទាំងអស់ ហើយទ្រង់បានជ្រើសរើសបុរសម្នាក់គឺលោកអាប់រ៉ាមជាអ្នកដែលនឹងបំពេញនូវគោលបំណងរបស់ព្រះអង្គ:

ក) អាប់រ៉ាម គឺជាសាសន៍ដទៃដែលមិនជឿលើព្រះជាម្ចាស់ពេលដែលព្រះជាម្ចាស់បាន មានព្រះបន្ទូលទៅគាត់នៅក្នុងទីក្រុងអ៊ើរនៃស្រុកខាល់ដេ។

ខ) អាប់រ៉ាមបានជឿលើព្រះជាម្ចាស់ហើយព្រះអង្គបានប្រោសលោក អោយបានសុចរិត. *រ៉ូម ៤:៣* ។

គ) ព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យាថានឹងប្រទានកូនប្រុសមួយដល់លោកអាប់រ៉ាម *កំណើតពិភពលោក ១៥:២-៦* ។

ក្នុងការស្តាប់បង្គាប់ទៅលើការត្រាស់ហៅរបស់ព្រះជាម្ចាស់ អាប់រ៉ាមបានធ្វើដំណើរទៅកាន់ទឹកដីកាណាន *កំណើតពិភពលោក ១២:៥* ។ ជាច្រើនឆ្នាំបានកន្លងផុតទៅឈ្មោះរបស់លោកអាប់រ៉ាម បានប្តូរទៅជាលោក *អាប្រាហាំ* វិញ *កំណើតពិភពលោក ១៧:៤-៥* ។ លោកអាប្រាហាំ និងនាងសារ៉ាកាន់តែមានវ័យចំណាស់ទៅហើយទីបញ្ចប់ពួកគាត់កាន់តែមានវ័យចាស់ជាលក្ខណៈ ធម្មជាតិដែលពួកគាត់មិនអាចមានកូនបាន។ ប៉ុន្តែព្រះជាម្ចាស់មិនបានបំភ្លេចព្រះបន្ទូលសន្យារបស់ព្រះអង្គចំពោះលោកអាប្រាហាំឡើយ។ បន្ទាប់ពីរយៈពេល២៥ឆ្នាំនៃការរង់ចាំក្រោយមកកូននៃក្តីសន្យាគឺ *អ៊ីសាក* ក៏បានចាប់កំណើតឡើង។ ព្រះអង្គបានរង់ចាំដើម្បីបំពេញព្រះបន្ទូលសន្យារបស់ទ្រង់ ដូច្នេះកូននេះជាកូននៃអព្ភូតហេតុដ៏អស្ចារ្យ។ ព្រះអង្គក៏បានល្បងលជំនឿរបស់អាប្រាហាំផងដែរ។ *អាប្រាហាំ* បានឆ្លងផុតពីការល្បងលរបស់ព្រះជាម្ចាស់ យើងអានក្នុងព្រះគម្ពីរ *រ៉ូម៤:២០* ដែលលោកអាប្រាហាំមិនផ្លាស់ប្តូរពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ឡើយ។

អ៊ីសាកបានធំឡើងក្លាយជាយុវជនល្អម្នាក់។ បន្ទាប់មកមានថ្ងៃមួយដែលព្រះជាម្ចាស់បានប្រទាននូវការល្បងលដ៏ធំបំផុតដល់អាប្រាហាំ។ ព្រះជាម្ចាស់ចង់ឃើញថា តើអាប្រាហាំបានស្រលាញ់ព្រះអង្គខ្លាំងជាងអ៊ីសាកជាកូនរបស់គាត់ឬ? *កំណើតពិភពលោក២២:១២* ។

ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅអាប្រាហាំថា "ចូរយកអ៊ីសាក..." *កំណើតពិភពលោក២២:២* ។ នេះជាការល្បងមួយដ៏ពិបាកតែព្រះគម្ពីរបានប្រាប់យើងថាអាប្រាហាំបានចងចាំព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែលទ្រង់នឹងប្រទានពរដល់ផែនដីនេះតាមរយៈពូជពង្សរបស់គាត់។

លោកអាប្រាហាំបានដឹងថាព្រះជាម្ចាស់អាចលើកយកអ៊ីសាកចេញពីសេចក្ដីស្លាប់ ទោះបីជាជីវិតរបស់គាត់ត្រូវបានស្លាប់ក្ដី *ហេព្រើ១១:១៧-១៩*។ អាប្រាហាំបានលើកដៃរបស់គាត់យឺតៗជាមួយកាំបិតដើម្បីសំលាប់កូនប្រុសគាត់។ នៅខណៈភ្លាមៗនោះទេវតារបស់ព្រះជាម្ចាស់បានហៅលោកពីលើមេឃមកថា "កុំប្រហាជីវិតកូនអ្នកឡើយដ្បិតឥលូវនេះយើងដឹងថាអ្នកពិតជាកោតខ្លាចព្រះជាម្ចាស់មែន" *កំណើតពិភពលោក ២២:១០-១២*។

លោកអាប្រាហាំបានមើលនៅខាងក្រោយគាត់ បានឃើញពពែឈ្មោលមួយដែលជាប់នៅក្នុងគុម្ពោតព្រៃគាត់ក៏បានយកវាធ្វើជាយញ្ញបូជាជាដង្វាយដុតជំនួសកូនប្រុសរបស់គាត់*កំណើតពិភពលោក២២:១៣*។ លោកអាប្រាហាំបានហៅកន្លែងនោះថា "យេហូវ៉ា យីរ៉េ" ដែលមានន័យថាព្រះជាម្ចាស់នឹងផ្គត់ផ្គង់។

តើនេះមើលទៅដូចជាការល្បងលយ៉ាងលំបាកមួយដែលព្រះជាម្ចាស់ផ្ដល់ឱ្យអាប្រាហាំ ឬ? មែនហើយ! តែតាមរយៈការល្បងលនេះព្រះជាម្ចាស់បានបង្ហាញយើងនូវជំនឿដ៏ល្អប្រសើរពីរគឺ:

ក) ទ្រង់ផ្ដល់ឱ្យយើងនូវរូបភាពនៃក្ដីស្រលាញ់ដ៏អស្ចារ្យរបស់ទ្រង់ផ្ទាល់សំរាប់យើង ដោយប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គគឺព្រះយេស៊ូគ្រីស្ទទៅសុគតលើឈើឆ្កាង ដើម្បីលោះបាបយើងរាល់គ្នា។ ក្នុងរឿងរបស់អ៊ីសាកជារូបភាពមួយនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ។ អ៊ីសាកបានស្ដាប់បង្គាប់ដល់ឪពុករបស់គាត់គឺលោកអាប្រាហាំដែលបាននាំគាត់ឡើងលើភ្នំហើយឱ្យដេកនៅលើទីសក្ការៈបូជា។ យ៉ាងណាក៏ដោយព្រះគ្រីស្ទបានទៅគ្រប់ផ្លូវតាមរយៈការសុគត ដើម្បីសងថ្លៃទោសបាបរបស់យើងព្រះអង្គបានក្លាយជាចៀមដង្វាយនៃការសងថ្លៃបាបទៅព្រះជាម្ចាស់។

ខ) ព្រះជាម្ចាស់បានបង្ហាញដល់យើងនូវភាពស្មោះត្រង់ដ៏អស្ចារ្យរបស់ទ្រង់ក្នុងការរក្សានូវព្រះបន្ទូលសន្យារបស់ទ្រង់។ សេចក្ដីល្បងលរបស់អាប្រាហាំបានផ្ដល់ជាមេរៀនសំរាប់យើង *រ៉ូម ៤:១៣-២៥*។ យើងជឿទុកចិត្តលើព្រះអង្គនិងទទួលភាពសុចរិត *រ៉ូម៤:៥* ។ ជាដំបូងយើងត្រូវតែជឿថាព្រះគ្រីស្ទបានសុគតសំរាប់អំពើបាបរបស់យើងរាល់គ្នា ហើយទ្រង់បានរស់ពីសុគតឡើងវិញ។ បន្ទាប់មកសកម្មភាពរបស់យើងជាភស្ដុតាងបង្ហាញពីសេចក្ដីជំនឿពិតរបស់យើង។

លោកអាប្រាហាំបាទទួលរង្វាន់ដ៏ធំ និងទទួលព្រះបន្ទូលសន្យាបន្ថែមទៀត បន្ទាប់ពីគាត់បានឆ្លងផុតពីការល្បងលនេះ *កំណើតពិភពលោក ២២: ១៥-១៨*។ ដូចជាយើងនឹងទទួលព្រះបន្ទូលសន្យានៃគ្រប់អ្វីៗទាំងអស់ក្នុងព្រះគ្រីស្ទនៅពេលដែលយើងទទួល និងជឿទុកចិត្តលើព្រះអម្ចាស់នោះព្រះអង្គនឹងផ្គត់ផ្គង់ *រ៉ូម ៨:២៨-៣៩*។

នៅក្នុងមេរៀនបន្ទាប់យើងនឹងរៀនពីការរៀបអាពាហ៍ពិពាហ៍មួយនៅលើផ្លូវសន្យា។ សព្វថ្ងៃនេះយើងអាចទូលសូមព្រះជាម្ចាស់ជួយឱ្យយើងរឹងមាំនៅក្នុងជំនឿដើម្បីទទួលបាននូវគ្រប់អស់ទាំងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។

**ខគម្ពីរចងចាំ:** រ៉ូម ៤:២០-២១ លោកមិនបាត់ជំនឿ ហើយមិនសង្ស័យនឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទេ ផ្ទុយទៅវិញជំនឿរបស់លោកធ្វើឱ្យលោកមានកម្លាំងចិត្តនឹងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះលោកជឿប្រាកដក្នុងចិត្តថា បើព្រះជាម្ចាស់សន្យាធ្វើអ្វីព្រះអង្គពិតជាមានឫទ្ធានុភាពនឹងសំរេចតាមបានមិនខាន។

## សំនួររំលឹកៈ មេរៀនទី៦

១. ចូរបំពេញឈ្មោះនៃទីកន្លែងទាំងនេះដែលនៅក្នុងផែនទីៈ

ក. ផ្លូវនៃការ.......................................................

ខ. ផ្លូវនៃ.............................................................

គ. ជ្រុងនៃការ.......................................................

ឃ. សួនច្បារ........................................................

ង. ខ្សែបន្ទាត់នៃ....................................................

២. បន្ទាប់ពីប៉មបាបិលព្រះជាម្ចាសត្រាស់ហៅ........................................................... ដើម្បីចាប់ផ្ដើមផែនការថ្មី *កំណើតពិភពលោក ១២:១*។

៣. ព្រះជាម្ចាស់បានសន្យាកិច្ចការ៧យ៉ាងទៅអាប្រាហាំ។ អាន *កំណើតពិភពលោក១២:១-៣* ចូរសរសេរមានអ្វីខ្លះ?

ក. យើងនឹងធ្វើឱ្យអ្នកក្លាយទៅជា...............................................................................។

ខ. យើងនឹង...........................................................................................ដល់អ្នក។

គ. យើងនឹងឱ្យអ្នកមាន..........................................................................ល្បីល្បាញ។

ឃ. អ្នកនឹងក្លាយជាអ្នកដែល.....................................................................................។

ង. យើងនឹងឱ្យពរដល់ជនទាំងឡាយណាដែល......................................................ដល់អ្នក។

ច. យើងនឹងដាក់បណ្ដាសារដល់ជនទាំងឡាយណាដែល............................................ ដល់អ្នក។

ឆ. ដោយសារអ្នកធ្វើឱ្យ...............................................នៅលើ..................................... នឹងបានទទួលពរ។

៤. អាប្រាហាំបានជឿលើព្រះជាម្ចាស់ហើយទ្រង់បានប្រោសលោក............................................................ ...................................................... *កំណើតពិភពលោក១៥:៦*។

៥. ព្រះជាម្ចាស់មានព្រះបន្ទូលឱ្យលោកអាប្រាំហាំថ្វាយ........................................................... .............. ធ្វើជា........................................................................................... .*កំណើតពិភពលោក១៥:៦*។

៦. អាប្រាហាំបានជឿថាព្រះជាម្ចាស់អាចមានលទ្ធភាព.......................................................... ............ អ៊ីសាកឱ្យរស់ពីស្លាប់វិញបាន *ហេប្រឺ ១១:១៩*។

៧. អ៊ីសាកជារូបភាពមួយនៃ....................................................................... របស់យើង *យ៉ូហាន ៣:១៦*។

៨.	លោកអាប្រាប់ហាំជារូបភាពមួយនៃ.......................................................................................

..............................................................................................នៃយើង *យ៉ូហាន ៣:១៦* ។

៩. ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលសន្យាដ៏មានតំលៃជាច្រើនដល់យើង។ ពីរចំណុចក្នុង ចំណោមនោះគឺៈ

ក. *កិច្ចការ ១៦:៣១-* មានជំនឿលើព្រះអម្ចាស់យេស៊ូគ្រីស្ទអ្នក នឹងបានទទួល.......................................

..................................................................................................................................................។

ខ. *ភីលីព ៤:១៩* ព្រះរបស់ខ្ញុំនឹងបំពេញ...........................................................................................

..................................................................................................................................................។

១០	សរសេរខគម្ពីរចងចាំ *រ៉ូម៤:២០-២១*............................................................................................

......................................................................................................................................................

......................................................................................................................................................។

## មេរៀនទី៧ : អាពាហ៍ពិពាហ៍នៅលើផ្លូវសន្យា

**កំណើតពិភពលោក ២៤**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញពីភាពជិតស្និទ្ធិរបស់គ្រីស្ទបរិស័ទជាមួយព្រះគ្រីស្ទបច្ចុប្បន្ននិងរៀងរហូតទៅ**

យើងគ្រប់ៗគ្នាសុទ្ធតែចូលចិត្តទៅចូលរួមពិធីមង្គលការ។ នៅក្នុងពិធីមង្គលការយើងចូលរួមរីករាយជាមួយមនុស្សពីរនាក់ ដែលពួកគេមានការសប្បាយរីករាយនៅពេលដែលពួកគេបានរួបរួមដួងចិត្ត និងជីវិតរបស់ពួកគេតែមួយនៅក្នុងសេចក្តីស្រលាញ់។ តើអ្នកជឿថាព្រះជាម្ចាស់ដឹកនាំមនុស្សក្នុងការជ្រើសរើសដៃគូរជីវិតដែរឺទេ? ព្រះអង្គដឹកនាំកិច្ចការទាំងនោះចំពោះអ្នកដែលទុកចិត្តលើការសន្យារបស់ទ្រង់។ នៅក្នុងព្រះគម្ពីរបានប្រាប់យើងថា "*ចូរផ្ញើរវាសនារបស់អ្នកនៅក្នុងព្រះហស្តរបស់ព្រះអង្គ ចូរផ្ញើរជីវិតលើព្រះអង្គនោះទ្រង់នឹងជួយអ្នក*" ទំនុកតម្កើង ៣៧:៥។

សព្វថ្ងៃយើងដូចជាកំពុងធ្វើដំណើរនៅលើផ្លូវនៃការសន្យា យើងនឹងឃើញអំពីរបៀបដែលព្រះជាម្ចាស់ស្វែងរកប្រពន្ធអោយអ៊ីសាក។ បន្ទាប់មកយើងនឹងទៅចូលរួមមង្គលការមួយដែល ទោះបីជាអាចនឹងមានការខុសគ្នាខ្លះ ពីររបៀបនៃការរៀបការសព្វថ្ងៃក៏ដោយ។ អស់រយៈពេលច្រើនឆ្នាំកន្លងផុតទៅអ្នកស្រីសារ៉ាបានស្លាប់ ហើយលោកអាប្រាហាំក៏មានវ័យកាន់តែចាស់ជរា។ គាត់ក៏បានសំរេចចិត្តរៀបចំអោយអ៊ីសាករៀបការ។

អាប្រាហាំបានហៅអ្នកបំរើដែលគាត់ទុកចិត្តម្នាក់មក ហើយអោយគាត់បានសន្យាថា គាត់នឹងមិនស្វែងរកប្រពន្ធអោយអ៊ីសាកពីក្នុងចំណោមស្ត្រី *ជនជាតិកាណាន* ឡើយ ប៉ុន្តែគាត់នឹងទៅរកពីពូជពង្សរបស់លោកអាប្រាហាំវិញ។ ព្រះជាម្ចាស់ប្រាប់យើងជាអ្នកដែលរស់នៅក្នុងសម័យនៃព្រះគុណ ដែលជាអ្នកជឿលើព្រះអម្ចាស់មិនគួររៀបការជាមួយអ្នកមិនជឿលើព្រះអង្គឡើយ *២កូរិនថូស ៦:១៤-១៨*។

អ្នកបំរើនោះបានចេញដំណើរជាមួយសត្វអូដ្ឋ១០ក្បាលសំរាប់ដឹកជំនូន និងការអំណោយសំរាប់ស្ត្រីដែលនឹងក្លាយជាប្រពន្ធរបស់អ៊ីសាក។ ពេលដែលគាត់បានមកដល់ទីក្រុង*ណាឃ័រ* ក្នុងស្រុក*មេសូប៉ូតាមា* ជាកន្លែងសាច់ញាតិរបស់លោកអាប្រាហាំ គាត់បានឈប់នៅក្បែរអណ្តូងដើម្បីទៅដងទឹកអោយអូដ្ឋផឹក។ វាជាពេលដែលស្ត្រីៗចេញមកដងទឹក។ អ្នកបំរើបានអធិដ្ឋានសុំការដឹកនាំពី ព្រះអង្គអោយទ្រង់បង្ហាញនូវស្ត្រីម្នាក់ដែលត្រឹមត្រូវសំរាប់ធ្វើជាប្រពន្ធរបស់អ៊ីសាក។ គាត់ទូលសុំថាម្នាក់នោះជាស្ត្រីម្នាក់ដែលនឹងដងទឹកអោយគាត់ពិសារបន្ទាប់មកគាត់រង់ចាំចំលើយពីព្រះអម្ចាស់។

ភ្លាមៗនោះ*រេបិកា* បានដើរមកហើយគាត់បានសុំទឹករេបិកាបរិភោគ។ ស្រាប់តែនាងបានអោយទឹកគាត់បរិភោគហើយនាងបានដងទឹកអោយសត្វអូដ្ឋទាំងអស់ផឹកទៀតផង នាងបានបំពេញនូវការតម្រូវទាំងអស់អ្នកបំរើអោនក្បាលចុះថ្វាយបង្គំព្រះជាម្ចាស់គាត់បានជូនអំណោយទៅគ្រួសាររបស់រេបិកា ដើម្បីបង្ហាញដល់ពួកគេពីទ្រព្យសម្បត្តិ និងមុខតំណែងរបស់អ៊ីសាក។ រេបិកាទទួលយកអំណោយ និងទុកចិត្តលើអ្នកបំរើនោះ។ បន្ទាប់មកគាត់សួររេបិកាថា "*តើនាងនឹងទៅនៅជាមួយអ៊ីសាករឺទេ?*" នាងឆ្លើយថា "*ចា៎! ខ្ញុំទៅ*"។ នាងបានបោះជំហានចូលទៅរកការសន្យា។ នាងមិនភ័យខ្លាចនឹង

ចេញទៅនៅលើទឹកដីធំលែក និងជាមួយមនុស្សដែលនាងមិនស្គាល់ពីមុននោះទេពីព្រោះនាងជឿជាក់លើព្រះជាម្ចាស់ដែលនឹងដឹកនាំអ្នកបំរើនោះក៏នឹងថែរក្សានាងដែរ ។

ការធ្វើដំណើររបស់ពួកគេបានឆ្លងកាត់វាលខ្សាច់ហើយស្ថិតក្រោមកំដៅថ្ងៃយ៉ាងក្តៅ ប៉ុន្តែរេបិកាមិនមានការព្រួយបារម្ភណ៍អំពីគ្រោះថ្នាក់ឡើយ ពីព្រោះនាងប្រមើលមើលដោយជឿជាក់ថានាងនឹងបានជួបជាមួយមនុស្សម្នាក់ ដែលនាងមិនធ្លាប់ជួបដែលនាងនឹងក្លាយជាប្រពន្ធរបស់គេ ។

បន្ទាប់ពីល្ងាចមួយដែលអ៊ីសាកបានចេញក្រៅទៅវាលហើយអធិដ្ឋាន ។ គាត់បានបើកភ្នែកហើយឃើញសត្វអូដ្ឋកំពុងដើរមក ។ អ្នកបំរើបានប្រាប់អ៊ីសាកគ្រប់ទាំងកិច្ចការអោយដឹង ហើយគាត់ដឹងថាព្រះជាម្ចាស់បានរៀបចំរេបិកាអោយក្លាយជាប្រពន្ធរបស់គាត់ ។ អ៊ីសាកស្រលាញ់នាងខ្លាំងណាស់ ព្រោះនាងជាអ្នកដែលព្រះជាម្ចាស់រៀបចំសំរាប់គាត់ ។

ពេលខ្លះយើងដូចជារេបិកាដែរ យើងកំពុងធ្វើដំណើរក្នុងដំណើរជីវិតឆ្ពោះទៅជួបជាមួយម្នាក់ដែលស្រលាញ់យើងនៅស្ថានសួគ៌ ។ យើងកំពុងធ្វើដំណើរឆ្ពោះទៅមុខក្នុងការរង់ចាំម្នាក់ដែលយើងស្រលាញ់ឯលំហរអាកាស ។ *ខ្សែបន្ទាត់នៃការសង្រ្គោះ* ជាការតំណាងអោយអស់អ្នកដែលត្រូវបានទទួលដោយព្រះគ្រីស្ទជាព្រះសង្រ្គោះនិងកំពុងរង់ចាំការត្រាស់ហៅរបស់ទ្រង់ពីស្ថានសួគ៌ ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រាប់យើងអំពីព្រះជាម្ចាស់ដែលយើងរង់ចាំ ។ យើងមិនដែលឃើញទ្រង់តែយើងស្រលាញ់ទ្រង់យើងចូលចិត្តនិយាយជាមួយទ្រង់ ហើយចូលចិត្តអានសំបុត្ររបស់ទ្រង់គឺព្រះគម្ពីរ ។ ទ្រង់ប្រាប់យើងអំពីព្រះពរខាងព្រលឹងវិញ្ញាណរបស់យើង និងតំណែងរបស់យើងនៅជាមួយទ្រង់នៅស្ថានសួគ៌ ។ យើងនឹងនៅរួមគ្នាជាមួយព្រះជាម្ចាស់រៀងរហូត *អេភេសូ ១:-២:* ។

នៅក្នុងពេលនេះយើងអាចនិយាយជាមួយទ្រង់ដោយការអធិស្ឋាន ហើយទ្រង់នឹងឆ្លើយតបដឹកនាំជីវិតយើងទាំងមូល ។ គ្មានអ្វីដែលធំពេក រឺ តូចពេកនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់យេស៊ូនៃយើងឡើយ ។

នេះគឺជាការរៀបអាពាហ៍ពិពាហ៍ដែលមិនធម្មតា! មនុស្សភាគច្រើនចង់អោយមានការប្រារព្ធកម្មវិធីដ៏ធំ ប៉ុន្តែយើងដឹងថាកូនសោរឆ្ពោះទៅរកមង្គលការដែលសប្បាយរីករាយនោះគឺសេចក្តីស្រលាញ់ ។ យើងអាចទទួលព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ទជាព្រះសង្រ្គោះ ដោយការសុំព្រះអង្គអោយមកគង់ក្នុងជីវិតយើងយ៉ាងស្ងៀមស្ងាត់ជាពេលដែលយើងប្រកបជាមួយទ្រង់ រឺក៏នៅក្នុងយុទ្ធនាការនៃការផ្សាយដំណឹងល្អមួយក៏ដោយ ។ ប្រសិនបើយើងស្រលាញ់ព្រះអង្គដោយព្រោះទ្រង់សុគតសំរាប់អំពើបាបរបស់យើងទូលព្រះអង្គនូវកិច្ចការនោះ ហើយយើងទទួលព្រះអង្គជាព្រះអង្គសង្រ្គោះរបស់យើង ។ យើងបានក្លាយជាមនុស្សម្នាក់រួមនៅក្នុងអង្គទ្រង់ជាមិនខាន ។ តើថ្ងៃនេះអ្នកនឹងទទួលទ្រង់ដោយផ្ទាល់ខ្លួនអ្នករឺទេ?

**ខគម្ពីរចងចាំ:** *ទំនុកតំកើង ៣៧:៥*

"ចូរផ្ញើរវាសនារបស់អ្នកនៅក្នុងព្រះអង្គ ចូរផ្ញើរជីវិតលើព្រះអង្គនោះទ្រង់នឹងជួយអ្នក"

## សំនួររំឭករិះ មេរៀនទី៧

ចូរឆ្លើយសំនួរខាងក្រោមនេះ:

១.មធ្យោបាយធ្វើដំណើរដែលរេបិកាបានប្រើ.........................................................................................
*កំណើតពិភពលោក២៤:៦១*។

២.ប្រភេទផ្ទះរបស់អ៊ីសាកនិងរេបិកាគឺ...................................................................................................
*កំណើតពិភពលោក២៤:៦* ។

៣.អំណោយខ្លះៗដែលរេបិកាបានទទួល...................................................................................................
...................................................................................... *កំណើតពិភពលោក២៤:២២*។

៤.កន្លែងដែលអ្នកបំរើបានជួបរេបិកា......................................................................................................
*កំណើតពិភពលោក២៤:១៣*។

បំពេញចន្លោះទំនេរខាងក្រោម ដើម្បីបង្ហាញពីបទពិសោធន៍របស់ អ៊ីសាក និងរេបិកាដែលមានលក្ខណៈដូចនឹងបទពិសោធន៍ដែលយើងជួបនៅក្នុងសម័យព្រះគុណសព្វថ្ងៃ។

៥. អ៊ីសាកបានចេញពីផ្ទះរបស់គាត់មកជួបរេបិកា។ ព្រះគ្រីស្ទនឹងយាងមកពី.............................................
..............................................................................ដើម្បីជួបយើង ១ថេស្សាឡូនិក៤:១៦។

៦. រេបិកាតែងតែនៅជាមួយអ៊ីសាកជានិច្ច។ យើងនឹងនៅជាមួយព្រះគ្រីស្ទ...........................................
......................................................................................... *១ថេស្សាឡូនិក៤:១៧*។

៧. រេបិកាបានផ្តល់ការថ្នាក់ថ្នមទៅអ៊ីសាក។ យើងនឹង................... ......................................................
.........................................................អ្នកដទៃជាមួយការសន្យានេះ *១ថេស្សាឡូនិក៤:១៨*។

៨. អ៊ីសាកបានទទួលរេបិលកា ហើយស្រលាញ់ថ្នាក់ថ្នមនាង។ ព្រះយេស៊ូគ្រីស្ទទួលយើង និង...................
........................................................យើង *១យ៉ូហាន៤:១៦*។

៩. រេបិកាបាននិយាយអំពីអ៊ីសាកនៅពេលដែលនាងធ្វើដំណើរតាមផ្លូវ។ យើងត្រូវ.......................................
...........................ព្រះអម្ចាស់យេស៊ូគ្រីស្ទនៃយើងនៅពេលយើងធ្វើដំណើរនៅលើមាគ៌ានៃជីវិត *ទំនុកតម្កើង១០៥:២*។

១០ ចូរសរសេរខគម្ពីរចងចាំនៅ*ទំនុកតម្កើង៣៧:៥* ...........................................................................
.......................................................................................................................................................
.......................................................................................................................................................។

**មេរៀនទី៨ :** **ការប្រកួតបោកចំបាប់នៅលើផ្លូវសន្យា**

**កំណើតពិភពលោក ២៥-៣៥**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញថាការបន្ទន់ទៅតាមព្រះវិញ្ញាណដ៏វិសុទ្ធអាចនាំយើងទៅរកជ័យជំនះ ។**

តើមនុស្សចូលចិត្តការបោកចំបាប់គ្នាដែរឺទេ? មានការប្រកួតបោកចំបាប់ពីរប្រភេទក្នុងពិភពលោកនេះមួយ គឺការបោកចំបាប់ខាងសាច់ឈាមរវាងមនុស្សពីរនាក់ និងការបោកចំបាប់ខាងព្រលឹងវិញ្ញាណដែលយើងមិនអាចមើលឃើញ។ សព្វថ្ងៃពេលដែលយើងកំពុងធ្វើដំណើរយើងនឹងឮពីការបោកចំបាប់ដ៏ចំឡែកមួយរវាងមនុស្ស និងទេវតា ។

ក្រោយពីការស្លាប់របស់លោក *អាប្រាហាំ* ទៅព្រះជាម្ចាស់បានលេចមកអោយលោកអ៊ីសាកឃើញ និងបានបញ្ជាក់ដល់គាត់នូវការសន្យាទាំងអស់ដែលទ្រង់បានសន្យាជាមួយ *អាប្រាហាំ កំណើតពិភពលោក ២៦:៤*។ ព្រះជាម្ចាស់បានសន្យាថានឹងធ្វើអោយពូជពង្សរបស់គាត់កើនចំនួនច្រើនដូចជាផ្កាយនៅលើមេឃ។ លោក*អ៊ីសាក* បានជឿលើព្រះជាម្ចាស់ហើយគាត់បានរង់ចាំ។

*អ៊ីសាក* និង *រេបិកា* កើតបានកូនភ្លោះប្រុសពីរនាក់។ ទោះបីជាពួកគេជាបងប្អូនគ្នាក៏ដោយ *អេសាវ* និង *យ៉ាកុប* តែងតែប្រឆាំងគ្នាទៅវិញទៅមកតាំងពីក្នុងផ្ទៃម្តាយមកម្លេះ។ *អេសាវ* បានធំឡើងក្លាយជាអ្នកបរបាញ់ ប៉ុន្តែយ៉ាកុបចូលចិត្តនៅផ្ទះជាមួយហ្វូងចៀម និងហ្វូងសត្វរបស់ឪពុក។ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់នាង *រេបិកា* ថាកូនប្រុសច្បង *អេសាវ* នឹងបំរើកូនប្រុសប្អូន *យ៉ាកុប*។ ក្រុមគ្រួសារទាំងមូលដឹងថាព្រះជាម្ចាស់រក្សាការសន្យារបស់ទ្រង់ ប៉ុន្តែគ្មាននរណាម្នាក់ដឹងពីរបៀបដែលព្រះពរនៃការសន្យានោះបានទៅលើលោកយ៉ាកុបយ៉ាងណាឡើយ ។

ដំបូងបង្អស់គឺយ៉ាកុបបានទទួលនូវសិទ្ធិជាកូនច្បង ដែលមានមកពីកំណើតដោយការដោះដូរវត្ថុជាមួយ *អេសាវ កំណើតពិភពលោក ២៥:២៤-៣៤*។ ការនេះមានទំនាក់ទំនងទៅនឹងការសន្យានៃជាតិសាសន៍ និងព្រះសង្គ្រោះ។

លើកទីពីររេបិកាបានជំរុញអោយ*យ៉ាកុប* ទៅទទួលព្រះពរពី*អ៊ីសាក* ដោយការទាញយកផលប្រយោជន៍ពីភាពងងឹតភ្នែករបស់ឪពុកគាត់។ ព្រោះតែ *អេសាវ* មានសេចក្តីសំអប់ និងបានលក់សិទ្ធិជាកូនច្បង ឥឡូវនេះគាត់បានបាត់បង់ព្រះពរពីអ៊ីសាកដែរ *កំណើតពិភពលោក ២៧:១-៣៣*។ ហេតុនេះ*យ៉ាកុប* ត្រូវរត់ភៀសខ្លួនទៅនៅទឹកដីផ្សេង ដើម្បីកុំអោយអេសាវសម្លាប់គាត់បាន។ ព្រះជាម្ចាស់បានលេចឡើងអោយយ៉ាកុបឃើញ ហើយទ្រង់បានសន្យាថានឹងគង់ជាមួយថែរក្សាព្រមទាំងនាំគាត់ត្រឡប់មកលើទឹកដីរបស់អ៊ីសាកវិញ។ ព្រះអម្ចាស់នៃព្រះគុណចង់អោយលោកយ៉ាកុបទុកចិត្តលើទ្រង់ ដើម្បីធ្វើការបំពេញបំណងព្រះហឬទ័យរបស់ទ្រង់ និងចង់អោយលោកថ្វាយអ្វីៗទាំងអស់ទៅព្រះជាម្ចាស់។

យ៉ាកុបបានស្នាក់នៅស្រុក*ហារ៉ន* ផ្ទះលោក*ឡាបាន់* ត្រូវជាបងប្រុសរបស់រេបិកាអស់រយៈពេល២០ឆ្នាំ។ អំឡុងពេលដែលគាត់ស្នាក់នៅទីនោះមានបញ្ហាកើតឡើងយ៉ាងច្រើនរវាងយ៉ាកុប និងឪពុកមារបស់គាត់។ នៅចុងបញ្ចប់ព្រះជាម្ចាស់មានព្រះបន្ទូលទៅយ៉ាកុបអោយត្រឡប់ទៅលើទឹកដីសន្យាវិញ។ យ៉ាកុបបានយកប្រពន្ធរបស់គាត់កូនប្រុសទាំង ១១ នាក់ពួកអ្នកបំរើ និងហ្វូងចៀមរបស់គាត់ទាំងអស់ ហើយចាកចេញទៅនៅពេលយប់ព្រោះគាត់ខ្លាចលោកឡាបាន់។ វាជា

ការចាំបាច់មួយក្នុងការឆ្លងកាត់ទឹកដី*អេដុម* ជាទឹកដីដែលលោកអេសាវកាន់កាប់។ យ៉ាកុបមានការភ័យខ្លាចម្តងទៀត។ គាត់ក៏បានរៀបចំគំរោងការមួយដើម្បីធ្វើអោយអេសាវទន់ចិត្តអាណិតគាត់ និងគ្រួសាររបស់គាត់ជាមួយហ្វូងចៀមព្រមទាំងសត្វដទៃទៀតរបស់គាត់។ យ៉ាកុបបានចែកពួកគាត់ជាក្រុម ហើយដាក់អ្វីៗដែលគាត់ស្រលាញ់នៅផ្នែកខាងក្រោយ និង បានបញ្ជូនរបស់ល្អៗទាំងអស់ឆ្លងកាត់តាមអូរនៅពេលយប់ខណៈពេលដែលគាត់នៅតែម្នាក់ឯង។

រំពេចនោះមានបុរសម្នាក់មកពីស្ថានសួគ៌បានលេចឡើង ហើយចាប់ផ្តើមបោកចំបាប់ជាមួយលោកយ៉ាកុប។ ពួកគេបានបោកចំបាប់គ្នាពេញមួយយប់យ៉ាកុបបានប្រយុទ្ធដើម្បីការពារជីវិតរបស់គាត់។ ពេលដែលយ៉ាកុបមិនព្រមបោះបង់ចោលបុរសនោះក៏ប៉ះសាច់ចន្លូករបស់លោកយ៉ាកុបត្រង់កន្លែងប្រសព្វឆ្អឹងក៏ពោលថា "*អោយខ្ញុំទៅត្បិតជិតភ្លឺហើយ* " លោកយ៉ាកុបយល់ថាព្រះជាម្ចាស់មិនចង់សម្លាប់គាត់ទេ ប៉ុន្តែលោកក៏ព្រមចុះចាញ់ដោយសុំអោយបុរសនោះប្រទានពរដល់គាត់។ យ៉ាកុបក៏តបថា "*ខ្ញុំនឹងមិនលែងលោកឡើយ លុះត្រាតែលោកប្រទានពរអោយខ្ញុំសិន*"។ បុរសនោះពោលតបវិញថា "បុរសនោះពោលថាគេនឹងលែងហៅអ្នកថាយ៉ាកុបទៀតហើយគឺគេនឹងហៅអ្នកថា អ៊ីស្រាអែលវិញត្បិតអ្នកបានបោកចំបាប់ជាមួយព្រះជាម្ចាស់ និងជាមួយមនុស្សហើយអ្នកមានជ័យជំនះ"។

សព្វថ្ងៃយើងរស់នៅក្នុងសម័យកាល ដែលបានបង្ហាញដោយ "*អាកាសយានដ្ឋាននៃព្រះគុណ* " នៅលើផែនដី។ យើងមិនអាចមើលឃើញមនុស្សដែលនៅស្ថានសួគ៌បានទេ ប៉ុន្តែមានការអស្ចារ្យជាច្រើនដែលយើងមើលមិនឃើញហើយយើងកំពុងតែប្រឈមមុខជាមួយនោះគឺអំណាចនៃភាពងងឹត និងជីវិតចាស់របស់យើងដែរ។ ពេលដែលយើងទទួលព្រះយេស៊ូគ្រីស្ទជាព្រះអង្គសង្គ្រោះនោះព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើង ប៉ុន្តែយើងនៅតែមានអំពើបាបនៃជីវិតចាស់របស់យើង។ និស្ស័យលោកីយ៍ ឬក៏ផ្នែកសាច់ឈាមគឺតែងតែប្រឆាំងជាមួយព្រលឹងវិញ្ញាណ *កាឡាទី៥:១៦-១៧*។ យើងត្រូវតែសម្របជីវិតយើងទៅតាមព្រះវិញ្ញាណ ប្រសិនបើយើងចង់មានជ័យជំនះ និងទទួលព្រះពរនៅក្នុងជីវិតរបស់យើង។

ការទទួលការសង្គ្រោះ និងដំណើរនៅលើខ្សែបន្ទាត់នៃការសង្គ្រោះធ្វើអោយយើងក្លាយខ្លួនដូចជាទាហានក្នុងការប្រយុទ្ធលើអាកាសដ៏អស្ចារ្យគ្រប់ពេលវេលាទាំងអស់។ *អេភេសូ ៦:១២* បានប្រាប់យើងថាយើងប្រយុទ្ធនឹងឥទ្ធិពលអរូបិយដ៏អាក្រក់ទាំងឡាយដែលនៅស្ថានលើ។ វិញ្ញាណអាក្រក់ និងអំណាចនៃភាពងងឹតមិនចង់អោយយើងដែលជាអ្នកជឿលើព្រះយេស៊ូរស់នៅដោយទទួលជ័យជំនះខាងវិញ្ញាណទេ ដូចនេះយើងត្រូវតែពាក់ដោយគ្រឿងសស្ត្រាវុធ ដើម្បីប្រយុទ្ធប្រឆាំងជាមួយសត្រូវរបស់យើង *អេភេសូ ៦:១៣*។

ពេលលោកយ៉ាកុបបានថ្វាយខ្លួនទៅព្រះជាម្ចាស់ គាត់បានប្តូរឈ្មោះទៅជាអ៊ីស្រាអែលដែលមានន័យថា *អ្នកអង្គម្ចាស់ជាមួយព្រះ*។ ពេលអ្នកមិនជឿលើព្រះជាម្ចាស់ថ្វាយខ្លួនទៅព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះនោះពួកគេនឹងក្លាយទៅជា *បុត្រាបុត្រីនៃព្រះជាម្ចាស់*។ តើថ្ងៃនេះអ្នកជាបុត្រធីតានៃព្រះជាម្ចាស់ហើយ រឺនៅ?

**ខគម្ពីរចងចាំ:** *អេភេសូ ៦:១៣* ហេតុនេះចូរបងប្អូនប្រើគ្រឿងសស្ត្រាវុធទាំងប៉ុន្មាន របស់ព្រះជាម្ចាស់ទៅដើម្បីអោយបងប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហររឹងប៊ឹង ដដែលដោយបានប្រើគ្រប់មធ្យោបាយ ។

## សំនួររំឭកៈ មេរៀនទី៨

ប្រវត្តិរបស់លោកយ៉ាកុបបានបង្ហាញយើងនូវលក្ខណៈពីរយ៉ាងរបស់បុត្រធីតានៃព្រះ។ ទីមួយគឺជីវិតតាមបែបលោកីយ៍ ហៅថាជីវិតចាស់ដែលកំពុងព្យាយាមត្រួតត្រាលើជីវិតថ្មី។ យើងអាចបង្ហាញពីសកម្មភាពរបស់មនុស្សដែលនិស្ស័យនេះកំពុងគ្រប់គ្រងលើពួកគេ។ យកពាក្យនៅក្នុងតារាងខាងក្រោមរួចសរសេរដាក់តាមលក្ខណៈនិស្ស័យដែលបញ្ជាក់វា។ កាឡាទី ៥:១៩-២៣

សេចក្តីស្រលាញ់ ប្រមឹក ការឈ្លោះប្រកែកគ្នា សេចក្តីជំនឿ ការប្រឆាំងគ្នា សេចក្តីសុខសាន្ត ចិត្តស្លូតបូត ការកាប់សម្លាប់គ្នា ច្រណែនឈ្នានីស សេចក្តីអំណរ កំហឹងឃោរឃៅ ចិត្តអត់ធ្មត់។

| ជីវិតចាស់ | ជីវិតថ្មី |
|---|---|
| ១:.................................... | ១:.................................... |
| ២:.................................... | ២:.................................... |
| ៣:.................................... | ៣:.................................... |
| ៤:.................................... | ៤:.................................... |
| ៥:.................................... | ៥:.................................... |
| ៦:.................................... | ៦:.................................... |

៧. ប្រសិនបើយើងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ទគឺយើងនឹង ........................ ........................... ...............................ផ្ចៃកសាច់ឈាម ឬជីវិតចាស់ *កាឡាទី ៥:២៤*។ នេះជាមធ្យោបាយតែមួយក្នុងការយកជ័យជំនះលើជីវិតចាស់។

៨. ការប្រយុទ្ធរបស់យើងនៅស្ថានលើគឺជាការប្រយុទ្ធមួយផ្សេង។ *អេភេសូ ៦:១២* ប្រាប់យើងថាយើងមិនមែនប្រឆាំងជាមួយសាច់ឈាមទេ ប៉ុន្តែប្រឆាំង ជាមួយនឹងៈ

ក...........................................................................................................។

ខ...........................................................................................................។

គ...........................................................................................................។

ឃ...........................................................................................................។

៩.ប្រសិនបើយើងចង់ទទួលយកបាននូវជ័យជំនះនៅស្ថានលើ យើងត្រូវតែប្រើប្រាស់.................................... ...............................................................................របស់ព្រះជាម្ចាស់។ *អេភេសូ ៦:១៣*

១០ ចូរសរសេរខព្រះគម្ពីរ *អេភេសូ៦:១៣* ពីការចងចាំរបស់អ្នកៈ...................................................... ................................................................................................................................... ................................................................................................................................... ..........................................................។

**មេរៀនទី៩:** **ផ្លូវនៃការសន្យាបែកចេញទៅអេស៊ីប**

**កំណើតពិភពលោក ៣៧-៥០**

**គំនិតសំខាន់:** **ដើម្បីបង្ហាញពីប្រវត្តិរបស់អ៊ីស្រាអែលក្នុងការទំនាក់ទំនងទៅព្រះយេស៊ូគ្រីស្ទ**

តើអ្នកធ្លាប់មើលតាមរយៈកែវយឺតជាឧបករណ៍សំរាប់មើលអ្វីដែលនៅឆ្ងាយដែររឺទេ? ប្រសិនបើអ្នកធ្លាប់មើល អ្នកក៏បានឃើញពីចំងាយដ៏ឆ្ងាយដែរ។ ឥឡូវនេះយើងនឹងមើលទៅបុរសម្នាក់នៅលើ*ផ្លូវសន្យា* ដែលជីវិតរបស់គាត់ដូចជាកែវយឺតដែរ។ តាមរយៈបទពិសោធន៏របស់គាត់យើងអាចឃើញសម័យកាលព្រះយេស៊ូគ្រីស្ទ រឺក៏សម័យកាលខាងមុខនៃរាជាណាចក្រពីចំងាយនៅលើមាគ៌ានៃជីវិត។ យើងអាចហៅគាត់បានថាជា*បុរសគំរូម្នាក់* ព្រោះគាត់ជារូបភាពមួយដែលតំណាងអោយអ្វីៗដែលនៅខាងមុខ។ ជាពិសេសលោកយ៉ូសែបជារូបភាពបង្ហាញពីព្រះយេស៊ូគ្រីស្ទដែលត្រូវជនជាតិយូដាជាប្រជារាស្ត្ររបស់ទ្រង់ប្រព្រឹត្តចំពោះអង្គទ្រង់ពេលដែលព្រះអង្គមានព្រះជន្មរស់នៅលើផែនដីនេះ។

លោកយ៉ាកុបស្រលាញ់លោកយ៉ូសែបលើសកូនឯទៀតទាំងអស់ ពីព្រោះលោកយ៉ូសែបជាកូនប្រុសដែលកើតមកនៅពេលគាត់មានវ័យចាស់ណាស់ទៅហើយ យ៉ូសែបជាកូនរបស់គាត់ជាមួយប្រពន្ធសំណប់ចិត្តរបស់គាត់ គឺអ្នកស្រីរ៉ាជែល។ គាត់បានអោយអាវធំទៅយ៉ូសែបជាអាវដែលពិសេសមានចាក់ពណ៌ជាច្រើន តំណាងអោយអំណាចហើយអាវធំនេះជាមូលហេតុដែលបណ្តាលអោយ បងប្អូនរបស់គាត់ទាំងអស់ច្រណែនគាត់។

ថ្ងៃមួយយ៉ាកុបបានចាត់អោយយ៉ូសែបទៅកន្លែងមួយហៅថា *ស៊ីគែម* ទៅមើលពីរបៀបដែលបងប្អូនគាត់ធ្វើការ។ រំពេចនោះបងប្អូនគាត់ទាំងអស់ឃុបឃិតគ្នា ដើម្បីសម្លាប់យ៉ូសែបពីព្រោះតែអាវធំនោះ និងការច្រណែនដែលចេញពីចិត្តរបស់ពួកគេ។ ភ្លាមនោះផែនការមួយបានសំរេចឡើងដោយការបោះយ៉ូសែបចូលទៅក្នុងអណ្តូងដែលគ្មានទឹក ហើយបន្ទាប់មកគេនឹងប្រាប់ឪពុកពួកគេថាយ៉ូសែបស្លាប់បាត់ទៅហើយ។ ពេលពួកគេរៀបចំនឹងធ្វើគំរោងនេះ ពួកគេក៏ឃើញរទេះអ្នកជំនួញឆ្លងកាត់ផ្លូវទៅស្រុកអេស៊ីប។ ពួកគេក៏លក់លោកអោយជនជាតិអ៊ីស្មាអែលក្នុងតំលៃជាប្រាក់សុទ្ធ២0ស្លឹង។ អ្នកជំនួញទាំងនេះនាំយកគាត់ចូលទៅស្រុកអេស៊ីប ហើយលក់គាត់អោយធ្វើជាទាសករអោយលោកប៉ូទីផាជាមេទ័ពស្រុកអេស៊ីប។

យ៉ូសែបជាមនុស្សដែលពោរពេញដោយភាពស្មោះត្រង់ និងជាអ្នកបំរើដែលមានការទុកចិត្តទៅលើព្រះជាម្ចាស់ មិនបានប៉ុន្មានគាត់ក៏បានឡើងធ្វើជាអ្នកមេការនៅក្នុងផ្ទះរបស់លោកប៉ូទីផា។ ប៉ុន្តែយ៉ូសែបបានប្រឈមមុខនឹងអំពើបាបនៃសាច់ឈាមពេលប្រពន្ធរបស់លោកប៉ូទីផាបានព្យាយាមប្រលោមទាក់ចិត្តគាត់។ ពេលដែលគាត់បានបដិសេធស្ត្រីនោះក៏បានទំលាក់កំហុសដាក់យ៉ូសែប ហើយយ៉ូសែបក៏ត្រូវបានគេចាប់បញ្ជូនទៅក្នុងគុក។ ខណៈពេលដែលយ៉ូសែបនៅក្នុងគុកមានមនុស្សពីរនាក់ នៅជាមួយគាត់ដែលម្នាក់ជាអ្នកថ្វាយនំប៉័ង និងម្នាក់ទៀតជាអ្នកថ្វាយស្រាជូនស្តេច។ ពួកគាត់ទាំងពីរនាក់មានសុបិន្តនិមិត្តចំឡែកហើយជាសុបិន្តមិនធម្មតាយ៉ូសែបបានកាត់សុបិន្តអោយពួកគេដោយមាន ការណែនាំពីព្រះជាម្ចាស់។ អត្ថន័យនៃសុបិន្តនោះគឺម្នាក់ត្រូវស្លាប់ ហើយម្នាក់ទៀតនៅមានជីវិតរស់។ សុបិន្តបានក្លាយជាការពិតប៉ុន្តែយ៉ូសែបត្រូវបានគេភ្លេច។ ថ្ងៃមួយស្តេចផារ៉ោននៃប្រទេសអេស៊ីបបានសុបិន្តនិមិត្តអស្ចារ្យ ហើយមានតែមហាតលិកជាអ្នកថ្វាយ

ស្រាប៉ុណ្ណោះនៅទីកឃើញពីលោកយ៉ូសែបដែលនៅក្នុងគុក។ គាត់បានប្រាប់ស្តេចផារ៉ោនពីការកាត់សុបិន្តដ៏ត្រឹមត្រូវកាលពីគាត់នៅក្នុងគុក។ ស្តេចផារ៉ោនបានអោយគេទៅហៅលោកយ៉ូសែបដែលជាអ្នកចេះកាត់ស្រាយន័យសុបិន្តនិមិត្តយ៉ាងត្រឹមត្រូវថ្វាយទ្រង់។ ដោយហេតុនេះយ៉ូសែបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងប្រទេសអេស៊ីប បន្ទាប់ពីស្តេចផារ៉ោនទុកជារង្វាន់ដល់លោក។

យ៉ូសែបបានកាត់សុបិន្តថានឹងមានកើតទុរ្ភិក្សនៅក្នុងប្រទេសអេស៊ីបឆាប់ៗ។ ដោយយ៉ូសែបបានកាត់សុបិន្តយ៉ាងត្រឹមត្រូវប្រជាជនអេស៊ីបបានរៀបចំស្បៀងអាហារយ៉ាងច្រើន និងដាំដំណាំយ៉ាងច្រើនសំរាប់រក្សាទុកបំពេញតំរូវការទុកជាមុន។ ពេលគ្រោះទុរ្ភិក្សមកដល់ប្រជាជនអេស៊ីបមានស្បៀងអាហារច្រើនសំរាប់បរិភោគ។

លោកយ៉ាកុបបានអោយកូនប្រុសទាំង១០របស់គាត់ ទៅប្រទេសអេស៊ីបដើម្បីទិញស្បៀង។ ពួកគេបានឱនក្បាលគោរពពីមុខលោកយ៉ូសែប ហើយសុំទិញស្បៀងអាហារដើម្បីបំពេញតំរូវការគ្រួសារពួកគេដែលកំពុងស្រេកឃ្លាន។ តាមពិតពួកគាត់មិនបានស្គាល់ថាអ្នកគ្រប់គ្រងនោះជាលោកយ៉ូសែបដែលជាប្អូនប្រុសរបស់ពួកគេទេ ជាអ្នកដែលពួកគាត់បានលក់អោយធ្វើជាទាសករតាំងពីច្រើនឆ្នាំមុន! ពួកគាត់មិនអាចចំណាំលោកយ៉ូសែបបានទេ ប៉ុន្តែលោកយ៉ូសែបស្គាល់ពួកគេយ៉ាងច្បាស់។ លោកយ៉ូសែបបានល្បងលមើលចិត្តរបស់ពួកគាត់ ថាតើចិត្តពួកគាត់ផ្លាស់ប្តូរដែរឬទេ តាំងពីពួកគាត់បានលក់លោកមក។ *កំណើតពិភពលោកជំពូក ៤៤-៤៥* បានប្រាប់យើងអំពីការល្បងលទាំងអស់នោះ ដែលលោកល្បងលបងប្អូនរបស់គាត់។ ចុងបញ្ចប់ពួកគេបានបង្ហាញការពិតដែលបញ្ជាក់ពីភាពស្មោះត្រង់។ បន្ទាប់មកលោកយ៉ូសែបបានបង្ហាញខ្លួនអោយបងប្អូនរបស់គាត់ស្គាល់។ យើងអាចស្រមៃមើលពីការឱបក្តាយំ និងការរំភើបរីករាយពេលដែលពួកគាត់បានរៀនពីកិច្ចការទាំងនោះពីបងប្អូនប្រុសរបស់ពួកគាត់! បន្ទាប់មកយ៉ូសែបបានអញ្ជើញឪពុករបស់គាត់ និងនាំក្រុមគ្រួសាររបស់គាត់ទាំងមូលមករស់នៅក្នុងប្រទេសអេស៊ីប។ ព្រះជាម្ចាស់បានសន្យាប្រទានព្រះពរដល់លោកយ៉ាកុបក្នុងប្រទេសអេស៊ីប ហើយនឹងនាំជាតិសាសន៍របស់លោកត្រឡប់មកទឹកដីសន្យាវិញ *កំណើតពិភពលោក ៤៦:៣-៤*។

ឥឡូវនេះយើងនឹងមើលតាមរយៈកែវយឺតពីចំងាយដ៏ឆ្ងាយ។ តើចំនុចណាខ្លះដែលជីវិតលោកយ៉ូសែបមានបទពិសោធន៍ដូចបទពិសោធន៍របស់ព្រះយេស៊ូគ្រីស្ត?

១. ព្រះយេស៊ូ និងលោកយ៉ូសែបជាកូនប្រុសជាទីស្រលាញ់ដូចគ្នា *ម៉ាថាយ៣:១៧*។

២. ព្រះយេស៊ូ និង លោកយ៉ូសែបមានសេចក្តីជំនឿទៅលើបំណងព្រះហឫទ័យរបស់ ឪពុកដូចគ្នា *យ៉ូហាន៨:២៩*។

៣.ព្រះយេស៊ូ និងលោកយ៉ូសែបបានពាក់អាវធំនៃសិរីរុងរឿង ដូចគ្នា លោកយ៉ូសែប ពាក់អាវដែលមានពណ៌ច្រើន ចំណែកឯព្រះយេស៊ូពាក់អាវធំដែល ធ្វើពីក្រណាត់មួយផ្ទាំងគ្មានថ្នេរ *យ៉ូហាន ១៩:២៣*។

៤. ព្រះយេស៊ូនិងលោកយ៉ូសែបមានព័ន្ធកិច្ចនៃសេចក្តីមេត្តាទៅលើបងប្អូនរបស់ខ្លួន *យ៉ូហាន ១:១១*។

៥. ព្រះយេស៊ូ និង លោកយ៉ូសែបត្រូវបានគេស្អប់ដោយគ្មានមូលហេតុ *យ៉ូហាន ១៥:២៥*។

៦. ព្រះយេស៊ូ និងលោកយ៉ូសែបត្រូវបានគេលក់ក្នុងតំលៃជាប្រាក់មួយចំនួន *ម៉ាថាយ ២៦:១៥*។

៧. ព្រះយេស៊ូ និងលោកយ៉ូសែបត្រូវបានគេចោទប្រកាន់ *ម៉ាថាយ ២៦:៦០*។

៨. ព្រះយេស៊ូ និងលោកយ៉ូសែបត្រូវបានគេបំភ្លេច។ មហាតលិកភ្លេចលោកយ៉ូសែប ចំណែកឯព្រះយេស៊ូគ្រីស្ទ ត្រូវបានបំភ្លេចដោយលោកិយ៍ *យ៉ូហាន ១:១០*។

៩. ព្រះយេស៊ូ និងលោកយ៉ូសែបនៅជាមួយមនុស្សដែលមានទោស។ ម្នាក់ត្រូវបាត់បង់ជីវិតម្នាក់ទៀតទទួលសង្គ្រោះ *លូកា២៣:៣២*។

១០. ព្រះយេស៊ូ និងលោកយ៉ូសែបត្រូវបានគេលើកឡើងពីរូងក្រោមដី និងត្រូវបានគេលើកតម្កើង *ភីលីព២:៨-១១*។

១១. ព្រះយេស៊ូ និងលោកយ៉ូសែបបានសង្គ្រោះមនុស្សយ៉ាងច្រើនអោយគេចផុតពីសេចក្តីស្លាប់ និងអោយគេមានជីវិត *យ៉ូហាន៣:១០* និង *យ៉ូហាន១:១២*។

១២. ព្រះយេស៊ូ និងលោកយ៉ូសែបត្រូវបានលើកតម្កើងដោយ បងប្អូនរបស់ពួកលោក*សាការី១២:១០*។

១៣. ព្រះយេស៊ូ និងលោកយ៉ូសែបបានផ្តល់អ្វីៗគ្រប់យ៉ាង ដើម្បីអ្នកដែលលោកស្រលាញ់ *យ៉ូហាន១៤:១-៦* និង *រ៉ូម៨:៣២*។

លោកយ៉ាកុប និងលោកយ៉ូសែបបានស្លាប់ក្នុងប្រទេសអេស៊ីប ប៉ុន្តែពួកលោកស្លាប់ដោយមានក្តីសង្ឃឹម។ លោកយ៉ូសែបបានពោលថា "ខ្ញុំស្លាប់ ប៉ុន្តែព្រះជាម្ចាស់នឹងពិតជាមកសួរសុខទុក្ខអ្នក" *កំណើតពិភពលោក ៥០:២៤-២៦*។ ព្រះជាម្ចាស់ដែលដឹកនាំអ្នកនៅលើផ្លូវសន្យាមិនដែលកុហក ហើយព្រះអង្គក៏មិនដែលបំភ្លេចការសន្យារបស់ទ្រង់ដែរ។

តើទ្រង់ជាព្រះដ៏អស្ចារ្យរបស់អ្នករឺទេ? ទ្រង់អាចធ្វើអ្វីៗទាំងអស់ ប្រសិនបើអ្នកទទួលយកព្រះបុត្រារបស់ទ្រង់គឺព្រះអម្ចាស់យេស៊ូគ្រីស្ទជាព្រះអង្គសង្គ្រោះដោយរួមជាមួយព្រះយេស៊ូគ្រីស្ទអ្នកនឹងទទួលបាននូវអ្វីៗ ទាំងអស់ *រ៉ូម៨:៣២*។

**ខព្រះគម្ពីរចងចាំ:** *រ៉ូម ៨:៣២* ព្រះអង្គពុំបានទុកព្រះបុត្រារបស់ព្រះអង្គផ្ទាល់ទេគឺ ព្រះអង្គបានបញ្ជូនព្រះបុត្រានោះមកសំរាប់យើងទាំងអស់គ្នា បើដូច្នោះព្រះអង្គមុខជាប្រណីសណ្តោស ប្រទានអ្វីៗទាំងអស់មកយើងរួមជាមួយព្រះបុត្រានោះដែរ ។

## សំនួររត្រិះរិះ មេរៀនទី៩

អ្នកត្រូវស្វែងរកចំលើយដាក់ក្នុងឃ្លាទាំង៩ ខាងក្រោមអំពីព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ទនៃយើង។ ចូរបំពេញនូវព្រឹត្តការណ៍ដែលអ្នកគិតថា យ៉ូសែបមានលក្ខណៈស្រដៀងនឹងព្រះយេស៊ូនៃ ឃ្លានីមួយៗនៅខាងក្រោមៈ

១. ព្រះអម្ចាស់យេស៊ូគ្រីស្ទជាព្រះបុត្រាជាទីស្រលាញ់តែមួយគត់របស់ព្រះបិតា *ម៉ាថាយ ៣:១៧*។

លោកយ៉ូសែបគឺជាកូនប្រុសជាទីស្រលាញ់របស់.................................................................................

......................................................*កំណើតពិភពលោក ៣៧:៣*។

២. ព្រះយេស៊ូយាងមកពីស្ថានសួគ៌ដើម្បីបំពេញព័ន្ធកិច្ចនៃក្តីមេត្តាករុណា ចំពោះបងប្អូន របស់ទ្រង់ជនជាតិយូដា *យ៉ូហាន ១:១១*

លោកយ៉ូសែប..........................................................................................................................

*កំណើតពិភពលោក ៣៧:១៣*។

៣. ព្រះយេស៊ូត្រូវគេស្អប់ដោយគ្មានមូលហេតុអ្វីទាំងអស់ *យ៉ូហាន ១៥:២៥*។

ចំណែកឯលោកយ៉ូសែបត្រូវបាន ......................................................................................................

..........................................*កំណើតពិភពលោក ៣៧:៥ និង ១១*។

៤. ព្រះយេស៊ូបាននៅជាមួយចោរពីរនាក់ក្នុងភាពអាម៉ាស់មានចោរមួយត្រូវបាត់បង់ជីវិត ហើយម្នាក់ទៀតបានទទួលការសង្គ្រោះ *លូកា២៣: ៣២*។

លោកយ៉ូសែបមាន...................................................................................................................

.........ពីរនាក់នៅជាមួយលោកដែរ *កំណើតពិភពលោក ៤០:១-៣*។

៥. ព្រះយេស៊ូត្រូវបានគេលក់ក្នុងតំលៃជាប្រាក់សុទ្ធ៣០ស្លឹង *ម៉ាថាយ ២៦:១៥*។

លោកយ៉ូសែបត្រូវបានគេលក់ក្នុងតំលៃ ..............................................................................................

.......................................................*កំណើតពិភពលោក ៣៧:២៨*។

៦. ថ្ងៃណាមួយព្រះយេស៊ូនឹងត្រូវបានគេលើកតម្កើងសិរីរុងរឿង ដោយបងប្អូនរបស់ទ្រង់ជាជនជាតិយូដាហើយទ្រង់នឹងឡើងគ្រងរាជ្យលើពួកគេ *សាការី ១២:១០*។

លោកយ៉ូសែបត្រូវបានគេគោរព និងកោតសរសើរដោយ..............................................................................

.......................................................*កំណើតពិភពលោក ៤៥:២៦*។

៧. ព្រះយេស៊ូសង្គ្រោះមនុស្សពីសេចក្តីស្លាប់អោយមានជីវិតអស់កល្ប *យ៉ូហាន ៣:១៦*។ លោកយ៉ូសែបបានសង្គ្រោះ.

.....................................................................................................................................

.................................................................. *កំណើតពិភពលោក ៤១:៥៦-៥៧*។

៨. ព្រះយេស៊ូប្រទានអ្វី១ទាំងអស់ដោយព្រោះតែសេចក្តីស្រលាញ់ របស់ទ្រង់តែមួយគត់ *រ៉ូម ៨:៣២*។

យ៉ូសែបបានផ្តល់.............................. ...................................................................... *.កំណើតពិភពលោក ៤៥:១១-១២*។

៩. ព្រះយេស៊ូបានរស់ឡើងវិញពីផ្នូរ និងត្រូវបានលើកតម្កើងនៅស្ថានបរមសុខ *ភីលីព ២:៩-១១*។

លោកយ៉ូសែបត្រូវបានលើកឡើងវិញពី................................................................ ...............................

*កំណើតពិភពលោក ៤១:១៤ និង ៤១*។

១០.ចូរសរសេរខគម្ពីរចងចាំ រ៉ូម ៨:៣២ ដែលប្រាប់យើងពីរបៀបដែលព្រះជាម្ចាស់ ប្រទានអ្វី១ទាំងអស់សំរាប់យើង:.......................................................................................................................

...........................................................................................................................................។

## មេរៀនទី១០ : បុណ្យរំលង និងការឆ្លងកាត់លើផ្លូវនៃការសន្យា

**សេរីភាព ១-១៤**

**គំនិតសំខាន់ : ដើម្បីបង្រៀនពីភាពពេញលេញនៃសេចក្តីសង្គ្រោះក្នុងអង្គព្រះគ្រីស្ត**

សូមយើងតាំងខ្លួនមួយភ្លែតដោយគិតថា ប្រទេសរបស់អ្នកស្ថិតក្នុងសង្គ្រាម! សត្រូវកំពុងបញ្ជូនយន្តហោះពេញដោយគ្រាប់បែកទំលាក់លើប្រទេសអ្នក! អ្នកឃើញពួកគេកំពុងមកមានចំនួនយ៉ាងច្រើន។ អ្នកចាប់ផ្តើមអធិដ្ឋានអោយពួកគេហោះរំលងផុតទៅដោយគ្មានការទំលាក់គ្រាប់បែក។ ពេលពួកគេហោះរំលងមែននោះអ្នកនឹងមានសុវត្ថិភាព! សេចក្តីស្លាប់មិនអាចប្រហារអ្នកបានឡើយ។

ថ្ងៃនេះយើងនឹងសិក្សាពីរបៀបដែលប្រជារាស្ត្ររបស់ព្រះអង្គត្រូវបានសង្គ្រោះពីសេចក្តីស្លាប់បីប្រភេទខណៈពេលដែលពួកគេបានរួមធ្វើដំណើរលើផ្លូវសន្យា។ ចុងបញ្ចប់នៃមេរៀនមុនយើង ស្ថិតក្នុងប្រទេសអេស៊ីបបន្ទាប់ពីការស្លាប់របស់លោកយ៉ាកុប និងលោកយ៉ូសែប។ នៅពេលលោកយ៉ូសែបកាន់អំណាចគ្រប់យ៉ាងមានដំណើរការល្អចំពោះកូនចៅអ៊ីស្រាអែល ដែលជាពូជពង្សលោកយ៉ាកុប ប៉ុន្តែជាច្រើនឆ្នាំក្រោយមកស្តេចផារ៉ោនថ្មីឡើងសោយរាជ្យ។ ដោយសារទ្រង់មានការភ័យខ្លាចចំពោះការកើនឡើងនៃប្រជាជនអ៊ីស្រាអែលទ្រង់ ចាប់ក៏ផ្តើមកៀបសង្កត់ពួកគេជាទាសករ *សេរីភាព១:៨-២២*។

នៅពេលដែលទុក្ខវេទនាកាន់តែកើនឡើងប្រជាជនអ៊ីស្រាអែលមិនអាចទាំទ្របានពួកគេបានស្រែកយំអង្វររកព្រះជាម្ចាស់ *សេរីភាព ២:២៣-២៥*។ ទ្រង់ព្រះសណ្តាប់ពួកគេ ហើយបានត្រាស់ហៅជនជាតិអ៊ីស្រាអែលម្នាក់ឈ្មោះម៉ូសេ ដើម្បីដឹកនាំប្រជាជនរបស់ទ្រង់ទៅកាន់ទឹកដីសន្យាដែល ទ្រង់សន្យាចំពោះលោកអាប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប។ យើងហៅទីនោះថាជាទឹកដីសន្យា។ ព្រះអង្គទ្រង់ប្រទានទីសំគាល់ជាច្រើន ឬគ្រោះកាចទៅលោកម៉ូសេ ដើម្បីបង្ហាញដល់ប្រជាជនអ៊ីស្រាអែល និងប្រជាជនអេស៊ីបថាព្រះដ៏ពិតគង់នៅជាមួយលោកម៉ូសេ។ យើងអាចអានពីរឿងដ៏គួរអោយចាប់អារម្មណ៍គ្រោះកាច និងការប្រយុទ្ធប្រឆាំងគ្នានៅក្នុង *សេរីភាព ៧:៨-១១: ១០*។ ព្រះជាម្ចាស់ទ្រង់បណ្តាលអោយមានភាពខុសគ្នាយ៉ាងជាក់ច្បាស់រវាងប្រជាជនអេស៊ីប និងប្រជាជនអ៊ីស្រាអែល ប៉ុន្តែបន្ទាប់ពីកិច្ចការទាំងអស់នេះស្តេចផារ៉ោននៅតែបដិសេធមិនអោយអ៊ីស្រាអែលចាកចេញពីអេស៊ីបឡើយ។

ព្រះជាម្ចាស់បានប្រាប់លោកម៉ូសេអំពីផែនការនៃបុណ្យរំលងនៃកូនចៀមនៅក្នុង *សេរីភាព ១២* ។ ប្រជាជនទាំងអស់ធ្វើតាមផែនការដែលព្រះជាម្ចាស់បានប្រាប់ដល់លោកម៉ូសេជាអ្នកដឹកនាំ។ នៅកណ្តាលអាធ្រាតយប់មួយព្រះជាម្ចាស់ឆ្លងកាត់ប្រទេសអេស៊ីបហើយសម្លាប់គ្រប់កូនច្បងនៃគ្រប់ផ្ទះ។ ទ្រង់បានប្រាប់ដល់ប្រជាជនអ៊ីស្រាអែលហើយថាអោយពួកគេត្រូវសម្លាប់ចៀមហើយយកឈាមលាបនៅខ្លោងទ្វារផ្ទះនោះពួកគេនឹងរួចជីវិត ឯផ្ទះណាដែលគ្មានឈាមនោះគ្រប់កូនច្បងនឹងត្រូវសំលាប់។ យប់នោះសេចក្តីស្លាប់កើតឡើងគ្រប់ផ្ទះនៃប្រជាជនអេស៊ីបសម្រែកនៃការយំសោកកើតឡើងពេញផ្ទៃប្រទេស។

ភ្លាមៗនោះស្តេចផារ៉ោនស្រែកថា "ចេញទៅ" ដូចនេះលោកម៉ូសេដឹកនាំប្រជាជនចេញពីប្រទេសអេស៊ីប។ ប្រជាជនអេស៊ីបបានផ្តល់អំណោយដល់ជនជាតិអ៊ីស្រាអែលជាថ្លៃទាសករ។ អេស៊ីបមានការត្រេកអរក្នុងការបណ្តេញអ៊ីស្រាអែល។ នៅពេលជនជាតិអ៊ីស្រាអែលស្ថិតក្នុងការភៀសខ្លួនទាហានស្តេចផារ៉ោនបានដេញតាមក្រោយពួកគេ។ ស្តេចផារ៉ោនបានប្តូរគំនិត ហើយសំរេចចិត្តមិនអោយអ៊ីស្រាអែលចាកចេញទេ នៅពីមុខអ៊ីស្រាអែលមានសមុទ្រក្រហមដែលគ្មានផ្លូវឆ្លងកាត់ រីផ្លូវវៀងនោះឡើយ។

លោកម៉ូសេប្រាប់ប្រជាជនថា "កុំភ័យខ្លាចអ្វីឡើយ ចូរតាំងស្មារតីឡើង... ព្រះជាម្ចាស់សង្គ្រោះអ្នករាល់គ្នា... ព្រះអង្គច្បាំងជំនួសអ្នករាល់គ្នា " *សេរីភាព ១៤:១៣-១៤*។ បន្ទាប់មកលោកម៉ូសេលើកដំបងតំរង់ទៅសមុទ្រក្រហម ហើយទឹកក៏ញែកជាពីរ។ ដីស្ងួតក៏លេចឡើងដើម្បីអោយអ៊ីស្រាអែលឆ្លងកាត់ដោយសុវត្ថិភាព។ តើទាហានដែលដេញតាមនោះអាចឆ្លងដោយសុវត្ថិភាពពីរ? ទេ! ពួកគេគិតថាអាចឆ្លងកាត់បានតែពួកគេត្រូវលិចក្នុងកណ្តាលសមុទ្រទៅវិញ។

អ៊ីស្រាអែលទទួលការសង្គ្រោះពីសេចក្តីស្លាប់បីយ៉ាងគឺ ១. ពិការ សម្លាប់របស់ទេវតា ២. ពីសមុទ្រក្រហម ៣. ពីទាហាននៃស្តេចផារ៉ោន។ ព្រះទ្រង់ធ្វើកិច្ចការទាំងអស់នេះដោយអំណាចចេស្តាទ្រង់។ យើងអស់អ្នកដែលរស់នៅក្នុងអាកាសយាន្តនៃព្រះគុណសព្វថ្ងៃក៏ឈ្នះសេចក្តីស្លាប់បី យ៉ាងដែរគឺ ១. លោកីយ៍ ២. សាច់ឈាម ៣. សាតាំង។ ឥលូវយើងអាចពិចារណាពីបទពិសោធន៍ របស់យើង ដែលស្រដៀងនឹងការភៀសខ្លួនរបស់អ៊ីស្រាអែល។

អេស៊ីបតំណាងអោយលោកីយ៍ដែលត្រូវវិនិច្ឆ័យនៅថ្ងៃណាមួយ។ អ៊ីស្រាអែលទទួលការសង្គ្រោះពីការវិនិច្ឆ័យដោយឈាមដែលលាបលើខ្លោងទ្វារ រីឯយើងបានទទួលលការសង្គ្រោះតាមរយៈព្រះលោហិតរបស់ព្រះគ្រីស្តដែលលាបក្នុងដួងចិត្តយើង។

សាច់ឈាមគឺជាជីវិតចាស់ដែលប្រឆាំងនឹងជីវិតខាងព្រលឹងវិញ្ញាណ។ អ៊ីស្រាអែលហូបសាច់ចៀមអាំងនៅបុណ្យរំលង ដើម្បីមានកំលាំងក្នុងដំណើររបស់ពួកគេ រីឯយើងរស់នៅក្នុងអង្គព្រះគ្រីស្តដោយសិក្សាព្រះបន្ទូលរបស់ព្រះអង្គ ដើម្បីទទួលយកកំលាំងក្នុងការធ្វើដំណើរជីវិត។ គោលដៅរបស់យើងគឺលះបង់ចោលជីវិតចាស់ ហើយទទួលជីវិតថ្មីនៃព្រះវិញ្ញាណដែលកើតឡើងតាមការបំពេញអាហារមកពីព្រះវិញ្ញាណគឺព្រះបន្ទូល។

ស្តេចផារ៉ោននិងពលទាហានស្តេចតំណាងអោយសាតាំងនិងពួកបរិវា។ នៅពេលដែលអ៊ីស្រាអែលទទួលការសង្គ្រោះតាមរយៈការស្តាប់បង្គាប់ពាក្យមេដឹកនាំរបស់ពយកកគេគឺលោកម៉ូសេ ដូច្នេះយើងទទួលការសង្គ្រោះតាមរយៈការស្តាប់បង្គាប់ព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូគ្រីស្ត។ ដោយសារសេចក្តីជំនឿយើងមានជ័យជំនះលើគ្រោះមរវាងជីវិតចាស់និងជីវិតថ្មី។ យើងកាន់តែមានជ័យជំនះលើការល្បួង និងទុក្ខលំបាកដែលសាតាំងដាក់នៅក្នុងជីវិតយើងដោយការស្តាប់បង្គាប់មេដឹកនាំរបស់យើង ប្រសិនបើយើងមិនស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ដូចអ៊ីស្រាអែលមិនស្តាប់បង្គាប់ពាក្យរបស់លោកម៉ូសេយើងនឹងចាញ់សត្រូវរបស់យើង។

យើងឃើញករណីនីមួយៗនៃការសង្គ្រោះរបស់អ៊ីស្រាអែលពឹងផ្អែកលើការជឿ និងការស្តាប់បង្គាប់ព្រះជាម្ចាស់។ នៅពេលនោះទ្រង់បង្ហាញអំណាចចេស្តាទ្រង់។ ការសង្គ្រោះរបស់យើងចេញពីលោកីយ៍សាច់ឈាម និងសាតាំងពឹងផ្អែកលើសេចក្តីជំនឿ និងការស្តាប់បង្គាប់ព្រះបន្ទូលព្រះជាម្ចាស់។ ព្រះយេស៊ូគឺជាបុណ្យរំលងរបស់យើងដែលបានបូជាសំរាប់

យើង។ យើងជឿលើព្រះយេស៊ូគ្រីស្តហើយទទួលទ្រង់ជាព្រះសង្គ្រោះដោយទទួលព្រះលោហិតទ្រង់ក្នុងដួងចិត្តនិងជីវិតយើង។ នៅពេលនោះទ្រង់នឹងបំពេញការសង្គ្រោះដ៏អស្ចារ្យនេះ។

**ខព្រះគម្ពីរចងចាំ:** *១កូរិនថូស ៥:៧*

" ដ្បិតគេសម្លាប់ព្រះយេស៊ូធ្វើជាយញ្ញបូជារបស់យើងក្នុង ឱកាសបុណ្យរំលងរួចស្រេចទៅហើយ "

## សំនួរត្រិះរិះ មេរៀនទី១០

១.អ៊ីស្រាអែលឈានដើរតាមផ្លូវនៃការសន្យាទៅក្នុងប្រទេសណា? សេរីភាព ១:១...................................
.............................................................................................................................។

២.ហេតុអ្វីបានជាយើងហៅទឹកដីកាណានថាជាទឹកដីសន្យា? សេរីភាព ១២:២៥.........................................
............................................................................................................................................
...........................................................................................។

៣.តើអ្វីខ្លះជាគ្រោះកាចដែលព្រះជាម្ចាស់បានដាក់ចំពោះប្រទេសអេស៊ីប? សេរីភាព ៧-១២.......................
..................................................................................................................................
..................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
..........................។

ព្រះជាម្ចាស់សង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គពីសេចក្ដីស្លាប់បីយ៉ាង នៅពេលដែលពួកគេរត់ភៀសខ្លួនទៅទឹកដីកាណាននៅលើផ្លូវនៃការសន្យា។ សូមបំពេញ ចន្លោះ

៤.សេរីភាព ១២:១២- ១៣...............................................................................។

៥.សេរីភាព ១៤:២២-២៣...............................................................................។

៦.សេរីភាព ១៤:២៧-២៨...............................................................................។

យើងទទួលការសង្គ្រោះមានសុវត្ថិភាពពីសត្រូវរបស់យើងដែលចង់បំផ្លាញរាងកាយ
និងព្រលឹងវិញ្ញាណរបស់យើង។ ព្រះទ្រង់មានវិធីបីយ៉ាង ដើម្បីប្រើ។ ចូរបំពេញចន្លោះខាងក្រោម:

៧.កាឡាទី១:៤ព្រះគ្រីស្តប្រទានអង្គទ្រង់ដើម្បីអាចរំដោះយើងអោយ រួចពី.........................................
............................................................................................................................................
...................................................................................................................................។

៨. រ៉ូម ៨:១៣ ប្រសិនបើបងប្អូនរស់តាម.......................................................................................................

..........................................................................................................បងប្អូននឹងត្រូវស្លាប់មិនខាន។

៩. ១ពេត្រុស៥:៨ សត្រូវរបស់អ្នកគឺ........................................................................................................

..............................................................តាមស្វែងរកអ្នកដើម្បីបំផ្លាញ។

១០. សរសេរខព្រះគម្ពីរចងចាំ ១កូរិនថូស៥:៧

..........................................................................................................................................................

..........................................................................................................................................................

..................................................................................។

**មេរៀនទី ១១ : ស្រមោលភ្នំផ្លូវនៃការសន្យា**

**សេរីភាព ១៥-៣២**

**គំនិតសំខាន់ : ដើម្បីបង្ហាញហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យ និងទៅកានអ្នកដែលព្រះជាម្ចាស់ប្រទាន**

តើអ្នកធ្លាប់ឃើញភ្នំដែរឬទេ? ដោយមើលពីចំងាយយើងឃើញថាហាក់ដូចជាកូនភ្នំដ៏តូចមួយប៉ុន្តែពេលអ្នកមកកាន់តែជិតវាកាន់តែធំដែលអ្នកមិនអាចមើលបានសព្វឡើយ ។ ឥលូវពេលដែលយើងសិក្សាអំពីអ៊ីស្រាអែលលើផ្លូវនៃការសន្យា យើងនឹងមកដល់ភ្នំស៊ីណៃ។ អ្នកនឹងដឹងលឺពីរបៀបដែលវាក្លាយជាភ្នំដ៏គួរអោយភ័យខ្លាចរបៀបដែលវាមានផ្សែង រញ្ជួយ និងរបៀបដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ម៉ូសេ ។ វាជាពេលមួយដ៏យូរមុនពេលអ៊ីស្រាអែលឆ្លងកាត់ស្រមោលនៃភ្នំនេះ ។

អ៊ីស្រាអែលឥលូវស្ថិតនៅលើផ្លូវនៃការសន្យាចុះទៅកាន់ទឹកដីសន្យា ។ ព្រះជាម្ចាស់នឹងល្បងលប្រជារាស្ត្ររបស់ទ្រង់ ដើម្បីមើលថាពួកគេរៀបចំខ្លួនរួចជាស្រេចដើម្បីទទួលទឹកដីសន្យា ដែលព្រះជាម្ចាស់បានសន្យាចំពោះអាប្រាហាំ អ៊ីសាក និងយ៉ាកុប ។ ព្រះអង្គក៏ចង់បង្ហាញថាអ៊ីស្រាអែលត្រូវការទ្រង់គ្រប់ពេល និងគ្រប់ផ្លូវដែលគេដើរ ។

បន្ទាប់ពីពួកគេឆ្លងកាត់ទន្លេក្រហម ពួកគេចូលទៅក្នុងវាលរហោស្ថានស៊ួរ ឥលូវការល្បងលចាប់ផ្តើមលើពួកគេ:

១ កាល្បងលទី១: ប្រភពទឹកម៉ារ៉ា *សេរីភាព ១៥:២២-២៥*។ ប្រជាជនធ្លាក់ចុះនៅពេលដែលគេរអ៊ូរទាំ ប៉ុន្តែព្រះជាម្ចាស់ស្មោះត្រង់ចំពោះពួកគេ ។ ដើមឈើជារូបភាពពីព្រះគ្រិស្តដែលធ្វើអោយទឹកទៅជាផ្អែម ។ ព្រះយេស៊ូសុគតនៅលើឈើឆ្កាង ដើម្បីដកអស់ទាំងភាពល្វីងជូរចត់នៃអំពើបាបរបស់យើងទៅដាក់លើអង្គទ្រង់ផ្ទាល់ ។

២ ការល្បងលទី២: *ភាពស្រេកឃ្លាន សេរីភាព ១៦:៣-២១*។ ប្រជាជនធ្លាក់ចុះម្តងទៀត ប៉ុន្តែព្រះទ្រង់បង្ហាញភាពស្មោះត្រង់ដោយប្រទាន *នំម៉ាណា*។ *នំម៉ាណា* ជាប្រភពនំបង្ហាញពីព្រះគ្រិស្តជានំបុ័ងជីវិត *យ៉ូហាន៦* ។

៣ ការល្បងលទី៣: ការសំរាកនៅរេភីឌីម *សេរីភាព១៧:១-៧*។ ពួកប្រជាជនធ្លាក់ចុះ ប៉ុន្តែព្រះជាម្ចាស់ប្រទានទឹកចេញមកពីថ្ម។ ថ្មតំណាងអោយព្រះគ្រិស្ត ហើយទឹកគឺជាព្រះវិញ្ញាណដ៏វិសុទ្ធ *យ៉ូហាន៤:១៤* ព្រះវិញ្ញាណដ៏វិសុទ្ធតាមការឈឺចាប់នៃការសុគតរបស់ព្រះគ្រិស្ត ។

បន្ទាប់មកអ៊ីស្រាអែលមកដល់ភ្នំស៊ីណៃហើយបោះជំរុំនៅពីមុខភ្នំ ។ ពេលវេលាបានមកដល់ជាពេលវេលានៃការល្បងលដ៏ធំ *សេរីភាព ២០:២០*។ ព្រះអង្គនឹងល្បងលមើលសេចក្តីស្រលាញ់ និងសេចក្តីជំនឿអ៊ីស្រាអែលចំពោះទ្រង់តាមក្រឹត្យវិន័យដែលទ្រង់ប្រទាន *សេរីភាព១៩:៥-៦*។ លោកម៉ូសេឡើងទៅលើភ្នំហើយព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់គាត់ *សេរីភាព ១៩*។ គ្រប់គ្នាភ័យខ្លាចពីភាពដ៏វិសុទ្ធនៃទ្រង់នៅពេលពួកគេលឺពីក្រឹត្យវិន័យនៅក្នុង*សេរីភាព២០:១៨-២០*។ ក្រឹត្យវិន័យត្រូវបានបន្ថែមទៅលើការសន្យា ។ យើងឃើញថាក្រឹត្យវិន័យនៃការធ្វើដំណើរមានការកើនឡើង *កាឡាទី ៣:១៩-២៨*។

តើអ្នករំពឹងថាអ៊ីស្រាអែលនឹងធ្វើអ្វីនៅពេលម៉ូសេនៅលើភ្នំ? ពួកគេបំផ្លាញ់ក្រឹត្យវិន័យដំបូងបង្អស់ដែលបានដាក់។ *សេរីភាព ៣២* បានប្រាប់យើងអំពីគោមាស ព្រះពិរោធរបស់ព្រះយេហូវ៉ា ការជួយសុំទោសរបស់ម៉ូសេ ការបំបែកថ្មនៃសម្ព័ន្ធមេត្រី ហើយនឹងការវិនិច្ឆ័យអ៊ីស្រាអែល ៣០០០ នាក់។

តើអ៊ីស្រាអែលបានឆ្លងផុតការល្បងលដែរឬទេ? ទេ! សូម្បីតែនៅថ្ងៃដំបូងបន្ទាប់ពី ក្រឹត្យវិន័យត្រូវបានដាក់ ហើយនេះមិនមែនជាចុងបញ្ចាប់នៃការល្បងលនោះទេ។ ព្រះអង្គបានដាក់អោយគេនៅក្រោមក្រឹត្យវិន័យជាច្រើនឆ្នាំ ប៉ុន្តែពួកគេបំផ្លាញគ្រប់ទាំងក្រឹត្យវិន័យម្តងហើយម្តងទៀត។ ព្រះអង្គបន្ថែមក្រឹត្យទៅលើការសន្យាដោយសារអំពើបាបរបស់អ៊ីស្រាអែលក្រឹត្យវិន័យត្រូវបានបន្ថែមរហូតដល់គ្រាប់ពូជនៃការសន្យាមក ប៉ុន្តែពួកគេបញ្ចប់ដោយការឆ្កាងអង្គនៃការសន្យាពេលទ្រង់យាងមក។ ឥឡូវយើងឃើញថា ហេតុអ្វីបានជាក្រឹត្យវិន័យត្រូវបានដាក់ ហើយវាបង្ហាញពីអ្វី។

ក្រឹត្យវិន័យត្រូវបានដាក់អោយដោយសារតែអំពើបាប *កាឡាទី ៣: ១៩*។ អ៊ីស្រាអែលប្រព្រឹត្តអំពើបាបម្តងហើយម្តងទៀត ប៉ុន្តែពួកគេមិនយកចិត្តទុកដាក់លើអំពើបាបរបស់ពួកគេឡើយ។

ក្រឹត្យវិន័យបង្ហាញថាអ៊ីស្រាអែលពេញដោយអំពើបាបដូចជាសាសន៍ដទៃ ដែលគ្មានមូលហេតុអាចដោះសារបានឡើយ *រ៉ូម ៣:១៩-២០*។

ក្រឹត្យវិន័យបង្ហាញថាភាពដ៏វិសុទ្ធនៃព្រះជាម្ចាស់តំរូវអោយមានភាពសុចរិតគ្រប់លក្ខណ៍ដែរ *សេរីភាព២០:៣-៦*។ ដូចនេះក្តីសង្ឃឹមនៃអ៊ីស្រាអែលស្ថិតនៅលើភាពសុចរិតអង្គនៃការសន្យា គឺព្រះយេស៊ូគ្រិស្ត *កាឡាទី ៣:២៩*។

ក្រឹត្យវិន័យត្រូវបានផ្តល់ដល់អ្នកណា? គឺអ៊ីស្រាអែល។ ក្រឹត្យវិន័យត្រូវបានឆ្លងនៅលើភ្នំកាល់វ៉ារី។ តើក្រឹត្យវិន័យត្រូវបានផ្តល់ឱ្យយើងជាអ្នករស់នៅលើអាកាសយាននៃព្រះគុណដែរ ឬទេ? ទេ! ប៉ុន្តែយើងអាចរៀនក្រឹត្យវិន័យចេញពីអ៊ីស្រាអែលរៀនដែរ។ យើងទន់ខ្សោយហើយមានអំពើបាប។ ព្រះជាម្ចាស់ទាមទារនូវសេចក្តីសុចរិតគ្រប់ល័ក្ខណ៍។ យើងគ្រាន់តែបានទទួលភាពសុចរិត បានតាមរយៈការជឿលើព្រះគ្រិស្តតែប៉ុណ្ណោះ។ ការរក្សាក្រឹត្យវិន័យនឹងមិនសង្គ្រោះយើងឡើយតែការទុកចិត្តលើការសំរេចរបស់ព្រះគ្រីស្តលើឈើឆ្កាង នឹងសង្គ្រោះសំរាប់អ្នកណាដែលចូលមករកទ្រង់។

**ខព្រះគម្ពីរចងចាំ:** *កាឡាទី ៣:១៩* បើដូច្នេះតើវិន័យមានប្រយោជន៍អ្វី? ព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យមកដើម្បីបង្ហាញអំពើទុច្ចរិតរបស់មនុស្ស ហើយវិន័យនេះមានខ្លឹមសាររហូតទាល់តែពូជពង្ស ដែលត្រូវទទួលមរតកតាមព្រះបន្ទូលសន្យាយាងមកដល់។ ពួកទេវទូតបាននាំយកវិន័យមកតាមរយៈមនុស្សម្នាក់ដែលជួយធ្វើអន្តរាគមន៍ ។

## <u>**សំនួររត្រិះរិះ មេរៀនទី១១**</u>

នៅពេលអ៊ីស្រាអែលធ្វើដំណើរឆ្លងកាត់ពីអេស៊ីបទៅកាន់ទឹកដីកាណាន ព្រះជាម្ចាស់ល្បងលពួកគេដើម្បីបង្ហាញថា ប្រសិនបើពួកគេដើរនៅក្នុងផ្លូវរបស់ទ្រង់ ហើយតើពួកគេរៀបចំខ្លួនរួច ដើម្បីគ្រប់គ្រងទឹកដីសន្យា។ យោងទៅតាមខព្រះគម្ពីរខាងក្រោម ចូរបំពេញចន្លោះដើម្បីបង្ហាញ ពីការល្បងល និងអ្វីដែលព្រះជាម្ចាស់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់គេ។

១. *សេរីភាព ១៥:២២-២៥* នៅប្រភពទឹកម៉ារ៉ា : ទឹកគឺ................................................................................................................................។ ព្រះជាម្ចាស់ប្រាប់លោកម៉ូសេអោយបោះ..................................................................................................................ទៅក្នុងទឹក ហើយទឹកក្លាយទៅជា..............................................................................................................................។

២. *សេរីភាព ១៦:៣-៥* នៅវាលរហោស្ថានស៊ីនប្រជាជនគិតថា ពួកគេនឹងស្លាប់ដោយសារ.................................................................... ប៉ុន្តែព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលមកថាទ្រង់នឹងប្រទាន....................................................មកពី..................................................................................។

៣. *សេរីភាព ១៧:១-៦* នៅរេភីឌីមពួកគេមានការ.....................................................................ពីព្រោះនៅទីនោះគ្មាន...................................................................សោះឡើយ ប៉ុន្តែព្រះជាម្ចាស់ប្រាប់លោកម៉ូសេអោយវាយលើ...........................................នោះ.......................................នឹងចេញមក។

៤. មានតែមនុស្សម្នាក់ដែលអាចបំពេញនូវការស្រេកឃ្លានផ្ទៃកព្រលឹងវិញ្ញាណរបស់យើង។ ដោយយោងទៅតាមខព្រះគម្ពីរ ចូរសរសេរឈ្មោះម្នាក់នោះនៅក្នុងចន្លោះ។ *យ៉ូហាន ៦:៣៥*...........................................................................................យ៉ូហាន៤:១៤.......................................................................។

៥. តើប្រជាជនអ៊ីស្រាអែលនៅឯណានៅពេលដែលព្រះជាម្ចាស់ផ្ដល់ នូវការល្បងលរដ៏ធំ បំផុតនោះ? *សេរីភាព ១៩:១-២*...........................................................................................។

ខព្រះគម្ពីរយោងខាងក្រោមនេះបង្ហាញថា ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យដល់ពួកគេ។ ចូរបំពេញល្បះខាងក្រោម:

៦. *កាឡាទី ៣:១៩* ព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យមកពីព្រោះដើម្បី ....................................................................................................................................................។

៧. *រ៉ូម ៣:១៩* ព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យមកពីព្រោះដើម្បី....................................................................................................................................................។

៨. *រ៉ូម ៣:១៩* ព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យមកពីព្រោះដើម្បីអោយពិភពលោក....................................................................................................................................................។

៩. ចូរគូររូបភាពបង្ហាញពីការថ្វាយបង្គំរបស់អ៊ីស្រាអែលដែលជាការបំផ្លាញក្រឹត្យវិន័យ មុនដំបូងបង្អស់ សេរីភាព ៣២:៤។

| |
|---|
| |

១០. សរសេរខគម្ពីរចងចាំ កាឡាទី ៣:១៩...........................................................................

.......................................................................................................................................

....................................................................................................................... ...............។

**មេរៀនទី១២ :** **ការស្ថិតនៅក្រោមវិន័យលើផ្លូវសន្យា**

**ជំរឿនប្រជាជន ៨-១៤**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញថាមានអង្គមួយដែលផ្សះផ្សារវាងមនុស្ស និងព្រះ**

តើអ្នកខ្លាចមន្ត្រីប៉ូលីសដែរទេ ពេលគាត់ដើរកាត់ផ្ទះរបស់អ្នក? មិនខ្លាចទេបើសិនយើងធ្វើកិច្ចការត្រឹមត្រូវ។ តើអ្នករំពឹងថាគាត់នឹងមកនៅពេលអ្នកធ្វើអ្វីប្រឆាំងនឹងច្បាប់ដែរទេ? ក្មេងប្រុសម្នាក់ត្រូវបានចាប់ពីបទលួចកង់។ មន្ត្រីប៉ូលីសបាននឹងកំពុងយកគាត់ទៅកាន់ប៉ុស្តិ៍ ប៉ុន្តែនៅពេលនេះម្តាយក្មេងមកដល់។ ឪពុកក្មេងអង្វរទៅកាន់មន្ត្រីប៉ូលីស ដើម្បីសុំដោះលែងកូន ហើយសន្យាថាគាត់ដាក់វិន័យក្មេងនោះ។ ដូច្នេះក្មេងប្រុសអាចគេចផុតពីការទៅកាន់តុលាការ រឺគុក។ ឪពុកក្មេងប្រុសបានក្លាយជាអ្នកផ្សះផ្សារដែលគាត់នៅចន្លោះក្មេងប្រុសហើយនឹងទោសនៃច្បាប់។

យើងនឹងឃើញនៅពេលយើងធ្វើដំណើរលើមាគ៌ានៃជីវិតអ៊ីស្រាអែលក៏ត្រូវការអ្នកផ្សះផ្សារដែរ។ មានការដាក់ទោសនៅពេលពាក់ព័ន្ធជាមួយការបំផ្លាញច្បាប់ ព្រះពរដ៏អស្ចារ្យនឹងមានដល់អ៊ីស្រាអែលពេលពួកគេថែរក្សាក្រឹត្យវិន័យ ប៉ុន្តែនឹងមានបណ្តាសារជាច្រើននៅពេលអ៊ីស្រាអែលមិនស្តាប់បង្គាប់ *ទុតិយកថា១៨។*

បន្ទាប់ពីការប្រទានក្រឹត្យវិន័យនៅ*ភ្នំស៊ីណៃ* ព្រះជាម្ចាស់ផ្តល់ការណែនាំពីបល្ល័ង្កនៃព្រះគុណជាទីអាថិកំបាំងនៃរោងឧបោសថជាកន្លែងជួបជុំសំរាប់ការថ្វាយយញ្ញបូជា។ ព្រះទ្រង់ប្រាប់ពួកគេពីហ្វូងមនុស្សដ៏អស្ចារ្យនៃអ៊ីស្រាអែល *ជំរឿនប្រជាជន៧:៨៩-១០:២៦*។ ក្រុមព្យាការីជាអ្នកនាំទូវផ្នែកនៃរោងឧបោសថ ពេលដែលត្រែប្រាក់បន្លឺសំលេងហៅប្រជាជនអោយធ្វើព្យុះហយាត្រា។ *ប្រជាជនអ៊ីស្រាអែលត្រូវបានដឹកនាំពេលថ្ងៃដោយពពក និងពេលយប់ដោយដុំភ្លើង*។

ពួកគេចេញដំណើរពីភ្នំស៊ីណៃទៅកាន់វាលរហោស្ថានប៉ារ៉ន *ជំរឿនប្រជាជន ១០:១១-៣៦*។ នៅពេលពួកគេមកដល់ *តាបេរ៉ា* ពួកគេរអ៊ូរទាំភ្លើងរបស់ព្រះជាម្ចាស់ធ្លាក់មកឆេះជាយជំរុំរបស់ពួកគេ។ ពេលលោកម៉ូសេអធិស្ឋានភ្លើងក៏រលត់ *ជំរឿនប្រជាជន ១១:១-៣*។ លោកម៉ូសេជាអ្នករំដោះអ៊ីស្រាអែលពីព្រះពិរោធរបស់ព្រះជាម្ចាស់។

ពេលពួកគេមកដល់ហាសេរ៉ូត អ្នកស្រីមេរីយ៉ាន និងលោកអារ៉ុនច្រណែនជំទាស់ជាមួយលោកម៉ូសេ។ ដោយសារតែពួកគេរអ៊ូរទាំពីលោកម៉ូសេ អ្នកស្រីមេរីយ៉ានក៏កើតឃ្លង់។ លោកម៉ូសេអធិដ្ឋានអោយអ្នកស្រីមេរីយ៉ាន ហើយគាត់ក៏បានជា។ លោកម៉ូសេគឺជាអ្នករំដោះម្តង ទៀតហើយ *ជំរឿនប្រជាជន ១២:១-១៦*។

អ៊ីស្រាអែលបោះជំរុំនៅ *កាដែស* លោកម៉ូសេចាត់អ្នកស៊ើបការណ៍ទៅក្នុងទឹកដីសន្យា១២នាក់ ម្នាក់ពីកុលសម្ព័ន្ធនីមួយៗ *ជំរឿនប្រជាជន ១៣*។ បន្ទាប់ពី៤០ថ្ងៃ ពួកគេនាំយកនូវសេចក្តីរាយការណ៍មកវិញ។ ពួកគេបង្ហាញពីផ្លែឈើហើយនិយាយថា "ស្រុកនោះពិតជាសម្បូរហូរហៀរណាស់ " ប៉ុន្តែពួកគេក៏និយាយផងដែរថាប្រជាជនទីនោះខ្លាំង និងមានកំពែងរឹងមាំផង។ ពួកគេថាកូនចៅលោកអាណាក់មានមាឌធំសំបើមរស់នៅទីនោះ។ លោកកាលែប និងយ៉ូស៊ូអានិយាយថា "ចូរយើងនាំគ្នាទៅដណ្តើមយកស្រុកនោះ"។ អ្នកស៊ើបការណ៍១០នាក់ទៀតនិយាយថាយើងមិនអាចប្រឆាំងនឹងមនុស្សខ្លាំងជាងយើងឡើយ"។ ពួកប្រជាជនមានការត្អូញត្អែរ និងរអ៊ូរទាំម្តងទៀត *ជំរឿនប្រជាជន ១៤:១-៣៩*។ ពួកគេស្រែក

ប្រឆាំងលោកម៉ូសេ និងព្រះជាម្ចាស់។ ពួកគេគំរាមថានឹងរើសមេដឹកនាំត្រលប់ទៅអេស៊ីបវិញ។ លោកម៉ូសេ និងលោកអរ៉ុនក្រាបមុខដល់ដីពីមុខសហគមន៍។ ពួកប្រជាជនបំរុងនឹងសំលាប់លោក។

សិរីរុងរឿងនៃព្រះជាម្ចាស់លេចឡើងក្នុងរោងឧបោសថនៅមុខប្រជាជនអ៊ីស្រាអែល។ ទ្រង់មានព្រះបន្ទូលទៅកាន់លោកម៉ូសេថា "តើប្រជាជននេះនៅតែមើលងាយយើងដល់កាលណា?" "តើពួកគេនៅតែមិនជឿលើយើងដល់កាលណាទៀត?...យើងនឹងប្រហារពួកគេដោយជំងឺអាសន្នរោគ យើងនឹងលុបបំបាត់ពួកគេ យើងនឹងធ្វើអោយអ្នកទៅជាប្រជាជាតិមួយដ៏ធំ និងមានកំលាំងជាងពួកនេះ" *ជំរឿនប្រជាជន ១៤:១១-១២*។

លោកម៉ូសេទូលអង្វរសំរាប់ប្រជាជន ហើយព្រះជាម្ចាស់ឆ្លើយតប ហើយមានព្រះបន្ទូលថា "សំរាប់កាលែប និងយ៉ូស៊ូអាអាចចូលទឹកដីសន្យាបាន តែអ្នកឯទៀតត្រូវវង្វេងក្នុងវាលរហោស្ថាន៤០ឆ្នាំ។ អ្នកស៊ើបការណ៍ដែលគ្មានជំនឿព្រះជាម្ចាស់អោយគេស្លាប់ដោយសារគ្រោះកាច។

អ៊ីស្រាអែលសមនឹងត្រូវបំផ្លាញដោយសារការគ្មានជំនឿ និងអំពើបាបរបស់គេ។ ដោយយោងទៅតាមព្រះគម្ពីរប្រជាជនទាំងអស់សមនឹងត្រូវបំផ្លាញគ្រប់គ្នាមានបាបលទ្ធផលនៃអំពើបាបគឺសេចក្តីស្លាប់ *រ៉ូម២:២៣ រ៉ូម៦:២៣* ។ ព្រះជាម្ចាស់ព្រះពិរោធជាមួយមនុស្សទុច្ចរិតជារៀងរាល់ថ្ងៃ *ទំនុកតំកើង ៧:១១* ប៉ុន្តែនៅពេលយើងនៅជាមនុស្សបាបព្រះគ្រីស្តបានសុគតសំរាប់យើង *រ៉ូម៥:៨* ឥលូវទ្រង់កំពុងអធិដ្ឋានសំរាប់យើង *ហេព្រើ ៧:២៥*។ ព្រះយេស៊ូគឺជាអ្នកផ្សះផ្សាររវាងយើង និងព្រះបិតា ព្រះអង្គនៅចន្លោះយើង និងព្រះពិរោធរបស់ព្រះជាម្ចាស់ចំពោះអំពើបាបយើង។ ឧទាហរណ៍ម៉ារីមិនមែនជាអ្នកផ្សះផ្សាររវាងព្រះនឹងយើងទេ ពីព្រោះមានតែអ្នកផ្សះផ្សារមួយប៉ុណ្ណោះគឺព្រះយេស៊ូគ្រីស្ត។ ព្រះគ្រីស្តដកការពិន័យដែលយើងសមនឹងទទួលលើឈើឆ្កាង ហើយនៅពេលយើងទទួលទ្រង់ជាព្រះសង្គ្រោះ ព្រះជាម្ចាស់ឃើញយើងនៅក្នុងព្រះគ្រីស្ត។

យើងបានរៀនពីលោកម៉ូសេដើរតួជារូបភាពនៃព្រះគ្រីស្តមុនពេលដែលព្រះគ្រីស្តយាងមក។ មានតែព្រះគ្រីស្តដែលជាអ្នកផ្សះផ្សាររវាងព្រះជាម្ចាស់ និងមនុស្ស ។ តើទ្រង់គឺជាអ្នកផ្សះផ្សាររបស់អ្នកហើយរឺនៅនៅថ្ងៃនេះ?

**ខព្រះគម្ពីរចងចាំ** : *១ធីម៉ូថេ ២:៥-៦*

" ដ្បិតមានតែព្រះជាម្ចាស់តែមួយ ជាស្ពានមេត្រីមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក គឺព្រះគ្រីស្តយេស៊ូដែលជាមនុស្ស។ ព្រះអង្គបានបូជាព្រះជន្ម ដើម្បីលោះមនុស្សទាំងអស់ នេះជាសក្ខីភាពមួយ ដែលព្រះអង្គបានបង្ហាញនៅពេលកំណត់ "។

## <u>សំនួររត្រិះរិះ មេរៀនទី១២</u>

អ៊ីស្រាអែលធ្វើដំណើរបន្ទាប់ពីការទទួលក្រឹត្យវិន័យ ប៉ុន្តែយើងឃើញថាមានការដាក់ទោសពីការបំផ្លាញក្រឹត្យវិន័យ ចូរបំពេញចន្លោះខាងក្រោមដោយយោងទៅតាមការណែនាំ។

| ការប្រព្រឹត្តអំពើបាប | ការដាក់ទោសនៃការអំពើបាប |
|---|---|
| ១. *ជំរឿនប្រជាជន ១១:១* | *ជំរឿនប្រជាជន ១១:១* |

......................................... ..................................................

២. *ជំរឿនប្រជាជន ១២:១* *ជំរឿនប្រជាជន ១២:១០*

............................................ ..................................................

៣. *ជំរឿនប្រជាជន ១៤:១១* *ជំរឿនប្រជាជន ១៤:១២*

.......................................... ..................................................

៤. តើលោកម៉ូសេធ្វើអ្វីគ្រប់ទាំងស្ថានភាពនៅក្នុងខព្រះគម្ពីរនេះ *ជំរឿនប្រជាជន ១១: ២ ជំរឿនប្រជាជន ១២:១៣ ជំរឿនប្រជាជន ១៤: ១៩*..............................................................................................................

........................................................................................................................................... ។

៥. លោកម៉ូសេជាអ្នកជួយសុំទោសរឺអ្នកសំរុះសំរួលរវាងព្រះពិរោធរបស់ព្រះជាម្ចាស់ និងមនុស្សបាប។ តើព្រះដែលមានព្រះជន្មគង់នៅ ហើយតែងតែអធិដ្ឋានសុំទោសអោយយើងមាននាមអ្វី?..........................................................

............................................................................................................................................. ។

៦. បំពេញចន្លោះខាងក្រោមដើម្បីបង្ហាញថា ហេតុអ្វីអ្នកដែលទទួលការសង្គ្រោះត្រូវការអោយព្រះយេស៊ូអធិស្ឋានសំរាប់ពួកគេ។ *១យ៉ូហាន ២:១* ម្នាលកូនចៅទាំងឡាយអើយ ខ្ញុំសរសេរសេចក្តីទាំងនេះមកអ្នករាល់គ្នាដើម្បីកុំអោយប្រព្រឹត្ត ..................................................។ ប៉ុន្តែប្រសិន បើមាននរណាម្នាក់ ប្រព្រឹត្ត..................................................យើងមានព្រះដ៏ជួយការពារមួយព្រះអង្គគង់នៅទល់មុខព្រះបិតាគឺព្រះយេស៊ូគ្រិស្តដ៏សុចរិត។

៧. ហេតុអ្វីមនុស្សលោកទាំងអស់សមនឹងទទួលការពិន័យ? *រ៉ូម ៣ : ២៣* ..........................................

............................................................................................................................................. ។

៨.តើព្រះគ្រិស្តធ្វើអ្វីនៅពេលយើងនៅជាមនុស្សបាបនៅឡើយ? *រ៉ូម៥:៨*..............................................

.......................................................................................................................................... ។

៩. បំពេញចន្លោះខាងក្រោមដើម្បីបង្ហាញអំពីការងារដ៏អស្ចារ្យរបស់ព្រះយេស៊ូគ្រិស្តជា ព្រះសង្គ្រោះនៃយើង។

➤ សំរាប់អ្នកគ្មានជំនឿ: *១ធីម៉ូថេ១:១៥* ព្រះយេស៊ូគ្រិស្តយាងមកលើផែនដី ដើម្បី ..................................

.......................................................................................................................មនុស្សបាប។

➤ សំរាប់អ្នកមានជំនឿ: *ហេប្រឺ៧:២៥* ព្រះអង្គអាចសង្គ្រោះយើងជាស្ថាពរព្រោះទ្រង់មានព្រះជន្មជារៀងរហូតដើម្បី..........................................................................................................................សំរាប់យើង។

១០.សរសេរខគម្ពីរចងចាំ: *១ធីម៉ូថេ២:៥*

..............................................................................................................................................

..............................................................................................................................................

.................................................................................. ។

**មេរៀនទី១៣ :** **ការដឹកនាំរបស់លោកយ៉ូស្វេនៅក្នុងទឹកដីសន្យា**

**យ៉ូស្វេ ១-១១**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញពីទ្រព្យសម្បត្តិនៃព្រះពររបស់ព្រះជាម្ចាស់ពឹងផ្អែកទៅលើការប្រកាន់ភ្ជាប់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់**

ដាវហើយនិងខែលរបស់ពួកយើង យើងនឹងប្រើប្រាស់ជាឧបករណ៍ប្រយុទ្ធក្នុងសង្គ្រាម នៅពេលយើងធ្វើដំណើរនៅលើផ្លូវសន្យាដែរ។ អ្នកនឹងរៀនពីការអាចិកំបាំងនៃរបៀបទទួលនូវការប្រទានពររបស់ជីវិតជាគ្រីស្ទបរិស័ទ្ធ។

លោកម៉ូសេជាអ្នកបំរើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ទទួលមរណៈភាពផុតទៅហើយ ព្រះជាម្ចាស់បានបញ្ចុះសពគាត់។ ឥឡូវនេះយើងមានអ្នកដឹកនាំថ្មីមួយរូបគឺលោកយ៉ូស្វេគាត់ត្រូវបាន តែងតាំងទៅជាអ្នកដឹកនាំប្រជាជនអ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យា។ លោកយ៉ូស្វេត្រូវបានតែងតាំងជាអ្នកដឹកនាំពីព្រោះគាត់បានបង្ហាញពីសេចក្តីជំនឿរបស់គាត់នៅក្នុងស្រុក *កាដាស* ស្បៀរនៅពេលដែលអ្នកយកការណ៍ដែលគ្មានជំនឿមានការភ័យខ្លាចនឹងចូលទៅនៅក្នុងទឹកដីសន្យា។ នៅកំឡុងពេល40ឆ្នាំក្នុងវាលរហោស្ថានមនុស្ស ដែលគ្មានជំនឿជាច្រើនបានស្លាប់ ហើយលោកយ៉ូស្វេត្រូវបានដឹកនាំមនុស្សជំនាន់ថ្មីទៅច្បាំងដណ្តើមនៅក្នុងទឹកដីសន្យា។ ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកយ៉ូស្វេ និងបានបង្កើតសេចក្តីសន្យាយ៉ាងច្បាស់លាស់ជាមួយគាត់ថាៈ "គ្រប់កន្លែងណាដែលអ្នកឈានជើងជាន់យើងអោយអ្នកទាំងអស់" *យ៉ូស្វេ១:៣* "យើងនឹងនៅជាមួយអ្នកដូចយើងបាននៅជាមួយម៉ូសេដែរ " *យ៉ូស្វេ ១:៥* "អ្នកនឹងទទួលជ័យជំនះ ប្រសិនបើព្រះបន្ទូលនៅក្នុងព្រះគម្ពីរនេះមិនដាច់ចេញមកពីមាត់របស់អ្នក " *យ៉ូស្វេ ១:៧-៩*។

ជ័យជំនះរបស់លោកយ៉ូស្វេបានផ្អែកលើសេចក្តីជំនឿរបស់គាត់ និងការគោរពតាមគម្ពីរវិន័យ។ ប្រជាជនអ៊ីស្រាអែលបានមកជិតទីក្រុងល្បីល្បាញមួយនៅទីក្រុងយេរីខូ។ លោកយ៉ូស្វេបានអោយអ្នកយកការណ៍ពីរនាក់ទៅមុនអ្នកយកការណ៍បានមកដល់ផ្ទះរបស់នាងរ៉ាហាប ដែលជាអ្នកសង្គ្រោះពួកគេពីសេចក្តីស្លាប់។ ពួកគេបានសន្យាជាមួយនាងថានឹងសង្គ្រោះនាងនៅពេលដែលទីក្រុងត្រូវបំផ្លាញ ប្រសិនបើនាងចងខ្សែពណ៌ក្រហមនៅមាត់បង្អួច *យ៉ូស្វេ ២:១៨ -២១* ។

បន្ទាប់មកប្រជាជនអ៊ីស្រាអែលបានឆ្លងកាត់ទន្លេ*យ័រដាន់* ព្រះជាម្ចាស់ក៏បានធ្វើអោយទឹកប្រមូលផ្តុំគ្នានៅនឹងថ្កល់ធ្វើផ្លូវសំរាប់ពួកគេឆ្លងកាត់ *យ៉ូស្វេ ៣:១៧*។ បន្ទាប់មកនៅក្នុង ជំពូកទី៦នៃកណ្ឌគម្ពីរយ៉ូស្វេប្រជាជនអ៊ីស្រាអែលត្រូវបានផ្តល់ការណែនាំសំរាប់ការច្បាំងដណ្តើមយកទីក្រុង*យេរីខូ*។ ពួកគេត្រូវដើរព័ទ្ធជុំវិញទីក្រុងដូចជាក្បួនដង្ហែ៦ថ្ងៃ។ នៅថ្ងៃទី៧ក្រុមបូជាចារ្យត្រូវផ្លុំត្រែ ស្នែងចៀម ហើយប្រជាជននាំគ្នាស្រែកអោយខ្លាំងៗពេលនោះកំពែងក្រុងក៏រលំចុះនៅនឹងកន្លែងតែម្តង *យ៉ូស្វេ ៦: ២០*។

តើវាហាក់ដូចជាមិនចំឡែកទេ រឺនូវជ័យជំនះនៃការប្រយុទ្ធនេះ? ប្រជាជននៃទីក្រុង*យេរីខូ* យាមយ៉ាងតឹងតែងនៅពេលដែលប្រជាជនអ៊ីស្រាអែលកំពុងដើរព័ទ្ធជុំវិញទីក្រុងទាំងនោះ ដោយឥតនិយាយស្តីអ្វីសោះ។ ព្រះជាម្ចាស់ចង់អោយយើងរៀនពីផ្លូវរបស់ព្រះអង្គគឺមិនមែនផ្លូវរបស់ពួកយើងទេ។ ព្រះអង្គចង់អោយអ្វីៗកើតឡើងដូចនេះហើយទ្រង់នឹងទទួលសិរីរុងរឿងគឺមិនមែនសិរីរុងរឿងរបស់មនុស្សទេ។ យើងនឹងសួរសំនួរខ្លះទៅអ្នករាល់គ្នា :

តើអ្វីដែលនាំអោយកំពែងទីក្រុងយេរីខូត្រូវរលំចុះ? សេចក្តីជំនឿក្នុងព្រះជាម្ចាស់ និងការស្តាប់បង្គាប់បញ្ជា រឺក៏ព្រះបន្ទូល *ហេប្រឺ ១១: ៣០*។

តើនាងរ៉ាហាបទទួលការសង្គ្រោះដោយសារអ្វី? សេចក្តីជំនឿក្នុងព្រះជាម្ចាស់ និងការស្តាប់ព្រះបន្ទូលរបស់ទ្រង់តាមរយៈអ្នកយកការណ៍ *ហេប្រឺ ១១:៣១*។

តើអ្វីដែលនាំអោយលោកយ៉ូស្វេទទួលជ័យជំនះ? សេចក្តីជំនឿក្នុងព្រះជាម្ចាស់ជាព្រះដឹកនាំយើងដែលយើងមើលមិនឃើញ។ ហើយគាត់បង្ហាញភស្តុតាងនៃជំនឿរបស់គាត់តាមរយៈការគោរពបញ្ជាព្រះជាម្ចាស់។ ព្រះបន្ទូលស្ថិតនៅជាប់មាត់របស់គាត់គាត់បានទុកចិត្ត និងគោរពលើអ្វីមួយដែលដូចជាចំឡែក។

តើអ្វីដែលនឹងនាំជ័យជំនះមកពួកយើងជាអ្នករស់នៅក្នុងអាកាសយានដ្ឋាននៃព្រះគុណ? យើងក៏មាន *"សង្គ្រាម"* ដែលត្រូវប្រយុទ្ធ និង*"ទឹកដីសន្យា"* សំរាប់ប្រកាសនៅពេលយើងធ្វើដំណើរនៅលើ *"មាគ៌ានៃជីវិត"*។ យើងមានកិច្ចការខ្លះៗដែលត្រូវកត់សំគាល់ពីការប្រយុទ្ធរបស់យើង៖

១. *"ទឹកដីសន្យ"* របស់យើងជាការប្រទានព្រះពរគ្រប់បែបយ៉ាងផ្នែកព្រលឹងវិញ្ញាណពីស្ថានបរមសុខ *អេភេសូ ៦:៦-៧*។

២. សត្រូវរបស់យើងជាគោលការណ៍ និងអំណាចរបស់លោកិយងងឹតនៅក្នុងស្ថានបរមសុខ *អេភេសូ៦:១១ -១២*។

៣. ជ័យជំនះរបស់ពួកយើងគឺអាចសម្រេចតាមរយៈជំនឿលើពាក្យទាំងប៉ុន្មាននៃមេដឹកនាំយើង គឺព្រះយេស៊ូគ្រិស្ត។ យើងបង្ហាញភស្តុតាងនៃជំនឿរបស់ពួកយើងដោយមានសកម្មភាពពឹងផ្អែកទៅលើព្រះបន្ទូលរបស់ទ្រង់។ ព្រះជាម្ចាស់ទ្រង់បានសន្យានូវគ្រប់កិច្ចការដែលជាបំណងចិត្តនឹង បង្កើតអោយមានសេចក្តីអំណរនិងមានជ័យជំនះនៅក្នុងជីវិតជាគ្រីស្តបរិស័ទ្ធ។ នៅក្នុងព្រះគ្រិស្តយើងមានផលផ្លែខាងព្រះវិញ្ញាណដូចជា: សេចក្តីអំណរ សន្តិភាព ប្រាជ្ញា អំណាច។ល។ សត្រូវរបស់យើងបានព្យាយាមបញ្ចៀសយើងចេញពីការទទួលនូវអ្វីៗទាំងនោះ ប៉ុន្តែបើយើងតាមលោក *យ៉ូស្វេ* និងទូលសុំព្រះពរទាំងនោះព្រះជាម្ចាស់ប្រាកដជាប្រគល់អោយយើងមិនខាន។

គួរអោយសោកស្តាយបន្ទាប់ពីការប្រយុទ្ធដណ្តើមយកទីក្រុង*យេរីខូ* មកប្រជាជនអ៊ីស្រាអែលមិនដែលច្បាំងយកទឹកដីកាណានទេ ពីព្រោះពួកគេមិនបានគោរពកោតខ្លាចព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពួកគេបានចូលទៅក្នុងទឹកដីនោះទោះបីជាយ៉ាងណាគេបែងចែកទឹកដីដូចជាការកំណត់របស់ព្រះជាម្ចាស់។

*តើសព្វថ្ងៃអ្នកមិនបានទទួលការសង្គ្រោះទេរឺ?* ប្រសិនជាដូច្នេះអ្នកនឹងដូចជានាង*រ៉ាហាប* រស់នៅកន្លែងមួយដែលមានតែការបំផ្លាញ ប៉ុន្តែអ្នកអាចទទួលការសង្គ្រោះដោយសារជំនឿដូចនាងរ៉ាហាប។ អ្នកបង្ហាញជំនឿរបស់អ្នកដោយសារការទទួលសារភាពកំហុសដែលព្រះគ្រិស្តគឺជាព្រះសង្គ្រោះរបស់អ្នក។ បន្ទាប់មកអ្នកអាចនាំអ្នកឯទៀតនៃក្រុមគ្រួសាររបស់អ្នកចូលទៅក្នុងកន្លែងដ៏សុខសាន្ត នៅក្នុងព្រះគ្រីស្តដូចនាងរ៉ាហាបដែលបាននាំក្រុមគ្រួសាររបស់នាងចូលទៅក្នុងផ្ទះនិងជួយពួកគេពីសេចក្តីវិនាសអន្តរាយ។

**ខព្រះគម្ពីរចងចាំ:** យ៉ូស្វេ ១:៩ តើយើងមិនបានបង្គាប់អ្នកទេរឺថា "ចូរមានកំលាំង និងចិត្តក្លាហានឡើង! កុំភ័យខ្លាច កុំតក់ស្លុត អោយសោះដ្បិតព្រះអម្ចាស់ជាព្រះរបស់អ្នកគង់នៅ ជាមួយអ្នកគ្រប់ទីកន្លែងដែលអ្នកទៅ។

## សំនួររត្រិះរិះ មេរៀនទី១៣

១. តើអ្នកណាជាអ្នកដឹកនាំអ៊ីស្រាអែលក្រោយពីលោកម៉ូសេស្លាប់ទៅ? *យ៉ូស្វេ ១:១-២* ............................ ........................................................................................។

២. តើហេតុអ្វីបានជាគាត់ត្រូវបានគេតែងតាំង? ទុតិយកថា ៣៤:៩........................................................ ........................................................................................................។

៣. តើការសន្យាបីយ៉ាងរបស់ព្រះជាម្ចាស់ជាមួយលោកយ៉ូស្វេមានអ្វីខ្លះ? *យ៉ូស្វេ១:៣*................................... ..............................................................។ *យ៉ូស្វេ១:៥*.................................................................. .......................................។ *យ៉ូស្វេ១:៨*.........................................................................................។

ចូរជ្រើសរើសពាក្យដែលត្រឹមត្រូវដើម្បីយកទៅបំពេញប្រយោគនីមួយៗ :

៤. ជ័យជំនះរបស់លោកយ៉ូស្វេត្រូវបានផ្អែកលើ ( ការខិតខំធ្វើការងារ/ ការគោរពកោតខ្លាច /ការរៀបចំល្អ ) *យ៉ូស្វេ ១:៨* ។

៥. វាគឺបានដោយសារ: ( ការអធិស្ឋាន ការប្រយុទ្ធ សេចក្តីជំនឿ ការរុញច្រាន ) ដែលធ្វើ អោយក្រុងយេរីខូត្រូវរលំ *ហេប្រឺ ១១:៣០*។

៦. នាងរ៉ាហាបបានទទួលការសង្គ្រោះដោយសារនាង :( ធ្លាប់ធ្វើល្អ ធ្លាប់ធ្វើអាក្រក់ គោរពវិន័យ មានជំនឿ) *ហេប្រឺ ១១:៣១*។

បទពិសោធន៍របស់អស់អ្នកណាដែលរស់នៅសព្វថ្ងៃក្នុងសម័យនៃព្រះគុណ គឺដូចជាបទពិសោធន៍របស់ជនជាតិអ៊ីស្រាអែលដែរ។ ចូរអានព្រះគម្ពីរ និងបំពេញចន្លោះខាងក្រោម:

៧. ជនជាតិអ៊ីស្រាអែលបានទទួលព្រះពរជាច្រើន ដែលជាព្រះបន្ទូលសន្យានៅក្នុងទឹកដីកាណានហើយពួកយើងក៏បានទទួលព្រះពរជាច្រើន ដែលជាព្រះបន្ទូលសន្យានៅក្នុង........................................................................ ........................................................................................*អេភេសូ១:៣*។

៨. សត្រូវរបស់ជនជាតិអ៊ីស្រាអែលគឺអស់អ្នកដែលមិនគោរពព្រះជាម្ចាស់នៅក្នុងទឹកដីកាណាន រីឯសត្រូវរបស់យើង ..........................................................................នៅក្នុងស្ថានបរមសុខ *អេភេសូ៦:១២*។

៩. ជ័យជំនះរបស់ជនជាតិអ៊ីស្រាអែលគឺផ្អែកលើសេចក្តីជំនឿ និងការគោរពរីឯជ័យជំនះរបស់ពួកយើងផ្អែកលើ .................................................................................................................*អេភេសូ៦:១៣.១៧*។

១០.សរសេរខព្រះគម្ពីរចងចាំ យ៉ូស្វេ ១:៩.............................................................................................. ..................................................................................................................................... .....................................................................................................................................។

**មេរៀនទី១៤ : មកពីផ្លូវសន្យាក្លាយទៅជាផ្លូវរាជាណាចក្រ**

**១សាំយូអែល៨ - ២សាំយូអែល ៦**

**គំនិតសំខាន់ : បង្ហាញពីភាពល្ងង់ខ្លៅផ្ដល់របស់ជីវិតអ្នកគ្រប់គ្រងម្នាក់**

"សូមអោយស្ដេចពួកយើងមួយអង្គមក!" នេះជាសំលេងរបស់ប្រជាជន " ស្ដេចមួយអង្គជាអ្នកគ្រប់គ្រងយើងដូចជាជនជាតិដទៃដែរ "។ ជាមួយនឹងការទាមទារនេះប្រជាជនអ៊ីស្រាអែលបានបដិសេធ *ព្រះជាម្ចាស់* ជាស្ដេចរបស់គេ និងជ្រើសរើសបុរសម្នាក់សំរាប់គ្រប់គ្រងពួកគេ។ ពួកគេចង់បានស្ដេចមួយអង្គដែលគេអាចឃើញ។ ពួកគេឡើយហាត់ក្នុងការដើរដោយជំនឿ និងលើសេចក្ដីសន្យារបស់ព្រះជាម្ចាស់។ ភាពល្ងង់ខ្លៅរបស់ជនជាតិអ៊ីស្រាអែល *១សាំយូអែល១០:១៩* ពួកគេមិនបានយល់ពីទុក្ខព្រួយដែលនាំមកលើពួកគេតាមរយៈការស្នើរសុំអោយមានបុរសម្នាក់មកគ្រប់គ្រងលើពួកគេទេ។

តើអ្នកនៅចាំខគម្ពីររបស់ពួកយើងពីផ្លូវនៃជីវិត និងផ្លូវនៃសេចក្ដីស្លាប់ទេ? យើងមានឧទាហរណ៍ជាច្រើនសំរាប់អស់អ្នកណាដែលជ្រើសរើសផ្លូវណាមួយ រឺផ្លូវដទៃទៀត។ សព្វថ្ងៃនេះយើងនឹងបានលឺអំពីស្ដេចពីរអង្គ។ ស្ដេចទីមួយគឺស្ដេចណាដែលជ្រើសរើសផ្លូវនៃសេចក្ដីស្លាប់ និងស្ដេចទីពីរគឺស្ដេចណាដែលជ្រើសរើសផ្លូវនៃជីវិតអស់កល្បជានិច្ច។

ប្រជាជនអ៊ីស្រាអែលបានរស់នៅក្នុងទឹកដីសន្យា(កាណាន) ប្រហែលជា *៣៥០* ឆ្នាំ និង ក្នុងកំឡុងពេលនោះពួកគេបានប្រព្រឹត្តអំពើបាបយ៉ាងច្រើនដូចជាបំផ្លាញក្រឹត្យវិន័យ និងគោរពព្រះក្លែងក្លាយ។ ព្រះជាម្ចាស់បានលើកមនុស្សឡើងជាចៅក្រមកាត់ក្ដីអោយអស់អ្នកណាដែលមានបញ្ហានៅក្នុងស្រុកអ៊ីស្រាអែល។ ជាអ្នកបានប្រយុទ្ធ និងបានរំដោះប្រជាជាតិជាភាពទាសករពីសត្រូវរបស់គេដែលបានជិះជាន់ពួកគេគ្រប់សារពើ យើងអាននៅកណ្ឌគម្ពីរ *វិរបុរស*។ នៅក្នុងការហៅបុរសម្នាក់អោយក្លាយទៅជាស្ដេចគ្រប់គ្រងពួកគេប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបយ៉ាងធំ *១សាំយូអែល ៨*។

ស្ដេចដំបូងបង្អស់ដែលត្រូវបានជ្រើសរើសគឺឈ្មោះ*សូល* គាត់មានរូបរាងសង្ហា ហើយខ្ពស់ដែលជាទីគាប់ភ្នែករបស់ប្រជាជន។ ប៉ុន្តែព្រះជាម្ចាស់មិនបានគាប់ព្រះហប្ញទ័យទេនៅពេលដែលព្រះអង្គទតមើលចិត្តគំនិតរបស់លោក*សូល*។ យើងនឹងឃើញថាតើសកម្មភាពរបស់លោក*សូល*នឹងបង្ហាញអ្វីដែលនៅក្នុងចិត្តរបស់លោក។

នៅក្នុងផែនទីរបស់អ្នក អ្នកនឹងឃើញពីការបត់មកពី *ផ្លូវសន្យា* ទៅជា *ផ្លូវរាជាណាចក្រ*វិញ។

បន្ទាប់ពីរជ្ជកាលស្ដេច*សូល* ពីរឆ្នាំមកព្រះអង្គបានដឹកនាំប្រជាជនប្រឆាំងនឹងសត្រូវរបស់ពួកគេគឺជនជាតិ*ភីលីស្ទីន* *១សាំយូអែល ១៣:១-១៤* ប្រជាជនអ៊ីស្រាអែលមានការភ័យខ្លាចយ៉ាងខ្លាំង។ ស្ដេច*សូល* ចង់ថ្វាយដង្វាយយញ្ញបូជាដើម្បីសុំអោយព្រះអម្ចាស់ជួយគាត់ ប៉ុន្តែព្យាការីព្រះជាម្ចាស់មិននៅទីនោះ។ ក្នុងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់មានតែបូជាចារ្យខាងវិន័យប៉ុណ្ណោះដែលអាចថ្វាយដង្វាយបាន។ ស្ដេច*សូល* បានអោយគេទៅតាមលោក*សាំយូអែល* ប៉ុន្តែលោក*សាំយូអែល* ពន្យាពេលវេលា។ ស្ដេច*សូល* បានថ្វាយដង្វាយយញ្ញបូជាដោយខ្លួនព្រះអង្គ។ ខណៈពេលនោះលោក *សាំយូអែល* ក៏មកដល់ហើយបាននិយាយដោយបញ្ជាថា: "ព្រះករុណាបានប្រព្រឹត្តអំពើដោយឥតគិតពិចារណា ឥឡូវនេះព្រះរាជ្យរបស់ព្រះករុណានឹងមិនអាចគង់វង្សបន្តទៀតបានទេ។ ព្រះជាម្ចាស់បានស្វែងរកបុរសម្នាក់ដែលគាប់ព្រះហប្ញទ័យព្រះអង្គ

*១សាំយូអែល១៣:១៣-១៤*។ ព្រះបាទ*សូល* មិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ម្តងទៀត ក្រោយពីបានច្បាំងជាមួយ *អាម៉ាឡេក* ស្តេច *សូល* មិនបាន បំផ្លាញគ្រប់ទាំងអ្វីៗដូចគាត់បានបញ្ជានោះទេ *១សាំយូអែល ១៥:១-២៣*។

ឥឡូវនេះ ព្រះជាម្ចាស់បានជ្រើសរើសបុរសម្នាក់ផ្សេងទៀត ដោយព្រះហឫទ័យរបស់ព្រះអង្គផ្ទាល់ដូចអ្វីដែលព្រះអង្គបានសន្យា។ *១សាំយូអែល ១៦:៧* បុរសនោះមានឈ្មោះថា*ដាវីឌ* ហើយលោកសាំយូអែលបានចាក់ប្រេងតាំងអោយគាត់។ ហើយលោក*ដាវីឌ* ក៏បានក្លាយទៅជាទីសំណប់ចិត្តរបស់ព្រះបាទ*សូល*។ ឥឡូវនេះយើងនឹងឃើញថា តើសកម្មភាពរបស់លោក*ដាវីឌ* នឹងបង្ហាញអ្វីដែលនៅក្នុងចិត្តរបស់លោក? លោក*ដាវីឌ* បានសម្លាប់យក្ស *កូលីយ៉ាត* គឺមេទ័ពដ៏ខ្លាំងពូកែរបស់ជនជាតិភីលីស្ទីន។ សូមយើងអានសាច់រឿងទាំងមូលនៅ *១សាំយូអែល១៧:១-៥៨*។

*ដាវីឌ* បានបង្ហាញភាពក្លាហាន ការបន្ទាបខ្លួន ភាពស្មោះត្រង់ដោយខ្លួនរបស់គាត់ផ្ទាល់ គាត់ជាបុរសម្នាក់ដែលពោរពេញដោយសេចក្តីជំនឿរឹងមាំ និងបានថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ *១សាំយូអែល១៧:៣៧. ៤៥-៤៦* ព្រះបាទ *សូល* ច្រណែន និងមិនព្រមប្រគល់រាជបល្ល័ង្កទៅអោយ*ដាវីឌ* ឡើយ។

ការពិតព្រះបាទ*សូល* បានព្យាយាមសម្លាប់*ដាវីឌ* *១សាំយូអែល ១៨: ១-១៤* ហើយ*ដាវីឌ* បានរត់គេចខ្លួន ដើម្បីជីវិតរបស់គាត់។ គាត់បានត្រាច់ចរណ៍ និរទេសអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែព្រះជាម្ចាស់គង់នៅជាមួយគាត់ជានិច្ច និងការពារគាត់ពីគ្រោះថ្នាក់គ្រប់ពេលដែលគាត់ត្រាច់ចរណ៍។ *ដាវីឌ* ត្រូវបានជ្រើសរើសផ្លូវនៃជំនឿ និងជីវិត។ ស្តេចសូលកាន់តែខ្សោយទៅៗ រហូតដល់ទីបញ្ចប់ទ្រង់ក៏ទៅសុំពីគ្រូធ្មប់ *១សាំយូអែល ២៨:៧-១៩*។ ស្ត្រីនោះប្រាប់ព្រះបាទ*សូល* អំពីសេចក្តីស្លាប់ ដែលនឹងមកដល់ក្នុងពេលឆាប់ៗនេះ។ ព្រះបាទ *សូល* ព្រមទទួលស្គាល់ថា " ខ្ញុំកាលពីមុនជាមនុស្សភ្លីភ្លើ " *១សាំយូអែល ២៦: ២១* គាត់បានជ្រើសរើសផ្លូវដែលមើលទៅ ដូចជាត្រឹមត្រូវសំរាប់មនុស្ស ប៉ុន្តែវាបានបង្ហាញពីផ្លូវនៃសេចក្តីស្លាប់។ ក្រោយពេលដែលព្រះបាទ*សូល* សុគតទៅលោក*ដាវីឌ* បានក្លាយជាស្តេចគ្រប់គ្រងលើកុលសម្ព័ន្ធទាំង១២នៃអ៊ីស្រាអែល។ ស្តេច*សូល* ឈរលើចរិតធម្មជាតិរបស់មនុស្ស ដែលតែងតែធ្វើអោយមានភាពភ្លីភ្លើសំរាប់អស់អ្នកដែលបង្កើតផលផ្លែនោះ។ រីឯស្តេច*ដាវីឌ* បានមានជំហរលើលក្ខណៈនៃព្រះវិញ្ញាណ ដែលយើងនឹងទទួលនៅពេលដែលយើងទទួលព្រះយេស៊ូគ្រីស្ទជាព្រះអង្គសង្គ្រោះ។ ព្រះគ្រីស្ទបានបង្កើតយើងដោយប្រាជ្ញា "*១កូរិនថូស១:៣០* " ហើយព្រះនាមរបស់ព្រះអង្គគឺជានាមដែលផ្តល់ឱវាទ " *អេសាយ ៩:៦* "។ *សុភាសិត១២:១៥* ប្រាប់ពួកយើងថា: "មនុស្សខ្លៅគិតស្មានថាខ្លួនប្រព្រឹត្តិត្រូវ រីឯមនុស្សដែលសុខចិត្តទទួលយោបល់ពីអ្នកដ៏ទៃជាមនុស្សមានប្រាជ្ញា "។

ព្រះបាទសូលបានព្យាយាមសម្លាប់ដាវីឌជាច្រើនដង ដូច្នេះលក្ខណៈធម្មជាតិចាស់(ជីវិតចាស់) គឺតែងតែព្យាយាមសម្លាប់លក្ខណៈធម្មជាតិថ្មី (ជីវិតថ្មី) *<u>តើអ្នកនឹងបង្កើតផលផ្លែអ្វីនៅសព្វថ្ងៃនេះ?</u> តើអ្នកនឹងទៅជាមនុស្សដែលល្ងង់ខ្លៅ រឺក៏មនុស្សដែលពោរពេញដោយប្រាជ្ញា? ព្រះគ្រិស្តគឺកំពុងរង់ចាំយោបល់របស់អ្នក។ វាគឺជាភាពវៃឆ្លាតដែលប្រគល់ជីវិតរបស់អ្នកទៅព្រះអង្គ។*

**ខព្រះគម្ពីរចងចាំ:** *សុភាសិត ១២:១៥* " មនុស្សខ្លៅគិតស្មានថាខ្លួនប្រព្រឹត្តត្រូវ រីឯមនុស្សដែលសុខចិត្តទទួលយោបល់ពីអ្នកដ៏ទៃជាមនុស្សមានប្រាជ្ញា។"

# <u>សំនួរត្រិះរិះ មេរៀនទី១៤</u>

១. ហេតុអ្វីបានជាផ្លូវសន្សាតឡូវហៅថាផ្លូវរាជាណាចក្រ ? *១សាំយូអែល ៨ :៥-៦*..........................

.......................................................................................................................................................

.......................................................................................................................................... ។

តើចំនុចបីយ៉ាងអ្វីខ្លះរបស់ព្រះបាទសូលធ្លាក់ចុះពីការផ្តល់កិត្តិយសជាស្តេច?

២. *១សាំយូអែល១៣ :១៣*............................................................................................................ ។

៣. *១សាំយូអែល១៥ :២៣*............................................................................................................ ។

៤. *១សាំយូអែល២៨ :៧*............................................................................................................... ។

តើដាវីឌបានធ្វើចំនុចបីយ៉ាងអ្វីខ្លះ ដែលបង្ហាញថាគាត់ជាស្តេចដ៏ខ្លាំងពូកែ?

៥. *១សាំយូអែល១៦ :៧*............................................................................................................... ។

៦. *១សាំយូអែល១៧ :៤៥*..................................................................................................... ។

៧. *១សាំយូអែល១៨ :៥* ........................................................................................................ ។

៨. យោងតាមគម្ពីរ *សុភាសិត១២:១៥* ហេតុអ្វីបានជាអ្នកនិយាយថាព្រះបាទ*សូល* ជាមនុស្សល្ងង់ខ្លៅ?

.......................................................................................................................................................

........................................................................................................................................... ។

៩. តើយើងអាចមានប្រាជ្ញាដោយរបៀបណា? *១កូរិនថូស១:៣០*..........................................................

.............................................................................................................................................. ។

១០.សរសេរខគម្ពីរចងចាំ សុភាសិត១២:១៥.......................................................................................

.......................................................................................................................................................

.......................................................................................................................................................

.................................................................................. ។

| | |
|---|---|
| **មេរៀនទី១៥ :** | **សិរីរុងរឿងនៃអាណាចក្ររបស់ព្រះបាទសាឡូម៉ូន** |
| | **១ ពង្សាវតាក្សត្រទី១-១១ និង ២ របាក្សត្រទី១-៩** |
| **គំនិតសំខាន់ :** | **ដើម្បីបង្ហាញអោយឃើញមុនពីរាជ្យ១០០០ឆ្នាំនៃរាជាណាចក្រ។** |

ដូចកាលពីក្មេងតើអ្នកធ្លាប់លេងធ្វើជាស្តេច និងម្ចាស់ក្សត្រិយ៍ដែរ ឬទេ? វាគឺជាការរីករាយណាស់ នៅពេលដែលយើងបានពាក់មកុដលើក្បាលរបស់យើង និងតាំងខ្លួនឯងជាអ្នកប្រាប់អោយអ្នកដទៃធ្វើអ្វីមួយនោះ។ តើអ្នកដឹងទេថាគ្រប់អ្នកមានជំនឿទាំងអស់នឹងបានសោយរាជ្យរួមជាមួយព្រះគ្រិស្តនៅថ្ងៃណាមួយមិនខាននៅលើទីតាំងមួយខ្ពស់ជាងស្តេច ឬជាងម្ចាស់ក្សត្រិយ/ ក្នុងសកលលោកសព្វថ្ងៃនេះ?

បន្ទាប់ពី*ដាវីឌ* បានក្លាយជាស្តេចគ្រប់គ្រងលើអ៊ីស្រាអែលទ្រង់មានបំណងចង់កសាងអាសនៈមួយ ជាកន្លែងសំរាប់ថ្វាយព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ទ្រង់តាមរយៈព្យាការីថា "អ្នកគឺមិនត្រូវកសាងអាសនៈសំរាប់នាមយើងឡើយពីព្រោះអ្នកបានកំចាយឈាមមនុស្សជាច្រើននៅក្នុងសង្គ្រាម។ អ្នកនឹងបង្កើតបានកូនប្រុសម្នាក់ ហើយគេនឹងសាងសង់អាសនៈសំរាប់នាមយើង គេនឹងក្លាយទៅជាបុត្ររបស់យើង យើងនឹងបង្កើតរាជាណាចក្ររបស់ទ្រង់លើអាណាចក្រនេះជារៀងរហូត"។ *១ក្ងរិថ្ងស ២២:៦-១០* មុនពេលដែលទ្រង់សុគតស្តេចដាវីឌបានបង្រៀន*សាឡូម៉ូន* និងបានចាក់ប្រេងតាំងគាត់អោយធ្វើជាស្តេចគ្រប់គ្រងទឹកដីរបស់ទ្រង់ *១ពង្សាវតា ក្សត្រ ១:៣៩*។

សាឡូម៉ូនបានចាប់ផ្តើមសោយរាជ្យគ្រប់គ្រង់លើអ៊ីស្រាអែលដែរ។ ទ្រង់បានទៅ*ហ្គីបៀន* គឺជាកន្លែងដែលសំខាន់សំរាប់ការថ្វាយបង្គំ ហើយថ្វាយដង្វាយដុតទាំងពាន់ៗ។ ហើយបន្ទាប់មកទៀតព្រះអម្ចាស់បានបង្ហាញអង្គទ្រង់នៅក្នុងសុបិន្តរបស់ព្រះបាទ*សាឡូម៉ូន* ហើយព្រះអង្គមានព្រះបន្ទូលថាៈ *សាឡូម៉ូន* តើអ្នកចង់បានអ្វី? គាត់អាចស្នើសុំអ្វីៗដែលគាត់ចង់បានពីព្រះអង្គគាត់ទូលព្រះអង្គថា "សូមព្រះជាម្ចាស់ប្រទានអោយទូលបង្គំនូវប្រាជ្ញា ពេលនោះព្រះអង្គក៏ប្រទានអោយគាត់ក្លាយជាអ្នកមានផងដែរ *២របាក្សត្រ ១:៧-១២*។ បន្ទាប់មក*សាឡូម៉ូន* បានត្រលប់ទៅទីក្រុងយេរ៉ូសាឡឹមវិញ ហើយគាត់ក៏បានអរព្រះគុណព្រះអម្ចាស់។ បន្ទាប់មកទៀតព្រះបាទ*សាឡូម៉ូន* ត្រូវបានគេស្នើសុំអោយជួយផ្សះផ្សារការឈ្លោះប្រកែកមួយរវាងស្ត្រីពីរនាក់ សូមយើងអានរឿងនេះនៅក្នុង *១ពង្សាវតា ក្សត្រ ៣:១៦-២៨*។ ព្រះបាទ*សាឡូម៉ូន* បានរៀបចំរាជាណាចក្រ ហើយទ្រង់មានក្រោលសេះ ៤០០០០ និងអ្នកគង្វាលសេះព្រមទាំងរទេះចម្បាំង ១២០០០ ចំនួលរបស់ទ្រង់មានរាប់លានក្នុងមួយឆ្នាំៗ។ រាជបល្ល័ង្ករបស់ព្រះបាទ*សាឡូម៉ូន* ធ្វើពីភ្លុកស្រោបមាសសុទ្ធ ហើយនិងគ្រប់ទាំងពែងក៏បានធ្វើពីមាសដែរ។ ព្រះបាទ*សាឡូម៉ូន* បានបង្កើតសុភាសិតចំនួន៣០០០ និងនិពន្ធចំរៀង១០០៥បទ។ ព្រះអង្គជាស្តេចដ៏ឆ្នើមដែលមានប្រាជ្ញា និងជាអ្នកមានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភជាងស្តេចទាំងអស់នៅលើផែនដី។

នៅក្នុង *២របាក្សត្រ ៥:១ ដល់ ៧:៣* យើងនឹងឃើញព្រះបាទ*សាឡូម៉ូន* បានសង់ប្រាសាទ និងធ្វើពិធីសម្ពោធថ្វាយព្រះជាម្ចាស់។ ហឹបនៃសម្ព័ន្ធមេត្រីជាប្រអប់ធំ ដែលមានវត្ថុដ៏វិសុទ្ធខាងក្នុងត្រូវបានយកទៅដាក់កន្លែងដ៏វិសុទ្ធ។ មានការច្រៀងរបស់ក្រុមអ្នកចំរៀងនៃពួកលេវី និងការផ្លុំរបស់អ្នកផ្លុំត្រែ។ ហ្វូងមនុស្សស្រែកថា "ទ្រង់ជាព្រះជាម្ចាស់ដ៏វិសុទ្ធ សេចក្តីមេត្តារបស់ទ្រង់នៅស្ថិតស្ថេរជានិច្ច "។ សិរីរុងរឿងរបស់ព្រះជាម្ចាស់បានចាក់បំពេញព្រះបាទ

*សាឡូម៉ូន* ហើយទ្រង់ក៏លុតជង្គង់ទាំងអធិដ្ឋាននៅចំពោះមុខប្រជាជនពិធីឆ្លងបានចប់ដោយការអធិដ្ឋាន។ ព្រះបាទ *សាឡូម៉ូន* បានឃើញពីថ្ងៃអនាគតជាថ្ងៃនៃទុក្ខលំបាកនឹងមកដល់ នៅពេលដែលអ៊ីស្រាអែលនឹងត្រូវជំលៀសទៅទឹកដីផ្សេងទ្រង់នឹងព្រះសណ្ដាប់ពាក្យអធិដ្ឋានរបស់ពួកគេ និងជួយពួកគេនៅថ្ងៃនោះ។ បន្ទាប់មកស្រាប់តែមានភ្លើងធ្លាក់មកពីស្ថានសួគ៌ ហើយឆេះយញ្ញបូជាអស់ទៅ។ ពេលនោះពួកសង្ឃមិនអាចចូលទៅទេព្រោះសិរីរុងរឿងរបស់ព្រះជាម្ចាស់បានចាក់បំពេញព្រះវិហារ។

ស្ដេចជាច្រើននៅលើផែនដីបានទៅសណ្ដាប់ព្រះប្រាជ្ញាញាណ និងទៅមើលទ្រព្យសម្បត្តិដ៏ស្ដុកស្ដម្ភរបស់ព្រះបាទ *សាឡូម៉ូន ២របាក្សត្រ ៩:២៣*។ ម្ចាស់ក្សត្រីនៃស្រុកសេបាមិនបានជឿពាក្យសំដីដែលគេនិយាយនោះទេ ដូច្នេះទ្រង់ក៏យាងទៅដោយផ្ទាល់ដើម្បីបញ្ជាក់ *២របាក្សត្រ ៩:៣-៨*។ តើអ្នកនៅចងចាំពីអ្វីដែលយើងបាននិយាយក្នុងព្រះគម្ពីរទេ? មនុស្សម្នាក់ រឺវត្ថុអ្វីមួយជារូបភាពពីពេលមុន។ រាជាណាចក្ររបស់ព្រះបាទ*សាឡូម៉ូន* បានបង្ហាញពីរាជាណាចក្រនៃស្ថានសួគ៌នៅលើផែនដី។ តើអ្នកនៅចងចាំពីអ្វីដែលព្រះជាម្ចាស់បានសន្យាជាមួយអាណាចក្ររបស់លោកអប្រាហាំ អ៊ីសាក យ៉ាកុប និងដាវីឌ និងរាជាណាចក្រនៅអស់កល្ប? នៅក្នុងផែនទីវាគឺតំណាងអោយភ្នំនៃរាជាណាចក្រ។ ជាកន្លែងស្ថិតនៅផ្នែកមួយនៃប្រាសាទដែលស្ដេច *សាឡូម៉ូន* បានកសាង។

ព្រះបាទ*សាឡូម៉ូន* គឺដូចជារូបភាពរបស់ព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ដនៃយើង ទ្រង់នឹង សោយរាជ្យជាស្ដេចលើអស់ទាំងស្ដេចគ្រប់ជាតិសាសន៍នៃផែនដីនឹងមកថ្វាយបង្គំគោរពព្រះអង្គ។ តើអ្នកមានការភ្ញាក់ផ្អើល រឺទេ ថាអ្នកនៅឯណានៅពេលនោះ? យើងត្រូវមើលលើ*ចំណោតនៃព្រះគុណ* ជាកន្លែងណាដែលអស់អ្នកណា ដែលទទួលព្រះគ្រិស្ដក្លាយជាអ្នកនាំសារនៃការសង្គ្រោះ មុនពេលទ្រង់គ្រងរាជ្យនៅលើផែនដី យើងនឹងបានជួបព្រះអង្គនៅក្នុងអាកាសទៅនៅជាមួយទ្រង់ជារៀងរហូត ពីព្រោះយើងទាំងអស់គ្នាជារូបកាយរបស់ព្រះគ្រិស្ដ។ នៅពេលទ្រង់សោយរាជ្យជាស្ដេចលើអស់ទាំងស្ដេចព្យាការីដ៏វិសុទ្ធរបស់ទ្រង់នឹងគ្រងរាជ្យជាមួយទ្រង់។ សព្វថ្ងៃនេះ យើងដូចជាកូនរបស់ព្រះអង្គដែលនឹងទទួលមរតករបស់ទ្រង់ ហើយយើងចែករំលែកសិរីរុងរឿង និងទ្រព្យសម្បត្តិរបស់ទ្រង់នៅស្ថានបរមសុខ។ យើងនឹងរង់ចាំទ្រង់ត្រាស់ហៅយើងដែលទ្រង់ចង់អោយយើងក្លាយទៅជារាជ្យទូតរបស់ព្រះអង្គ ដើម្បីសុំអោយអ្នកឯទៀតទទួលទ្រង់ជាព្រះសង្គ្រោះរបស់ពួកគេ។

យើងបានឃើញសិរីរុងរឿង ដែលមានលើព្រះបាទសាឡូម៉ូនពីព្រោះទ្រង់បានគោរពកោតខ្លាចព្រះជាម្ចាស់។ មេរៀនបន្ទាប់ យើងនឹងឃើញសោកនាដកម្មដែលនឹងមកដល់នៅពេលដែលព្រះបាទ *សាឡូម៉ូន* ឈប់គោរពកោតខ្លាចព្រះជាម្ចាស់។ ដូចនេះដើម្បីបញ្ចប់មេរៀនទី១៥ នៅក្នុងការសិក្សាមេរៀន *មាគ៌ានៃជីវិត* របស់ពួកយើង។ ប្រហែលអ្នកមិនទាន់មានសេចក្ដីសង្ឃឹមដ៏អស្ចារ្យនៅឡើយនៃការសោយរាជ្យរួមជាមួយព្រះគ្រិស្ដទេ។ វាគ្មានអ្វីដែលពិបាកទេសំរាប់យើងដែលក្លាយទៅជាកូនរបស់ព្រះអង្គទ្រង់នឹងទទួលយើង ហើយសង្គ្រោះអស់អ្នកដែលជឿថាទ្រង់បានសុគត់ និងរស់ឡើងវិញម្ដងទៀតសំរាប់យើង។ ព្រះអង្គនឹងទទួលអំពើបាបយើង ហើយយើងនឹងក្លាយទៅជាកូនរបស់ព្រះអម្ចាស់ ហើយនឹងបានរួមជាមួយព្រះគ្រិស្ដ។

**ខគម្ពីរចងចាំ** រ៉ូម៨:១៧ : ប្រសិនបើយើងពិតជាបុត្រមែននោះ យើងមុខជាទទួលមរតកពុំខាន។ យើងនឹងទទួលមរតកពីព្រះជាម្ចាស់គឺមរតករួមជាមួយព្រះគ្រីស្ត។ ដោយយើងរងទុក្ខលំបាករួមជាមួយព្រះអង្គ ដូច្នេះយើងក៏នឹងទទួលសិរីរុងរឿងរួមជាមួយព្រះអង្គដែរ។

## <u>សំនួររំឭក មេរៀនទី១៥</u>

ចូរមើលនៅក្នុងព្រះគម្ពីរ និងបំពេញនូវពាក្យដែលត្រឹមត្រូវ ដើម្បីបំពេញចន្លោះនៃ ប្រយោគខាងក្រោម :

១. ព្រះជាម្ចាស់បដិសេធមិនអោយដាវីឌសាងសង់ប្រាសាទពីព្រោះ ព្រះអង្គមាន..........................................
........................................................................................................*១របាក្សត្រ២២:៨* ។

២. ព្រះជាម្ចាស់មានព្រះបន្ទូលថាកូនរបស់ដាវីឌ...............................................................................................
...........................................................................នឹងសាងសង់វា *១របាក្សត្រ២២:៨* ។

៣. ព្រះជាម្ចាស់មានព្រះបន្ទូលថានៃរាជាណាចក្ររបស់ព្រះបាទ*សាឡូម៉ូន* ថា និងបង្កើត ឡើងអោយគ្រងរាជ្យលើអ៊ីស្រាអែល.................................................................................................................................. .
........................................................................................................ *១របាក្សត្រ២២:១០*។

៤. ព្រះបាទសាឡូម៉ូនបានសំណូមពរ អោយព្រះអម្ចាស់ប្រទាន អោយទ្រង់នូវ....................................
.............................................................................................................. *១របាក្សត្រ២:១០*។

៥. ព្រះជាម្ចាស់បានបង្ហាញថាព្រះអង្គសព្វព្រះហឫទ័យជាមួយយញ្ញបូជា និងការអធិដ្ឋាន របស់ព្រះបាទ*សាឡូម៉ូន* ហេតុនេះហើយទើប ព្រះអង្គបានទំលាក់............................................................................ .........................
...........................................................................................*២របាក្សត្រ៧:១*។

៦. ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះបាទសាឡូម៉ូនថា " ប្រសិនបើអ្នកត្រលប់ងាកចេញ និងបោះបង់ចោលការបញ្ជារបស់យើងហើយទៅ..........................................................................................ហើយយើងនឹង............
........................................................................... *២របាក្សត្រ៧:១៩-២០* ។

៧. រាជាណាចក្ររបស់ព្រះបាទ*សាឡូម៉ូន* គឺដូចជារូបភាពមួយនៃពេលវេលាដែលនឹងមកដល់ នៅពេលដែលព្រះគ្រីស្តនឹងសោយរាជ្យសំរាប់១000ឆ្នាំ (សហស្សវត្ស) ផែនដីនឹងពោរពេញទៅដោយ..........................................
......................................................................................................................................*អេសាយ១១:៩* ។

៨. សមាជិករបស់រូបកាយព្រះគ្រីស្តនឹង.................................................................... ............................
នៅពេលដែលគ្រីស្តសោយរាជ្យជាស្តេចលើ អស់ទាំងស្តេច *២ធីម៉ូថេ២:១២* ។

៩. ក្នុងកំឡុងពេលដែលយើងកំពុងរង់ចាំទៅជាមួយព្រះអម្ចាស់ ព្រះអង្គចង់អោយយើងក្លាយទៅជា..................
...................................................................................................របស់ព្រះគ្រិស្ត *២កូរិនថូស៥:២០*។

១០.សរសេរខគម្ពីរដោយចងចាំ *រ៉ូម៨:១៧*

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

.................................................................................................................................................... ។

## មេរៀនទី១៦ : ការចាកចេញពីភាពត្រូវគេបង្ខាំង

របាក្សត្រ និង ពង្សាវតារក្សត្រ

**គំនិតសំខាន់ :** ដើម្បីបង្ហាញថាសុភមង្គលកើតចេញពីការស្តាប់បង្គាប់ និងការទុកចិត្តលើព្រះជាម្ចាស់

តើអ្វីជាភាពខុសគ្នារវាងការស្តាប់ និងការមិនស្តាប់បង្គាប់? នៅពេលយើងចេះស្តាប់បង្គាប់យើងធ្វើអ្វីដែលយើងត្រូវបានណែនាំអោយធ្វើចំពោះកិច្ចការនោះ។ នៅពេលយើងមិនស្តាប់បង្គាប់គឺយើងបានធ្វើបំពាន រឺល្មើសមិនស្តាប់បង្គាប់ពីបទបញ្ជាអ្វីមួយ។

តើអ្វីជាភាពខុសគ្នារវាងការមានសុភមង្គល និងអពមង្គល? សុភមង្គលគឺការរំភើបចិត្ត រឺសេចក្តីសុខក្នុងអារម្មណ៍នៅពេលយើងសប្បាយ និងសំរេចបំណងអ្វីមួយ។ ឯភាពអពមង្គលគឺជាពាក្យផ្ទុយពីនេះ។ តើយើងសប្បាយចិត្តដែររឺទេនៅពេលយើងមិនស្តាប់បង្គាប់ព្រះ? ទេ! ព្រោះយើងបានធ្វើខុសនិងមនសិការរបស់យើងហើយការមិនស្តាប់បង្គាប់តែងតែបណ្តាលអោយមានការដាក់ពិន័យមិនមែនគ្រាន់តែអ្នកប្រព្រឹត្តប៉ុណ្ណោះទេ ថែមទាំងនាំទុក្ខទោសដល់អ្នកដទៃថែមទៀតផង។

នៅពេលព្រះអម្ចាស់ប្រទានក្រឹត្យវិន័យ និងបទបញ្ជាដល់ជនជាតិអ៊ីស្រាអែល ទ្រង់បានមានព្រះបន្ទូលទៅពួកគេថាទ្រង់នឹងប្រទានភ្លៀងដ៏ច្រើនបរិបូរណ៍ប្រទានពន្លឺសន្តិភាព និងភាពរុងរឿងមានជ័យជំនះគ្របដណ្តប់លើខ្មាំងសត្រូវ បើពួកគេអាចរក្សានូវបទបញ្ជារបស់ទ្រង់បានខ្ជាប់ខ្ជួន។ ប៉ុន្តែប្រសិនបើពួកគេមិនគោរពតាមក្រឹត្យវិន័យធ្វើរូបចំលាក់ក្លែងក្លាយ ហើយគោរពព្រះទាំងនោះព្រះអម្ចាស់នឹងធ្វើឱ្យពួកគេកើតជំងឺរាំរ៉ៃរីករាលដាលកើតឡើងនូវការស្លាប់ មានសត្វសាហាវ កើតទុក្ខគ្រាំគ្រា និងចាញ់ខ្មាំងសត្រូវទាំងពួង *លេវីវិន័យ ២៦:*។

ស្តេចសាឡូម៉ូនទ្រង់ជ្រាបពីបទបញ្ជាទាំងនេះ ប៉ុន្តែមិនយូរប៉ុន្មានទ្រង់ក៏មិនស្តាប់បង្គាប់ព្រះជាម្ចាស់។ ព្រះអង្គបានបង្កើនចំនួនសេះ មាស ប្រាក់ និងប្រពន្ធកាន់តែច្រើនឡើង *ទុតិយកថា ១៧:១៦-១៧*។ ប្រពន្ធរបស់ស្តេចសាឡូម៉ូនជាអ្នកមិនគោរពកោតខ្លាចព្រះជាម្ចាស់បានដឹកនាំទ្រង់ឱ្យងាកចេញពីព្រះអម្ចាស់ ហើយគោរពរូបសំណាកព្រះក្លែងក្លាយ។ ព្រះជាម្ចាស់មានព្រះបន្ទូលថា " ពីព្រោះឯងមិនបានរក្សាសម្ព័ន្ធមេត្រីរបស់យើង... យើងនឹងដករាជាណាចក្រពីឯង "។ បន្ទាប់ពីស្តេច *សាឡូម៉ូន* ស្លាប់ទៅកូនប្រុសរបស់ទ្រង់ឈ្មោះ *យេរ៉ូបោម* ឡើងគ្រងរាជ្យបន្ត។ នៅពេលប្រជាជនបានតវ៉ាញ្ញែរស្តេចមានបន្ទូលថា " ព្រះបិតារបស់ខ្ញុំបានធ្វើឱ្យអ្នករាល់គ្នាមានបន្ទុកធ្ងន់ ចំណែកខ្ញុំវិញ ខ្ញុំនឹងដាក់នឹមលើអ្នករាល់គ្នារឹតតែធ្ងន់ជាងមុន" *១ពង្សាវតាក្សត្រ១២:១៤*។ ជនជាតិអ៊ីស្រាអែលបានធ្វើការបះបោរប្រឆាំងបន្ទាប់មករាជាណាចក្រត្រូវបែងចែកជាពីរគឺអ៊ីស្រាអែល និងយូដា។

ស្តេចយេរ៉ូបោមគឺជាស្តេចដំបូងនៃអាណាចក្រភាគខាងជើងអ៊ីស្រាអែល។ ទ្រង់បានប្រព្រឹត្តអំពើអាក្រក់ជាច្រើនហើយអ្នកដែលសោយរាជ្យក្រោយៗទ្រង់ក្នុងទឹកដីអ៊ីស្រាអែលបានដើរតាមគន្លងរបស់ទ្រង់។ ព្រះអម្ចាស់បានបញ្ជូនការសន្យាដាក់ទណ្ឌកម្មថាកងទ័ពនៃពួកអាសេរីនឹងមកឡោមព័ទ្ធជុំវិញទីក្រុងសាម៉ារីរយៈពេល៣ឆ្នាំ ហើយចុងបញ្ចប់ពួកគេនឹងក្លាយជាឈ្លើយនៅទឹកដីនៃប្រទេសអាសេរី។ សំរាប់លទ្ធផលនេះគឺដោយសារកូនចៅអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាប

ទាស់នឹងព្រះហឫទ័យព្រះអម្ចាស់ ២ពង្សាវតាក្សត្រ១៧ៈ ១-៧។ អ្នកអាចឃើញថាហេតុអ្វីផ្លូវនៃរាជាណាចក្រនៅលើផែនទីរបស់យើង ឥលូវមានការបត់បែនហើយបត់ចុះឡើងបែបនេះគឺព្រោះតែអំពើបាប។

មានស្តេចជាច្រើនដែលបានធ្វើតាមស្តេចយេរ៉ូបោមនៅក្នុងរាជាណាចក្រនៃសាសន៍យូដា គឺសុទ្ធតែជាស្តេចដែលអាក្រក់។ មានតែមនុស្សមួយចំនួនតែប៉ុណ្ណោះ ដែលព្យាយាមគោរពកោតខ្លាចតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់។ នៅពេលដែលពួកគេគោរពព្រះជាម្ចាស់នាំអោយមានការប្រទានព្រះពរល្អៗ និងការការពារចំពោះគេ។ ប៉ុន្តែពួកគេមិនអើរពើជាមួយព្រះបន្ទូលព្រះអម្ចាស់ថែមទាំងធ្វើបាបព្យាការីរបស់ព្រះអម្ចាស់ទៀតផង។ មហាក្សត្រចុងក្រោយបង្អស់នៃសាសន៍យូដាគឺស្តេច*សេដេកា*។ ទ្រង់គឺជាស្តេចដែលល្ងីល្ងើនិងមិនស្តាប់បង្គាប់ព្រះអម្ចាស់។ ព្យាការី*យេរេមី* សរសេរថាៈ ស្រុកនេះទាំងមូលនឹងត្រូវវិនាសហិនហោច ហើយប្រជាជាតិទាំងនោះនឹងទៅជាចំណុះនៃស្តេចស្រុកបាប៊ីឡូនអស់រយៈពេល៧០ឆ្នាំ *យេរេមី ២៥:១១*។

*នេប៊ូកាណេសា* ជាស្តេចនៃស្រុកបាប៊ីឡូនបាននាំកងទ័ពទាំងអស់ប្រឆាំងនឹងស្រុក*យេរូសាឡឹម*។ ស្តេច*សេដេកា* បានព្យាយាមលួចរត់ចេញពីពួកគេ ប៉ុន្តែត្រូវពួកគេចាប់បាន។ ពួកគេបានសំលាប់កូនប្រុសរបស់ទ្រង់នៅនឹងមុខទ្រង់ ហើយគេខ្វេះភ្នែកទ្រង់ទាំងពីរផង។ ពួកគេដាក់ច្រវាក់ទ្រង់ជាឈ្លើយនាំយកទៅស្រុកបាប៊ីឡូន។ យើងហៅថាជាការដាក់ទោសពីការងាកចេញនៅលើផែនទីរបស់យើង។ គ្រួសារអភិជននៃពួកយូដាត្រូវបាននាំចេញទៅ ហើយពង្រាយអោយរស់នៅក្នុងចំណោមសាសន៍ដទៃ។ *ស្តេចនេប៊ូកាណេសា* បានដុតអាសនៈរបស់ព្រះអម្ចាស់រាជវាំងរបស់ស្តេច និងអ្វីៗផ្សេងទៀតដូចជាផ្ទះធំៗ។ ពួកទាហានកំទេចជញ្ជាំងនៃទីក្រុងសសរស្ពាន់ធំៗដ៏ស្អាតៗអោយខូចខ្ទេចខ្ទី ហើយពួកគេប្រមូលយកមាសប្រាក់ដែលនៅក្នុងព្រះវិហារ។

តើអ្នកយល់ទេអ្វីជាផលវិបាកដែលគួរឱ្យខ្លាចក្នុងការមិនស្តាប់បង្គាប់ព្រះជាម្ចាស់? មិនមែនមានតែស្តេច*សាឡូម៉ូន* និងស្តេចជាច្រើនទៀតដែលគ្មានអំណរទេ ប៉ុន្តែពួកគេនាំយកបញ្ហាជាច្រើនដល់ប្រជាជាតិទាំងមូល។ *នៅរ៉ូម ៦:១៦* ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់យើងថា បើយើងបំរើម្ចាស់ណាត្រូវស្តាប់ម្ចាស់នោះ។ ប្រសិនបើយើងមិនស្តាប់តាមព្រះបន្ទូលរបស់ព្រះអង្គ តើយើងកំពុងបំរើខ្លួនឯង រឺបំរើព្រះអង្គ? ព្រះអង្គចង់ឱ្យយើងស្តាប់បង្គាប់ទ្រង់ *២ថេស្សាឡូនិក ១:៨*។ ព្រះអង្គចង់ឱ្យកូនៗស្តាប់បង្គាប់ឪពុកម្តាយ *អេភេសូ ៦:១-៣* ។ ព្រះអង្គចង់ឱ្យយើងទាំងអស់គ្នាគោរពកោតខ្លាចទ្រង់ដោយភាពត្រឹមត្រូវ *រ៉ូម ៦:១៦-១៧*។

បទបន្ទូរនៃសេចក្តីពិតៈ គ្មានផ្លូវផ្សេងក្រៅពីការទុកចិត្ត និងការស្តាប់បង្គាប់ទៀតទេ ដើម្បីភាពរីករាយនៅក្នុងព្រះគ្រិស្តគឺមានតែការទុកចិត្ត និងការស្តាប់បង្គាប់។ បន្ទាប់ពី៧០ឆ្នាំកន្លងមកតាមរយៈសេចក្តីសន្យារបស់ទ្រង់ ចំពោះពួកគេបានអនុញ្ញាតឱ្យអ្នកមានជំនឿត្រលប់ទៅកាន់ទឹកដីសន្យា ប៉ុន្តែរាជាណាចក្រត្រូវបានបញ្ឈប់។

តើអ្នកណាជាអ្នកដឹកនាំរបស់អ្នកបច្ចុប្បន្ននេះ? អំពើបាប រឺភាពសុចរិត? សូមស្រែកទៅកាន់ព្រះយេស៊ូគ្រិស្តមានតែទ្រង់មួយប៉ុណ្ណោះ ដែលអាចប្រទានសុភមង្គលពិតប្រាកដដល់អ្នកបាន។

**ខគម្ពីរចងចាំ ៖** អេភេសូ ៦:១ កុមារាកុមារីអើយ ចូរស្តាប់បង្គាប់មាតាបិតារបស់អ្នក ដោយយល់ដល់ព្រះអម្ចាស់ធ្វើដូច្នេះទើបត្រឹមត្រូវ ។

## សំនួររំឭក មេរៀនទី១៦

អាននៅ *លេវីវិន័យ ២៦:១-៣* ហើយសរសេរ៦ចំនុចនៃការប្រទានពរ ដែលព្រះអម្ចាស់បានសន្យាជាមួយពួកអ៊ីស្រាអែល ប្រសិនបើពួកគេគោរពកោតខ្លាចទ្រង់ ហើយមិនគោរពព្រះក្លែង ក្លាយ ។

១-...................................... ...........................................

២-..................................... .............................................

៣-..................................... .............................................

អាន *លេវីវិន័យ ២៦:១៦,១៧,២០,២២,២៥,២៩,៣១,៣៣,៣៨* ហើយសរសេរ៦ ចំនុចជាការដាក់ទោសចំពោះអ៊ីស្រាអែលដែលមិនស្តាប់បង្គាប់ទ្រង់ ហើយគោរពព្រះក្លែងក្លាយ ។

៤-..................................... .............................................

៥-..................................... ............................................

៦-.................................... ..............................................

៧-ប៉ុន្តែព្រះអង្គស្រលាញ់ប្រជាជនរបស់ព្រះអង្គហើយទ្រង់មានព្រះបន្ទូលទៅកាន់ពិភពលោកថា...................
............................................................................................ ជាមួយជីដូន ជីតាពួកគេ *លេវីវិន័យ ២៦:៤៥*។

៨-នៅក្នុងចន្លោះខាងក្រោម ចូរគូសរូបភាពតំណាងពីផ្លូវនៃរាជាណាចក្របានធ្លាក់ចុះ ដោយសារស្តេចដែលប្រព្រឹត្តអាក្រក់ និងកំឡុងពេលក្នុងការជាប់ទោសដោយការងាកចេញ ។

៩ នៅលើបន្ទាត់ខាងក្រោមចូរសរសេរពាក្យនៃបទចំរៀងសេចក្តីពិត និងការស្តាប់បង្គាប់

.......................... ............................. ................................................ ..................................................

...................... ......................................................... .................................... ......................

............................... ........................... ................................................ ....................................... ។

១០. សរសេរខម្ពីរចងចាំ *អេភេសូ៦:១* ............................................................................

........................................................................................................................ ......................................

....................................................................................................................................... .......... ។

**មេរៀនទី១៧ :** **ព្យាការីឃើញកំពូលភ្នំស្រួចពីរ**

**១ពេត្រុស១:១០-១២-មាឡាគី**

**គំនិតសំខាន់ :** **បង្ហាញពីភាពខុសគ្នារវាងទំនាយពិត និងទំនាយក្លែងក្លាយ**

ក្នុងមេរៀននេះ យើងនឹងសិក្សាគ្របដណ្តប់ទៅលើភាពអស្ចារ្យមួយនៅលើមាគ៌ានៃជីវិត។ យើងនឹងមើលទៅកំពូលភ្នំដ៏ស្រួចទាំងពីរ។

ក្នុងមេរៀនមុន យើងបានធ្វើដំណើរចូលដល់ការដាក់ទោសដោយការងាកចេញរបស់ជនជាតិអ៊ីស្រាអែល។ យើងបានឃើញពីរបៀបដែលប្រជាជនបែរទៅគោរពព្រះក្លែងក្លាយ ហើយបានទទួលទោសសំរាប់អំពើបាបទាំងនោះផងដែរ។ វាគឺជាកំឡុងពេលដែលព្រះអម្ចាស់ត្រាស់ហៅព្យាការីជាមនុស្សរបស់ព្រះអង្គ ហើយជាអ្នកដែលនិយាយអំពីទ្រង់ដើម្បីដាស់តឿនពួកអ៊ីស្រាអែលអំពីការវិនិច្ឆ័យ និងផ្តល់សេចក្តីសុខសាន្តដល់ប្រជាជនដែលស្តាប់បង្គាប់ជាមួយការសន្យាចំពោះការយាងមកនៃស្តេចជាព្រះសង្គ្រោះ។

ទោះជាយ៉ាងណាក៏ដោយមានចំនុចមួយដែលព្យាការីមិនអាចយល់បាន។ សាវ័កពេត្រុសបាននិយាយអំពីរឿងនេះថាព្យាការី ដែលថ្លែងពីព្រះបន្ទូលអំពីព្រះហឫទ័យប្រណីសណ្តោសរបស់ព្រះអម្ចាស់ចំពោះបងប្អូនបាននាំគ្នាស្រាវជ្រាវ និងរិះរកចង់ដឹងអំពីការសង្គ្រោះនេះ។ ព្រះវិញ្ញាណរបស់ព្រះគ្រិស្តស្ថិតក្នុងព្យាការីទាំងនោះបានបញ្ជាក់ប្រាប់ទុកជាមុនអំពីទុក្ខលំបាករបស់ព្រះគ្រិស្ត និងពីសិរីរុងរឿងដែលព្រះអង្គនឹងទទួលតាមក្រោយ។ ពួកលោកក៏បានរិះគិតចង់ដឹងថាតើព្រឹត្តិការណ៍នេះនឹងកើតឡើងនៅពេលណាក្នុងកាលៈទេសៈណា *១ពេត្រុស១:១០-១១*។ ពួកគេមិនអាចយល់អំពីសេចក្តីសន្យាអំពីស្តេចមួយពោរពេញដោយសិរីរុងរឿងមានការបន្ទាបខ្លួន និងជាអ្នកបំរើដែលរងការទុក្ខលំបាកផង។ នៅលើផែនទីរបស់យើង យើងតំណាងឱ្យសេចក្តីទុក្ខលំបាក និងសិរីរុងរឿងដោយភ្នំទាំងពីរនេះគឺ *កំពូលភ្នំកាល់វ៉ារី និងភ្នំរាជាណាចក្រ*។

ប្រសិនបើយើងអានព្រះគម្ពីររបស់យើងពីអ្វីៗ ដែលព្យាការីបានថ្លែងប្រាប់ទុកមុន។ បន្ទាប់មកយើងតាំងខ្លួនជាអ្នកមើលទៅកំពូលភ្នំទាំងពីរនោះ។ នៅពេលបានអានអំពីទំនាយដែលព្យាការីបានទាយទុករួច ហើយចូរសំរេចចិត្តពីទំនាយនីមួយៗចំពោះភ្នំទាំងពីរនេះ។

ការក្បត់ ........................................................ *សាការី១១:១២-១៣*

ទឹកខ្មេះ និងទឹកប្រមាត់.................................... *ទំនុកតម្កើង៦៩:២០-២១*

ការមើលងាយ.................................................... *ទំនុកតម្កើង២២:៧-៨*

បោះដែកគោលនៅលើឈើឆ្កាង................................ *ទំនុកតម្កើង២២:១៦*

ការធ្វើឱ្យឈឺចាប់នៅលើព្រះភ័ក្រ្ត............................................. *មីកា៥:១*

ប្រមាថមើលងាយហើយវាយនឹងខ្សែរំពាត់........................ *អេសាយ ៥០:៦*

ការស្លាប់ និងការបញ្ចុះសព............................................ *អេសាយ ៥៣:៩*

ភាពទុក្ខលំបាកជំនួសអ្នកដ៏ទៃ...................................... *អេសាយ៥៣:៤-៦*

ចំនួនលេខជាមួយនឹងបាបកម្ម....................................*អេសាយ ៥៣:១២*

បញ្ចុះក្នុងផ្នូរ..................................................................*អេសាយ ៥៣:៩*

ការយាងមកក្នុងសិរីរុងរឿង..........................................*ដានីអែល ៧:១៣*

វិសាលភាពរាជាណាចក្រ...............................................*ដានីអែល ៧:១៤*

រាជាណាចក្រដែលគ្មានទីបញ្ចប់.....................................*ដានីអែល ៧:១៤*

ពូជពង្សរបស់ព្រះបាទដាវីឌ...................................*១របាក្សត្រ ១៧:១១*

ពិភពលោកទាំងមូលអោនក្រាបចុះ..........................*ទំនុកតម្កើង ២២:២៩*

ការឈឺចាប់របស់ប្រជាជាតិ...................................*ទំនុកតម្កើង ២:៤-៥*

ស្តេចនៅលើភ្នំស៊ីយ៉ូនគ្រងរាជ្យលើអ្នកមិនជឿព្រះអម្ចាស់ *ទំនុកតម្កើង២:៦-៨*

ភាពសុចរិតដែលអស្ចារ្យ...........................................*អេសាយ ៩:៦-៧*

សោយរាជ្យដោយព្រះប្រាជ្ញាញាណ............................*អេសាយ ១១:១-៤*

ការយាងចេញពីផ្នូរ................................................*ទំនុកតម្កើង ១៦:១០*

វាគឺមិនមែនជាការភ្ញាក់ផ្អើលទេ ដែលព្យាការីហើយនិងមនុស្សឆ្ងល់អំពីការប្រឆាំងដ៏ខ្លាំងក្លានេះ។ ពួកគេមិនអាចមើលឃើញពីអ្វីដែលអ្នកជឿអាចមើលឃើញនាពេលបច្ចុប្បន្ននេះទេ។ កំឡុងពេលជិត២០០០ឆ្នាំមកហើយ តាំងពីសម័យភ្នំកាល់វ៉ារី ហើយយើងមិនអាចដឹងថារយៈពេលប៉ុន្មានឆ្នាំទៀតទើបដល់សម័យកាលភ្នំរាជាណាចក្រ។ ព្រះអម្ចាស់ឥឡូវនេះកំពុងតែធ្វើកិច្ចការមួយជាការសំងាត់ក្នុងអង្គទ្រង់ ដែលជាការលាក់កំបាំងក្នុងកំឡុងពេលព្យាការីទាំងនោះ។ ព្យាការីមិនបានដឹងថាអ៊ីស្រាអែលនឹងបដិសេធមិនទទួលស្តេចរបស់ពួកគេទេ ហើយព្រះអម្ចាស់អាចបោះបង់ពួកអ៊ីស្រាអែលចោលខណៈពេលដែលទ្រង់បានបើកទ្វារនៃសេចក្តីជំនឿចំពោះសាសន៍ដទៃ។ សព្វថ្ងៃនេះគឺជាសម័យព្រះគុណដែលជាគំរោងការលាក់កំបាំង។ ប្រសិនបើអ្នករស់នៅសម័យព្យាការីអ្នកមិនអាចស្រាវជ្រាវ ឬរកឃើញពីការលាក់កំបាំងនេះបានទេ *អេភេសូ៣:៩*។ ស្តេចនៃអ៊ីស្រាអែលគឺកំពុងយាងមកម្តងទៀត ប៉ុន្តែការយាងមកលើកទី១នេះគឺជាខ្សែបន្ទាត់នៃការសង្គ្រោះរបស់ទ្រង់នឹងលើកមនុស្សឡើងទៅជួបព្រះយេស៊ូក្នុងលំហអាកាស !

យើងអាននៅក្នុង *១ពេត្រុស ១:១០-១១* ថាព្យាការីបានស្រាវជ្រាវដោយយកចិត្តទុកដាក់ហើយបានស៊ើបអង្កេតអំពីចំនុចទាំងនេះ។ តើអ្វីដែលព្រះអង្គចង់ឱ្យយើងធ្វើនៅពេលយើងមិនយល់អំពីចំនុចនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ *លោកប៉ូល* មានប្រសាសន៍ថាអ្នកនៅ *ក្រុងបេរេន* បានស្រាវជ្រាវព្រះគម្ពីរជារៀងរាល់ថ្ងៃ *កិច្ចការ ១៧:១១*។

ជាចុងក្រោយសំលេងរបស់ព្យាការីបានបញ្ឈប់ពីព្រោះព្រះអម្ចាស់ឈប់មានព្រះបន្ទូលទៅកាន់ពួកគេ។ ព្យាការីដែលស្តាប់បង្គាប់បានសរសេរព្រះបន្ទូលព្រះអង្គនៅក្នុងសញ្ញាចាស់ ពួកគេបានស្រាវជ្រាវហើយសង្ឃឹម និងរង់ចាំការយាងមកដល់របស់ទ្រង់។ *ផ្លូវនៃរាជាណាចក្រ* គឺបត់បែនចុះឡើងមានការខូចខាត និងគ្មានការយកចិត្តទុកដាក់ចំពោះវា។ វាគឺជាផ្លូវធំក្នុងភាពងងឹតនៃអំពើ បាបដែលគ្របដណ្តប់ពិភពលោកក្នុងសម័យដែលស្ងប់ស្ងាត់នោះ។

ក្នុងមេរៀនក្រោយសំលេងមួយនឹងលាន់លឺភ្លាមចេញពីភាពដែលស្ងៀមស្ងាត់។

តើអ្នកបានស្រាវជ្រាវព្រះគម្ពីរជារៀងរាល់ថ្ងៃរឺទេ? បើសិនជាអ្នកមិនទាន់បានធ្វើទេវាគឺជាពេលដែលត្រូវចាប់ផ្តើម។ មានតែព្រះគម្ពីរតែមួយគត់ដែលធ្វើឱ្យយើងស្វែងរកភាពអស្ចារ្យសេចក្តីពិត និងការសន្យាដែលព្រះអម្ចាស់បានប្រទានសំរាប់យើងរាល់គ្នា។ មានតែនៅក្នុងគម្ពីរទេដែលអាចណែនាំយើងឱ្យយើងរស់នៅត្រឹមត្រូវដើម្បីគាប់ព្រះហឫទ័យព្រះអម្ចាស់។

**ខគម្ពីរចងចាំ** កិច្ចការ១៧-១១ ៖ សាសន៍យូដានៅក្រុងនេះមានសន្ដានចិត្តល្អជាងនៅក្រុងថែស្សាឡូនិក ព្រោះគេបានទទួលព្រះបន្ទូលព្រះអង្គដោយចិត្តស្មោះស ហើយពិនិត្យពិច័យមើលព្រះគម្ពីរជារៀងរាល់ថ្ងៃដើម្បីឱ្យដឹងថាសេចក្តីដែលលោកប៉ូល និងលោកស៊ីឡាសមានប្រសាសន៍ប្រាប់ពួកគេពិតជាត្រឹមត្រូវ ឬយ៉ាងណា។

## <u>សំនួររត្រិះរិះ មេរៀនទី១៧</u>

យោងតាមព្រះគម្ពីរ *១ពេត្រុស១:១០,១១* ព្យាការីប្រាប់អំពីចំនុចពីរដែលជាប់ទាក់ ទងនឹងព្រះគ្រីស្ទ។ តើនោះជាអ្វី?

១.......................................................................................................។

២.......................................................................................................។

មានគម្ពីរខ្លះបានអះអាងដូចខាងក្រោម។ ចូរស្វែងរកហើយសរសេរនៅខាងក្រោម ឈ្មោះភ្នំទាំងពីរ។

| | | |
|---|---|---|
| *ទំនុកតម្កើង ៦៩:២* | *ទំនុកតម្កើង២:៤-៥* | *អេសាយ៥៣:៤-៦* |
| *ទំនុកតម្កើង២២:២៩* | *មីកា៥:១* | *ទំនុកតម្កើង២:៦-៨* |

| ភ្នំកាល់វ៉ារី | ភ្នំនៃរាជាណាចក្រ |
|---|---|
| ៣-........................................ . | ..................................................... |
| ៤-........................................ | ..................................................... |
| ៥-........................................ | ..................................................... |

៦-តើអ្វីនៅ *១ពេត្រុស១:១០* និយាយថាព្យាការីកំពុងតែព្យាយាមស្វែងយល់ចំពោះចំនុចទាំងនោះ?..........
..........................................................................................................................................
........................................................................................................................។

៧-តើអ្វីដែលលោកប៉ូលនិយាយអំពីអ្នកស្រុកបេរេន ក្នុងការបញ្ជាក់អោយឃើញថាអ្វីដែលគាត់ចែកចាយទាំងនោះពិតជាត្រឹមត្រូវ? *កិច្ចការ១៧:១១*.......................................................................................
..........................................................................................................................................
.......................................................................................។

៨-តើអ្វីដែលព្រះជាម្ចាស់ចង់ឱ្យយើងធ្វើដើម្បីយល់ពីព្រះបន្ទូលរបស់ទ្រង់? *២ធីម៉ូថេ ២:១៥* ........................

...............................................................................................................................................

............................................................................................................................................................ ។

៩- ហេតុអ្វីបានជាព្យាការីមើលមិនឃើញពីសម័យនៃព្រះគុណ? *អេភេសូ ៣:៥*..........................................

...............................................................................................................................................

..................................................................................................................................... ។

១០-សរសេរខគម្ពីរចងចាំ *កិច្ចការ ១៧:១១* ..........................................................................

..............................................................................................................................................................

.................................................................................................................................... ។

**រំលឹកឡើងវិញ** : ចូរគូសរូបភាពផែនទីមាគ៌ានៃជីវិតដែលយើងបានធ្វើដំណើរក្នុង មេរៀនរបស់យើង ហើយប្រគល់កិច្ចការនេះជាមួយនឹងមេរៀន។

**មេរៀនទី១៨ :** **មើលហ្ន៎!មហាក្សត្ររបស់អ្នកយាងមកដល់ហើយ!**

**ម៉ាថាយ,ម៉ាកុស, លូកា, យ៉ូហាន**

**គំនិតសំខាន់ :** **ដើម្បីបង្រៀនពីអត្តសញ្ញាណរបស់ព្រះគ្រីស្ទជាមួយប្រជាជនរបស់ទ្រង់**

៤០០ឆ្នាំនៃភាពស្ងប់ស្ងាត់! តើព្រះអម្ចាស់ភ្លេចពីសន្យារបស់ទ្រង់ឬ? ស្តេចនឹងយាងមកឬ? ភ្លាមៗសំលេងលេចលឺក្នុងភាពស្ងៀមស្ងាត់! ព្រះអង្គគឺមានព្រះបន្ទូលម្តងទៀតតាមរយៈសំលេងព្យាការី គឺលោក*យ៉ូហានបាទីស្ត* គាត់មានប្រសាសន៍ថា "ចូរកែប្រែចិត្តគំនិតឡើង ត្បិតព្រះរាជនៃស្ថានបរមសុខមកជិតដល់ហើយ... ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ចូរតំរង់ផ្លូវថ្វាយព្រះអង្គ" *ម៉ាថាយ៣:២-៣*។ ផ្លូវនៃរាជាណាចក្រត្រូវតែជុសជុល និងរៀបចំសំរាប់ការយាងមករបស់ព្រះអម្ចាស់។

៣០ឆ្នាំមុនលោកយ៉ូហានបានមកប្រាប់ពីរាជសារនេះ ថាទារកមួយបានកើតនៅទីក្រុងបេថ្លេហឹម។ ឈ្មោះរបស់គាត់ត្រូវបានគេហៅថាយេស៊ូ ដ្បិតទ្រង់យាងមកដើម្បីសង្គ្រោះប្រជាជនរបស់ទ្រង់ឱ្យរួចពីបាប *ម៉ាថាយ ១: ២១-២៣*។ ៣០ឆ្នាំក្រោយមកមនុស្សមួយចំនួនតូចបានលឺដំណឹងអំពីបុត្រាដែលប្រសូត្រនៅបេថ្លេហឹម រហូតដល់លោកយ៉ូហានបាទីស្ត ចែកចាយៈ *ចូរកែប្រែចិត្តគំនិត*។ នៅ*ម៉ាថាយ ៣:៤-៦* អ្នកស្រុកយេរូសាឡឹម អ្នកស្រុកយូដា និងអ្នកស្រុកនៅតំបន់ទន្លេយ័រដាន់ទាំងមូលនាំគ្នាចេញទៅរកលោក។ ពួកគេទទួលសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឱ្យពួកគេក្នុងទន្លេយ័រដាន់។ នេះគឺជាវិធីមួយដែលអ៊ីស្រាអែលបានរៀបចំផ្លូវរួចជាស្រេចសំរាប់ស្តេចរបស់ពួកគេ។

នៅពេលដែលលោកយ៉ូហានឃើញព្រះយេស៊ូដើរតំរង់មករកគាត់ គាត់បានប្រសាសន៍ថា មើលហ្ន៎! លោកនេះហើយជាកូនចៀមរបស់ព្រះអម្ចាស់ដែលដកបាបចេញពីមនុស្សលោក *យ៉ូហាន ១:២៩*។ ភ្លាមៗនេះ*លោកយ៉ូហាន* មិនចង់ធ្វើពិធីជ្រមុជទឹកឱ្យព្រះយេស៊ូទេ ប៉ុន្តែយើងអាចឃើញអ្វីដែលព្រះយេស៊ូឆ្លើយតបក្នុង*ម៉ាថាយ៣:១៤-១៧*។ បន្ទាប់មកព្រះវិញ្ញាណដ៏វិសុទ្ធបាននាំព្រះយេស៊ូទៅកាន់ទីរហោស្ថាននៃស្រុកយូដា ដើម្បីទទួលរងការល្បួងដោយវិញ្ញាណអាក្រក់។ គ្រប់ទាំងការល្បួង ព្រះយេស៊ូបានលើកយកព្រះបន្ទូលរបស់ព្រះអម្ចាស់មកតទល់ ហើយសាតាំងក៏ចាញ់គ្រប់ពេល។

តមកទៀតព្រះយេស៊ូបានចាប់ផ្តើមចែកចាយនៅ *ម៉ាថាយ៤:១៧ ត្បិតព្រះរាជ្យនៃស្ថានបរមសុខនៅជិតបង្កើយ ហើយចូរកែប្រចិត្តគំនិតឡើង*។ ព្រះយេស៊ូបង្ហាញទីសំគាល់ថាទ្រង់ផ្ទាល់ ដែលជាព្រះបុត្រាបេស់ព្រះអម្ចាស់ជាព្រះនៃសេចក្តីពិត។ ទ្រង់គឺជាអង្គដែលព្យាការីបានមានទំនាយទុកមក។ ព្រះអង្គបានធ្វើការអស្ចារ្យជាច្រើនដោយអំណាចព្រះចេស្តាទ្រង់ ធ្វើឱ្យមនុស្សកើតឃ្លង់ជាសះស្បើយ ធ្វើអ្នកខ្វាក់ភ្នែកបានភ្លឺ ទ្រង់បានដើរលើសមុទ្រ ដេញវិញ្ញាណអាក្រក់អោយរលកស្ងប់ ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ។

ព្រះអង្គជ្រើសរើសសាវ័ក១២នាក់និងប្រទានពរដល់ពួកគេដោយព្រះចេស្តាទ្រង់*ម៉ាថាយ១០:១-១០*។ បន្ទាប់មកព្រះអង្គបានចាត់សាវ័កទាំង១២ ដោយមានបទបញ្ជាខុសប្លែកពីអ្នកចែកចាយព្រះបន្ទូលនៅសម័យកាលនេះថាកុំទៅរកសាសន៍ដទៃ ប៉ុន្តែត្រូវទៅស្វែងរកអស់អ្នកដែលវង្វេងក្នុងចំណោមជនជាតិអ៊ីស្រាអែលវិញ។ ពេលធ្វើដំណើរទៅចូរប្រកាស

ថាព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ ចូរមើលអ្នកជំងឺឱ្យបានជា ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ឱ្យមនុស្សឃ្លង់បានស្អាតបរិសុទ្ធ ដេញខ្មោចចេញពីមនុស្ស ។ កុំរកមាសប្រាក់ រឺលុយកាក់ត្បិតអ្នកទទួលអំណាចដោយឥតបង់ថ្លៃដែរ កុំយកអាវពីរបន្លាស់កុំយកស្បែកជើង រឺដំបងទៅជាមួយ ត្បិតអ្នកធ្វើការត្រូវតែទទួលម្ហូបអាហារ *ម៉ាថាយ ១០:៥-១០*។

ថ្ងៃមួយឧប្បត្តិហេតុមួយបានកើតឡើង ។ នៅលើផែនទីរបស់យើង យើងបាននឹងធ្វើដំណើរលើផ្លូវធំនៃរាជាណាចក្រដោយគ្មានការយកចិត្តទុកដាក់ទៅលើសាសន៍ដទៃឡើយ ។ អ៊ីស្រាអែលគឺជាប្រភពនៃព្រះពរតែមួយគត់ដែលព្រះជាម្ចាស់កំពុងធ្វើការចាប់តាំងពីទ្រង់បានបោះបង់សាសន៍ដទៃនៅ*បាបិល*។ នៅពេលព្រះយេស៊ូកំពុងបង្រៀននៅតំបន់មាត់សមុទ្រជិតទីក្រុង*ទីរ៉ូស* និងទី*ក្រុងស៊ីដូន* មានស្ត្រីម្នាក់នៃសាសន៍កាណានមករកទ្រង់ យើងអាចអាននៅ*ម៉ាថាយ១៥:២១-២៨*។ ស្ត្រីនៃសាសន៍ដទៃនេះបានលឺអំពីព្រះចេស្ដាព្រះអម្ចាស់យេស៊ូ ហើយមកដើម្បីសុំការប្រទានពរពីទ្រង់ ។ ព្រះយេស៊ូទតឃើញថានាងមានភាពស្មោះត្រង់ និងជំនឿមុតមាំព្រះអង្គក៏ប្រទានពរដល់នាង ទោះបីវាមិនមែនជាពេលដែលមានទំនាយទុកប្រាកដថាព្រះពរពេញលេញត្រូវបានចែករំលែកទៅសាសន៍ដទៃក្នុងរាជាណាចក្រនោះឡើយ ។

ចូរប្រាប់ប្រជាជនថាព្រះរបស់អ្នកជិតមកដល់ហើយ ។ ហើយទ្រង់គង់នៅលើខ្នងកូនលា*ម៉ាថាយ២១:៥*។ ពួកអ៊ីស្រាអែលបានហៅព្រះយេស៊ូជាអ្នកស្រុកណាសារ៉ែតជាស្តេចរបស់ពួកគេ ហើយក៏អភិសេកទ្រង់ ។ ប៉ុន្តែពួកនាយកបូជាចារ្យ និងអាចារ្យមានការទាស់ចិត្តជាខ្លាំង*ម៉ាថាយ២១:១៥*។ ដូចនេះប្រជាជាតិអ៊ីស្រាអែលមិនបានស្វាគមន៍ចំពោះស្តេចរបស់ពួកគេទៀតឡើយ ។

យើងមើលពីការជ្រមុជរបស់ព្រះយេស៊ូ។ ហេតុអ្វីបានជាទ្រង់ទទួលពិធីជ្រមុជទឹក? ព្រះគម្ពីរមានព្រះបន្ទូលថា "ដើម្បីបំពេញសេចក្ដីសុចរិត" ពិធីជ្រមុជទឹកគឺជាសញ្ញា រឺជារូបភាពមួយទៅកាន់អ៊ីស្រាអែលអំពីការលុបលាងបាបរបស់ពួកគេ*កិច្ចការ២២:១៦*។ ព្រះយេស៊ូទ្រង់គ្មានបាបទាល់តែសោះ ប៉ុន្តែព្រះអង្គយាងមកក្នុងពិភពលោកយើងនេះគឺទ្រង់មកទទួលអំពើបាបជំនួសយើងដែលព្រះអង្គអាចនឹងប្រទានទូវសេចក្ដីសុចរិតគ្រប់លក្ខណៈដល់យើង *ហេព្រើ ២:១៧* ។

ក្នុងមេរៀនយើងបន្ទាប់ទៀត យើងនឹងឃើញពីរបៀបដែលព្រះគ្រិស្ដយាងទៅផ្លូវនៃសេចក្ដីស្លាប់នៅលើឈើឆ្កាងនៃភ្នំកាល់វ៉ារី ដើម្បីបំពេញកិច្ចការចំពោះការទទួលយកអំពើបាបរបស់យើង ។ ហើយឥលូវការងារនេះត្រូវបានបញ្ចប់ហើយ *អ្នកអាចទទួលការសង្គ្រោះបានតាមរយៈការមានសេចក្ដីជំនឿលើព្រះយេស៊ូគ្រិស្ដ*។

**ខគម្ពីរចងចាំ:** *២ កូរិនថូស ៥:២១* ព្រះគ្រិស្ដគ្មានបាបទាល់តែសោះតែព្រះអង្គម្ចាស់បានធ្វើឱ្យទ្រង់ក្លាយជាតួបាបសំរាប់យើងដើម្បីប្រោសយើងឱ្យបានសុចរិតរួមជាមួយព្រះគ្រិស្ដដែរ ។

## សំនួរត្រិះរិះ មេរៀនទី១៨

ចូរបំពេញចន្លោះក្នុងល្បះខាងក្រោម:

១- បន្ទាប់ពី៤០០ឆ្នាំនៃភាពស្ងប់ស្ងាត់ពួកអ៊ីស្រាអែលបានលឺសំលេងនៃ............................................................ ....................មានប្រសាសន៍ថា........................................................................................ *ម៉ាថាយ ៣:១-៣*។

២- អ៊ីស្រាអែលបានរៀបចំសំរាប់ការយាងមកនៃស្ដេចដោយ.................................................................

..................................................................................... *ម៉ាថាយ ៣:៦*។

៣- លោកយ៉ូហានបានមានប្រសាសន៍ថាគាត់ជ្រមុជដោយទឹក ប៉ុន្តែម្នាក់ដែលយាងមកក្រោយគាត់នឹងជ្រមុជដោយ..................................................................................................................... .......*ម៉ាថាយ ៣:១១*។

៤- ព្រះយេស៊ូមានព្រះបន្ទូលថាទ្រង់ត្រូវទទួលជ្រមុជទឹកដើម្បីបំពេញគ្រប់ទាំង...........................................

.................................................................................. *ម៉ាថាយ ៣:១៥*។

៥-ព្រះយេស៊ូបានប្រទានដល់សាវ័ករបស់ទ្រង់នូវអំណាចធ្វើទីសំគាល់អស្ចារ្យ ដើម្បីបង្ហាញថារាជាណាចក្រនៃស្ថានបរមសុខពិតជាជិតមកដល់ហើយ ។ រៀបរាប់ឈ្មោះការអស្ចារ្យទាំងនោះម៉ាថាយ ១០:៨។

.........................................................................................................................................................

.........................................................................................................................................................

........................................................................................................................................................ ។

ចូរមើលឯកសារយោង ហើយឆ្លើយនឹងសំនួរខាងក្រោមៈ

៦-ហេតុអ្វីបានជាព្រះយេស៊ូប្រាប់សាវ័ករបស់ទ្រង់ កុំអោយទៅរកសាសន៍ដទៃ? *ម៉ាកុស ៧:២៧*......................

.........................................................................................................................................................

........................................................................................................................................................ ។

៧-ហេតុអ្វីបានជាចុងក្រោយព្រះយេស៊ូយល់ព្រមនូវសំនូមពរពីស្ត្រីសាសន៍ដទៃ? *ម៉ាថាយ១៥:២៨*.................

.........................................................................................................................................................

........................................................................................................................................................ ។

៨-ហេតុអ្វីបានជាផ្នែកមួយរបស់មាគ៌ានៃជីវិតត្រូវបានហៅថាផ្លូវធំនៃរាជាណាចក្រ? *ម៉ាថាយ២១:១៥*............

.........................................................................................................................................................

........................................................................................................................................................ ។

៩-ហេតុអ្វីបានជាអស់អ្នកដែលរស់សម័យព្រះគុណមិនចាំបាច់ទទួលពិធីជ្រមុជទឹកដើម្បីទទួលភាពសុចរិត? *២កូរិនថូស៥:២១*..................................................................................................................................

........................................................................................................................................................ ។

១០-សរសេរខគម្ពីរចងចាំ ២កូរិនថូស៥:២១ :

.........................................................................................................................................................

........................................................................................................................................................ ។

**មេរៀនទី១៩ :** **ភ្នំកាល់វ៉ារីជាស្រមោលផ្លូវធំនៃរាជាណាចក្រ**

**ម៉ាថាយ-ម៉ាកុស-លូកា-យ៉ូហាន**

**គំនិតសំខាន់ : ដើម្បីបង្រៀនអំពីអត្តសញ្ញាណរបស់អ្នកជឿជាមួយការសុគត និងការរស់ឡើងវិញនៃព្រះគ្រីស្ទ ។**

យើងកំពុងមកកាន់តែជិតនឹងកំពូលភ្នំទីមួយដែលព្យាការីបានឃើញ។ គេហៅភ្នំនេះថា*ភ្នំកាល់វ៉ារី* ។ នៅក្នុងមេរៀនមុនយើងបានឃើញលោក*យ៉ូហាន* កំពុងរៀបចំផ្លូវ សំរាប់ស្តេចដោយហៅជនជាតិអ៊ីស្រាអែលសារភាពទោសកំហុស និងធ្វើពិធីជ្រមុជទឹក។ បន្ទាប់មកយើងបានឃើញ *ការជ្រមុជទឹករបស់ព្រះគ្រិស្ទមានលក្ខណៈអស្ចារ្យ* ដែលព្រះអង្គបានបង្ហាញអង្គទ្រង់ផ្ទាល់សំរាប់ប្រជាជនអ៊ីស្រាអែល។ ដោយព្រះយេស៊ូបានបង្ហាញអង្គទ្រង់ផ្ទាល់គឺជាអង្គតែមួយជាមួយប្រជាជនរបស់ព្រះអង្គ។ ថ្ងៃនេះយើងនឹងឃើញថាព្រះគ្រិស្ទបានធ្វើការជ្រមុជមួយទៀតនៅលើ *ភ្នំកាល់វ៉ារី* ការជ្រមុជមួយនេះគ្មានទឹកដូចជាលោក*យ៉ូហាន* បានជ្រមុជអោយទ្រង់នោះទេ តែជា*ការជ្រមុជក្នុងសេចក្តីស្លាប់* ។

មុនពេលទ្រង់ចូលទៅក្រុងយេរូសាឡឹមជិះលើខ្នងលា ព្រះយេស៊ូបានសួរទៅសាវ័ករបស់ទ្រង់ថា "តើមនុស្សទាំងឡាយថាបុត្រមនុស្សជានរណា? " *ម៉ាថាយ ១៦:១៣-១៩*។ និយាយអំពីដំណើររឿងនេះ។ ព្រះគ្រីស្ទបានហៅប្រជាជនអ៊ីស្រាអែលដែលមានជំនឿថាជាក្រុមជំនុំរបស់ទ្រង់ *ម៉ាថាយ១៦:១៨* ។ ពាក្យថាក្រុមជំនុំមានន័យថាជាក្រុមមួយដែលបានត្រាស់ហៅ។ នៅក្នុងរាជាណាចក្រអ៊ីស្រាអែល និងជាជាតិសាសន៍នៃពួកបូជាចារ្យ ដើម្បីដឹកនាំសាសន៍ដទៃទៅរកព្រះគ្រិស្ទជាស្តេច។ ដូច្នេះក្រុមមួយដែលញែកចេញនឹងក្លាយជាក្រុមជំនុំ។ រាជាណាចក្រក្រុមជំនុំបានសាងសង់ពឹងផ្អែកលើព្រះគ្រិស្ទផ្ទាល់ដែលជាសសរទ្រូង ហើយ*លោកពេត្រុស* បានទទួលកូនសោរនៃរាជាណាចក្រ និងអញ្ជើញអ្នកដទៃទៀតអោយចូល។

បន្ទាប់មកទៀតព្រះគ្រីស្ទបានធ្វើការសន្យានេះទៅ*លោកពេត្រុស* គាត់បានចាប់ផ្តើមប្រកាសថាទ្រង់ត្រូវតែសុគតមុននឹងរាជាណាចក្របានចាប់ផ្តើមបង្កើតឡើង *ម៉ាថាយ១៦:២១*។ នៅក្នុង *ម៉ាថាយ២០:២០-២៣* ព្រះគ្រីស្ទមានព្រះបន្ទូលពីការឈឺចាប់របស់ទ្រង់ និងការសុគតដូចជាការជ្រមុជមួយ។ នេះជាការជ្រមុជនៃសេចក្តីស្លាប់របស់ព្រះគ្រិស្ទ*លូកា១២:៥០*។ ពេលវេលាកាន់តែជិតមកដល់ហើយជាពេលដែលព្រះសង្គ្រោះជិតនឹងទទួលការឈឺចាប់ដោយការជ្រមុជក្នុងសេចក្តីស្លាប់របស់ទ្រង់។

ថ្ងៃមួយព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័កថា "អ្នកដឹងថាបន្ទាប់ពីពីរថ្ងៃជាពិធីបុណ្យរំលង (ការចងចាំពីបុណ្យរំលងនៅលើផ្លូវសន្យា) ហើយកូនមនុស្សត្រូវគេក្បត់គេនឹងបញ្ជូនទ្រង់ទៅឆ្កាង *ម៉ាថាយ២៦:១-២*។ ខណៈដែលព្រះយេស៊ូ និងពួកសាវ័កហូបអាហារនៅក្នុងពិធីបុណ្យចំលងព្រះយេស៊ូមានព្រះបន្ទូលថាម្នាក់ក្នុងចំណោមអ្នករាល់គ្នានឹងក្បត់ខ្ញុំ *ម៉ាថាយ ២៦:២១-២៥*។ បន្ទាប់ពីពួកគេច្រៀងចំរៀងពួកគេបានចេញទៅក្រៅទៅកាន់*ភ្នំអូលីវ* ទៅសួន*កេតសេម៉ានី* ។ វាជាកន្លែងដែលព្រះយេស៊ូអធិដ្ឋាន : ឱព្រះបិតាអើយ! ប្រសិនបើបានសូមអោយពែងនៃទុក្ខលំបាកនេះចេញឆ្ងាយពីទូលបង្គំទៅ *ម៉ាថាយ ២៦:៣៦-៤៥* ។

ខណៈពេលទ្រង់កំពុងមានព្រះបន្ទូលទាហានបានចូលមកចាប់ទ្រង់ ដែលដឹកនាំដោយសាវ័ករបស់ទ្រង់គឺ*លោកយូដាសអ៊ីស្ការីយ៉ុត ម៉ាថាយ២៦:៤៧-៥៦* ។ ព្រះយេស៊ូបាននាំទៅជួប*លោកកៃផាស* ដែលជាមហាបូជាចារ្យ ហើយបានធ្វើការចោទប្រកាន់ដោយប្រឌិតរឿងមិនពិត *ម៉ាថាយ ២៦: ៥៧-៦៨* ។ បន្ទាប់មកព្រះយេស៊ូត្រូវបានបញ្ជូនទៅ*លោកពីឡាត* ជាអ្នកដែលបានសួរថា តើអ្នកជាស្តេចនៃសាសន៍យូដាវឺ? ព្រះយេស៊ូឆ្លើយថា "ត្រូវដូចលោកមានប្រសាសន៍មែន " ទាហានបានបំពាក់រ៉ូបពណ៌ក្រហម ហើយយកម្កុដបន្លាមកបំពាក់លើព្រះកេសារទ្រង់ ហើយចងត្រែងនៅលើដៃទ្រង់។ ពួកគេចំអកដាក់ទ្រង់ទាំងស្រែកហៅថា...! ស្តេចនៃសាសន៍យូដា! ពួកគេស្តោះទឹកមាត់ដាក់ទ្រង់ ហើយវាយកេសារទ្រង់។ ទាំងអស់នេះបានកំពុងកើតឡើង ដូចជាព្យាការីបានទាយទុកនូវការឈឺចាប់ នៅលើភ្នំ *កាល់វ៉ារី* ។

ទីបញ្ចប់ពួកគេបានបង្ខំព្រះយេស៊ូឡើងទៅភ្នំលលាដ៏ក្បាល ដែលមានឈ្មោះកុលកូថា ពួកគេដាក់ទឹកខ្មេះ និងជាតិជូរ ហើយបានបោះដែកគោលឆ្កាងទ្រង់នៅលើឈើឆ្កាង *ម៉ាថាយ២៧:៣៣-៣៧* ។ ពួកទាហានបានដាក់ផ្លាកមួយលើសិរសាររបស់ទ្រង់ដែលសរសេរថានេះគឺជាព្រះយេស៊ូជាស្តេចនៃសាសន៍យូដា។ មានចោរពីរនាក់បានឆ្កាងនៅសងខាងព្រះយេស៊ូ។ ម្នាក់ក្នុងចំណោមពួកគេបានជ្រើសរើសផ្លូវនៃជីវិតម្នាក់ទៀតបានជ្រើសរើសផ្លូវនៃសេចក្តីស្លាប់។ ចោរដែលបានសារភាពអំពើ បាបទូលអង្វរថា *"សូមទ្រង់ចងចាំខ្ញុំផង"* ខណៈពេលដែលចោរម្នាក់ទៀតបានប្រមាថទ្រង់ *លូកា ២៣:៣៩-៤៥*។ បន្ទាប់មកព្រះយេស៊ូបានអធិដ្ឋានថា *"វាគឺបានបញ្ចប់សព្វគ្រប់ហើយ"* ទ្រង់ថ្វាយព្រះវិញ្ញាណនៃទ្រង់វិញ *យ៉ូហាន១៩:៣០*។ ពេលល្ងាចនោះ*លោកយូសែប* ជាអ្នកស្រុក*អារីម៉ាថា* បានសុំលោកពីឡាតយកព្រះសពព្រះយេស៊ូទៅបញ្ចុះនៅក្នុងផ្នូរថ្មី។ ហើយយកថ្មដ៏ធំមួយទៅឃាំងនៅមាត់ទ្វារផ្នូរ *ម៉ាថាយ២៧:៥៧-៦០*។ ស្តេចនៃសេចក្តីសន្យាបានសុគតហើយអ្នកគ្រប់គ្រងអ៊ីស្រាអែលបានគិតថាពួកគេគឺមានជ័យជំនះលើព្រះយេស៊ូជារៀងរហូត។

ថ្ងៃទី១បានកន្លងផុតទៅថ្ងៃទីពីរក៏បានកន្លងផុតទៅ ហើយនៅព្រឹកថ្ងៃទី៣ផ្នូរបានរបើកទ្វារព្រះសង្គ្រោះរបស់យើងមានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ *ម៉ាថាយ២៨:១-៦*។

តើព្រះយេស៊ូសមនឹងស្លាប់វឺទេ? ទេ! ថ្លៃឈ្នួលនៃអំពើបាបគឺសេចក្តីស្លាប់ ប៉ុន្តែព្រះយេស៊ូមិនដែលមានអំពើបាបសោះ។ ទ្រង់មានជីវិតជារៀងរហូតសូមយើងមើលៈ

១.វាជាអំពើបាបរបស់យើងដែលព្រះយេស៊ូត្រូវគេបោះដែកគោលនៅលើឈើឆ្កាង *១កូរិនថូស១៥:៣-៤*។ ទ្រង់បានលីអំពើបាបរបស់យើង ហើយបានស្លៀករ៉ូបពណ៌ក្រហមនៃការបន្ទាបខ្លួន ដូច្នេះដើម្បីអោយយើងអាចស្លៀករ៉ូបនៃសេចក្តីសុចរិតបាន។

២. ព្រះយេស៊ូបានពាក់ម្កុដបន្លា ដូច្នេះដើម្បីយើងអាចពាក់ម្កុដនៃសេចក្តីសុចរិត *២ធីម៉ូ ថេ៤:៨*។

៣.ព្រះយេស៊ូបានស្លាប់ដោយសេចក្តីស្លាប់របស់យើង។ បន្ទាប់មកទ្រង់រស់ឡើងវិញ ហើយឥឡូវទ្រង់បានផ្តល់អោយយើងរស់ឡើងវិញជាមួយទ្រង់ *រ៉ូម៦:៤*។ ពេលយើងទទួលជឿថាព្រះយេស៊ូជាព្រះសង្គ្រោះព្រះវិញ្ញាណបរិសុទ្ធនឹងជ្រមុជយើងទៅក្នុងរូបកាយនៃព្រះគ្រិស្តដែលក្រុមជំនុំសព្វថ្ងៃនេះជារបស់ព្រះគ្រិស្ត។ យើងបានទទួលអត្តសញ្ញាណជាមួយព្រះគ្រិស្ត ដូច្នេះការជ្រមុជនៃសេចក្តីស្លាប់របស់ទ្រង់ក្លាយជាការជ្រមុជរបស់យើង។ ការបញ្ចុះសពរបស់ទ្រង់គឺការបញ្ចុះ

សពរបស់យើង ហើយការរស់ឡើងវិញរបស់ទ្រង់គឺជាការរស់ឡើងវិញរបស់យើងដែរ។ ដូច្នេះការកើតជាថ្មីនៅក្នុងព្រះគ្រីស្ទយើងគួរតែដើរក្នុងភាពថ្មីនៃជីវិត។

**ខគម្ពីរចងចាំ:** *រ៉ូម៦:៤* "ហេតុនេះដោយពិធីជ្រមុជដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ ដូច្នេះព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណាយើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ"។

## <u>សំនួររត្រិះរិះ មេរៀនទី១៩</u>

ចូរមើលប្រយោគខាងក្រោមនេះខុស រឺត្រូវ។ ស្វែងរកក្នុងព្រះគម្ពីរហើយសរសេរនៅ ក្នុងវង់ក្រចក ( ) សរសេរអក្សរ (ត) បើនោះជា ប្រយោគ ត្រូវ ហើយសរសេរ អក្សរ (ខ) បើប្រយោគនោះខុស។

១.( ) ព្យាការីបានឃើញព្រះគ្រីស្ទឈឺចាប់សំរាប់អំពើបាបរបស់យើងនៅលើភ្នំកាល់វ៉ារី *ទំនុកតំកើង ២២: ១៦*។

២.( ) ព្រះគ្រីស្ទមានព្រះបន្ទូលពីការយាងមកជ្រមុជក្នុងសេចក្តីស្លាប់ *ម៉ាថាយ២០:២២*។

៣.( ) លោកពីឡាតបានសួរព្រះយេស៊ូថាតើទ្រង់ជាស្តេចនៃពិភពលោកទាំងមូលរឺ? *ម៉ាថាយ២៧:១១*។

៤.( ) ព្រះគ្រីស្ទសុគតព្រោះទ្រង់បានប្រព្រឹត្តិអំពើបាប *១កូរិនថូស ១៥:៣,ហេប្រឺ៧: ២៦*។

៥.( ) ពេលណាយើងទទួលព្រះយេស៊ូជាព្រះសង្គ្រោះយើងនឹងបានជ្រមុជក្នុងសេចក្តីស្លាប់ របស់ទ្រង់ *រ៉ូម ៦:៣-៤*។

៦.( ) គ្រាន់តែព្រះវិញ្ញាណនៃព្រះគ្រីស្ទដែលងើបឡើងពីផ្នូរ *លូកា ២៤:៣៧-៣៩*។

៧.( ) យើងមិនគ្រាន់តែជ្រមុជក្នុងសេចក្តីស្លាប់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏រស់ឡើងវិញជាមួយទ្រង់ នៅភាពជាជីវិតថ្មីផងដែរ *រ៉ូម៦:៤*

៨.( ) ការជ្រមុជនៃព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឱ្យយើងក្លាយជាសមាជិកនៃក្រុមជំនុំនៅលើ ផែនដីនេះ *១កូរិនថូស ១២:១៣*។

៩.( ) សរសេរពណ៌នាសង្ខេបខ្លីនៃការឆ្កាងព្រះយេស៊ូគ្រីស្ទ *ម៉ាថាយ ២៧:២៧-៥០*។

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

...............។

១០.សរសេរខគម្ពីរចងចាំ: *រ៉ូម៦:៤*

........................................................................................................................................

........................................................................................................................................

.......................................................................................................................................។

## មេរៀនទី២០ : លោកពេត្រុសគ្រប់គ្រងចរាចរណ៍លើផ្លូវធំនៃរាជាណាចក្រ

**កិច្ចការ ១-៧**

**គំនិតសំខាន់ :** **បង្រៀនពីការទទួលខុសត្រូវនៃអ្នកជឿដើម្បីជាទីបន្ទាល់ សំរាប់ព្រះគ្រីស្ទ**

ថ្ងៃមួយដែលពេញដោយអំណរ ជាពេលដែលពួកសាវ័កបានទទួលដំណឹងថា *ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ*។ ទ្រង់បានបង្ហាញអង្គទ្រង់មានព្រះជន្មរស់អោយ *មនុស្សជាង៥០០នាក់* ឃើញនៅចំណោមពួកសាវ័ករបស់ទ្រង់ ហើយមានព្រះបន្ទូលទៅពួកគេពីរាជាណាចក្រនៃព្រះជាម្ចាស់ *១កូរិនថូស១៥:៦*។ ពេលដែលពួកសាវ័កបានជួបជុំគ្នាពួកគេបានសួរទ្រង់ថាលោកម្ចាស់ តើព្រះអង្គនឹងធ្វើអោយរាជាណាចក្រអ៊ីស្រាអែលកើតឡើងម្តងទៀតនៅពេលនេះរឺ? ទ្រង់មានព្រះបន្ទូលតបទៅវិញថា" *ឯពេលវេលាដែលព្រះបិតាបានកំណត់ទុកដោយអំណាចរបស់ព្រះអង្គផ្ទាល់អ្នករាល់គ្នាមិនបាច់ដឹងទេ " ប៉ុន្តែអ្នករាល់គ្នានឹងទទួលឬទ្ធានុភាពមួយគឺឬទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ ហើយអ្នករាល់គ្នានឹងធ្វើជាទីបន្ទាល់របស់ខ្ញុំទាំងនៅក្រុងយេរូសាឡឹមក្នុងស្រុកយូដាទាំងមូលក្នុងស្រុកសាម៉ារី និង រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី" កិច្ចការ១:៦-៨*។

ព្រះជាម្ចាស់បានអោយឱកាសមួយដល់អ៊ីស្រាអែលទទួលស្គាល់ព្រះរបស់ពួកគេរស់ឡើងវិញជាមូលដ្ឋានមួយសំរាប់បង្កើតមាគ៌ានៃរាជាណាចក្រដែលនាំមកនូវរាជាណាចក្រ ពីព្រោះថាមានតែផ្លូវសន្យាដែលអាចធ្វើអោយការប្រទានពររបស់ព្រះជាម្ចាស់អាចមកលើពិភពលោកទាំងមូល។ ហេតុអ្វីបានព្រះជាម្ចាស់ដាក់ព្រះគុណជាច្រើន និងអោយអ៊ីស្រាអែលទទួលឱកាសដើម្បីសារ ភាពអំពើបាបរបស់ខ្លួនបន្ទាប់ពីពួកគេបានឆ្កាងរាជបុត្រារបស់ទ្រង់? ពីព្រោះ :

១. ព្រះគ្រីស្ទបានអធិដ្ឋាននៅលើឈើឆ្កាងថា "ព្រះបិតាអើយ សូមលើកលែងទោសអោយពួកគេផង" *លូកា ២៣:៣៤*

២. ព្រះជាម្ចាស់បានសន្យាព្រះគ្រិស្តនឹង នាងអេវ៉ា លោកអាប្រាហាម លោកអ៊ីសាក លោកយ៉ាកុប ស្តេចដាវីឌ ហើយអ្នកផ្សេងៗទៀតដែលតាមរយៈពូជពង្សរបស់ពួកគេ ហើយតាមរយៈជាតិសាសន៍អ៊ីស្រាអែលពិភពលោកទាំងមូលនឹងបានទទួលព្រះពរ។

៣. ព្រះជាម្ចាស់ចង់អោយការសាកល្បងចុងក្រោយមួយចំពោះអ៊ីស្រាអែល ដើម្បីឱ្យឃើញពីចិត្តរបស់ពួកគេ។ ពួកគេច្រានចោលព្រះជាម្ចាស់កាលពីអតីតកាលដែលពួកគេបានជ្រើសរើសយកស្តេចមួយ និងរូបបដិមាហើយពួកគេបានឆ្កាងព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយឥឡូវនេះព្រះជាម្ចាស់ចង់ឃើញអ្វី ដែលពួកគេនឹងធ្វើពេលដែលចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមក។

នៅថ្ងៃបុណ្យទី៥០ថ្ងៃបន្ទាប់ពីការឆ្កាងអ្នកជឿ១២០នាក់ប្រជុំគ្នានៅបន្ទប់ជាន់លើដើម្បីអធិដ្ឋាន។ ព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញហើយមានព្រះបន្ទូលថា "ស្នាក់នៅក្រុងយេរូសាឡឹមរហូតដល់..." *លូកា២៤:៤៩*។ ភ្លាមៗនោះសំលេងបានចេញមកពីឋានសួគ៌ *កិច្ចការ២:១-១៤*។ ពេលនោះ *លោកពេត្រុស* បានក្រោកឈរឡើង ហើយនិយាយទៅពួកយូដា

ទាំងអស់នៅទីក្រុងយេរូសាឡឹមដោយក្ដុកក្ដួលក្នុងចិត្ត... *"នេះគឺជាអ្វីដែលបានសន្យា!"* យើងប្រៀបធៀប *កិច្ចការ២:១៥-២១* ជាមួយ *យ៉ូអែល២: ២៨-៣២*។ ព្រះគ្រិស្តមានព្រះបន្ទូលរួចហើយថា *លោកពេត្រុស* ជាមនុស្សម្នាក់ដែលប្រើកូនសោនៃរាជាណាចក្រ។ នៅថ្ងៃបុណ្យទី៥០ *ជនជាតិយូដាប្រហែល ៣០០០នាក់* បានមកក្នុងការអញ្ជើញរបស់លោកពេត្រុស ហើយអ៊ីស្រាអែលបានទទួលឱកាសម្ដងទៀតដើម្បីកែប្រែចិត្ត និងទទួលការជ្រមុជទឹកសំរាប់ការអត់ទោសនៃអំពើបាប ដែលគេបានប្រព្រឹត្ត *កិច្ចការ២:៣៨*។

ពួកសាវ័កនិងពួកគេទាំងអស់ ដែលបានជឿនឹងបានទទួលអំណាចនៃសេចក្ដីសន្យា។ ពួកគេបានចាប់ផ្ដើមធ្វើទីសំគាល់អស្ចារ្យនៅក្នុងនាមព្រះគ្រិស្តដែលមានព្រះជន្មរស់ឡើងវិញ *កិច្ចការ៣: ១-១១* ។

ឥឡូវនេះហាក់ដូចជាពេលល្អបំផុតសំរាប់ស្ដេចយាងមកសារជាថ្មី *កិច្ចការ ៣:១៩-២១* ប៉ុន្តែមិនទាន់នៅឡើយទេ។ តើអោយអ្នកគ្រប់គ្រងជាអ្នកឆ្កាងព្រះគ្រិស្តទទួលទីបន្ទាល់នៃព្រះវិញ្ញាណដ៏វិសុទ្ធតាមរយៈពួកសាវ័កយ៉ាងដូចម្ដេច? ពួកគេនៅតែមិនទាន់រៀបចំមាគ៌ានៃរាជាណាចក្រអោយរួចរាល់សំរាប់ស្ដេចនៅឡើយ។ អព្ភូតហេតុដំបូងបំផុតបានធ្វើអោយពួកគេចាប់ផ្ដើមធ្វើការបៀតបៀនពួកសាវ័ក។ មហាបូជាចារ្យអ្នកគ្រប់គ្រងព្រះវិហារគណៈសាឌូស៊ីទាំងអស់រៀបផែនការសំលាប់ពួកអ្នកជឿ *កិច្ចការ៤:១-៣ កិច្ចការ៥:១៨*។

ទីបញ្ចប់ពួកគេបានចោលដុំថ្មសំលាប់ *លោកស្ទេផាន* ដែលពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលដែលគាត់អធិដ្ឋាន *កិច្ចការ៧*។ ដោយភាពត្រឹមត្រូវផ្ទាល់ *លោកសូល* បានឈរនៅពេលដែលពិជឃាតបានដាក់សំលៀកបំពាក់របស់ពួកគេនៅក្បែរជើងរបស់គាត់។ ការអធិដ្ឋានរបស់ *លោកស្ទេផាន* និយាយពីការលើកលែងសំរាប់អំពើដែលពួកគេបានប្រព្រឹត្តនេះ។

តើអ្វីដែលព្រះជាម្ចាស់នឹងធ្វើឥលូវនេះ ចាប់តាំងពីប្រជាជនទាំងនោះបដិសេធការរស់ឡើងវិញរបស់ព្រះជាម្ចាស់ និងប្រឆាំងនឹងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់? ព្រះយេស៊ូមានទំនាយពីការបដិសេធរបស់ពួកអ៊ីស្រាអែលចំពោះទ្រង់ *ម៉ាថាយ២១:៤២-៤៦*។ ទ្រង់បានមានព្រះបន្ទូលថាពាក្យដែលប្រឆាំងនឹងទ្រង់អាចអត់ទោសអោយបាន។ តែការប្រមាថប្រឆាំងព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចអត់ទោសអោយឡើយ *ម៉ាថាយ១២:៣១*។ ម្ដងទៀតអ្នកមិនជឿនឹងបិទចរាចរណ៍នៅ *លើមាគ៌ានៃរាជាណាចក្រ* ដូចព្រឹត្តិការណ៍ដែលបានកើតឡើងនៅ *ការដេសបានា* នៅក្នុងទីរហោស្ថាន។ អ្នកមិនជឿតែងតែនាំយកទុក្ខព្រួយ និងបញ្ហា ប៉ុន្តែពួកសាវ័កបានឃើញព្រះគ្រីស្ទរស់ឡើងវិញដោយសារពួកគេបានមើលឃើញទ្រង់និងក្លាយជាទីបន្ទាល់ពេញដោយអំណាចចេស្ដា។

សព្វថ្ងៃនេះយើងដែលជាអ្នកជឿរស់នៅលើអាកាសយានដ្ឋាននៃព្រះគុណ យើងមិនបានឃើញព្រះគ្រីស្ទដោយផ្ទាល់ភ្នែករបស់យើងដូចពួកសាវ័ករបស់ទ្រង់ទេ ប៉ុន្តែយើងបានកត់ត្រាទុកពីសេចក្ដីស្លាប់របស់ទ្រង់ និងការរស់ឡើងវិញនៅក្នុងព្រះគម្ពីរ។ ព្រះជាម្ចាស់មានព្រះហឫទ័យអោយយើងជឿលើព្រះបន្ទូលទ្រង់ ហើយក្លាយជាទីបន្ទាល់នៃអ្វីដែលនៅក្នុងព្រះបន្ទូល។

លោកពេត្រុសបានក្លាយជាប៉ូលីសចរាចរណ៍ដ៏ល្អម្នាក់។ គាត់បានចង្អុលទៅពួកយូដាថាព្រះគ្រិស្តជាផ្លូវនៃការសង្គ្រោះ។ តើអ្នកជាប៉ូលីសចរាចរណ៍ប្រភេទណា? ព្រះជាម្ចាស់មានព្រះហឫទ័យឱ្យយើងម្នាក់ៗដឹកនាំប្រជាជនឡើងទៅ

អាកាសយាននៃការសង្គ្រោះ។ លោកពេត្រុសបានអធិប្បាយ "*គ្មានការសង្គ្រោះណាមួយក្រៅពីអង្គទ្រង់នោះឡើយ* " *កិច្ចការ៤:១២*។

**ខគម្ពីរចងចាំ:** *កិច្ចការ៤:១២* "ក្រៅពីព្រះយេស៊ូគ្មាននរណាម្នាក់អាចសង្គ្រោះមនុស្ស បានទាល់តែសោះ ដ្បិតនៅក្រោមមេឃនេះព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមក មនុស្សដើម្បីសង្គ្រោះយើងនោះឡើយ"។

## <u>សំនួររត្រិះរិះ មេរៀនទី២០</u>

ចូរផ្ទៀងមើលព្រះគម្ពីរ ហើយអ្នកនឹងស្វែងរកចម្លើយទៅតាមសំនួរ សួរថា*តើជាអ្វី* ។

១. អ្វីដែលពួកសាវ័កបានសួរព្រះអម្ចាស់យេស៊ូអំពីរាជាណាចក្រពេលដែលទ្រង់បានលេចឡើងចំពោះពួកគេបន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់? *កិច្ចការ ១:៦*...................................

.....................................................................................................................

.....................................................................................................................

..........................................។

២. អ្វីដែលព្រះយេស៊ូបានឆ្លើយតប? *កិច្ចការ១:៧*.......................................................................

.....................................................................................................................

.....................................................................................................................។

៣. អ្វីដែលព្រះយេស៊ូប្រាប់ពួកសាវ័កថាគេនឹងបានទទួលពេលព្រះវិញ្ញាណដ៏វិសុទ្ធយាង មកសណ្ឋិតលើពួកគេ? កិច្ចការ១:៨..........................................................................................................

.....................................................................................................................

.....................................................................................................................។

៤. តើពួកសាវ័កបានក្លាយជាអ្វី? កិច្ចការ១:៨ ........................................................................

.....................................................................................................................

.....................................................................................................................។

៥. តើលោកពេត្រុសបានប្រាប់អ្វីអោយជនជាតិអ៊ីស្រាអែលធ្វើនៅ *ថ្ងៃបុណ្យទី៥០?* កិច្ចការ២:៣៨..........................................................................................................

.....................................................................................................................

.....................................................................................................................។

៦. អ្វីដែលជាមូលហេតុព្រះជាម្ចាស់ប្រទានឱកាសម្តងទៀតដល់អ៊ីស្រាអែលសារភាព អំពើបាបរបស់ខ្លួនបន្ទាប់ពីពួកគេឆ្កាងព្រះគ្រីស្ត? *លូកា២៣:៣៤*..................................................................

.......................................................................................................................................................

.......................................................................................................................................................។

៧. អ្វីជាការសន្យាចំពោះលោកពេត្រុសដែលបណ្តាលអោយគាត់ ក្លាយទៅជាអ្នកថែរក្សាទ្វារនៃរាជាណាចក្រ? *ម៉ាថាយ១៦:១៩*.......................................................................................................................

.......................................................................................................................................................។

៨. តើការសន្យាអ្វីសំរាប់យើងដែលជាបំណងចិត្តចំពោះការងារសំរាប់ព្រះជាម្ចាស់របស់យើងដូចដែល*លោកពេត្រុស*ធ្លាប់បានធ្វើ? ១កូរិនថូស៣:៨.......................................................................................................

.......................................................................................................................................................។

៩. តើយើងជាអ្នកនៅក្រោមព្រះគុណមានព្រះរាជសារអ្វីសំរាប់ការធ្វើដំណើរទៅ ក្នុងប្រលានយន្តហោះនៃព្រះគុណហើយអញ្ជើញមនុស្សទៅយាននៃការសង្គ្រោះ? *រ៉ូម១០:៩-១០* .......................................................................

.......................................................................................................................................................

.......................................................................................................................................................។

១០. សរសេរខគម្ពីរចងចាំៈ កិច្ចការ៤:១២

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................។

**មេរៀនទី២១ :** **ផ្លូវនៃសាសន៍ដទៃភ្ជាប់ជាមួយផ្លូវធំនៃរាជាណាចក្រ**

**កិច្ចការ ៨-៩**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញពីការត្រាស់ហៅរបស់ព្រះគ្រីស្ទក្នុងការបំរើ**

នៅពេលយើងចាប់ផ្តើមការធ្វើដំណើររបស់យើងនៅថ្ងៃនេះ យើងត្រូវតែងាកមកមើលជ្រុងនៃការភាន់ច្រឡំ។ នៅទីនោះពួកគេបានបោះបង់ព្រះជាម្ចាស់ ដូច្នេះហើយព្រះជាម្ចាស់ក៏បានបោះបង់ចោលពួកគេវិញ។ បន្ទាប់មកព្រះជាម្ចាស់បានជ្រើសរើសបុរសម្នាក់គឺ*អាប់រ៉ាម* ដើម្បីចាប់ផ្តើមនៅការទាក់ទងមួយថ្មីជាមួយមនុស្ស។ មនុស្សទាំងអស់បានងាកទៅរកផ្លូវនៃសាសន៍ដទៃ គឺមានតែ*អាប់រ៉ាម* ប៉ុណ្ណោះដែលបានដើរតាមព្រះជាម្ចាស់នៅលើ*ផ្លូវសុទ្ធា*។ មេរៀននេះចាប់ផ្តើមលើ*ផ្លូវធំនៃរាជាណាចក្រ* ហើយយើងនឹងឃើញថាអ៊ីស្រាអែលបដិសេធជាបន្តបន្ទាប់នូវការផ្តល់អោយនៃរាជាណាចក្ររបស់ព្រះជាម្ចាស់ និងការត្រាស់ហៅសាវ័កថ្មីមួយរបស់ព្រះជាម្ចាស់គឺមិនមែនម្នាក់ក្នុងចំណោមសាវ័កទាំង១២នោះទេ ដើម្បីចាប់ផ្តើមអ្វីមួយថ្មីសំរាប់ទាំងសាសន៍យូដា និងសាសន៍ដទៃ។

នៅពេល*ស្ទេផាន* ត្រូវបានត្រូវគេគប់ដុំថ្មសំលាប់នៅទីនោះមានបុរសម្នាក់បានឈរនៅក្បែរ និងយាមសំលៀកបំពាក់របស់ពួកអ្នកគប់ដុំថ្មនោះ។ បុរសនោះគឺ*លោកសូល* ជាអ្នកចេះដឹងជាតិយូដា និងជាសិស្សម្នាក់របស់គ្រូដ៏ល្អនៅ*ភីលីស្ទីន*។ គាត់ជាគណៈផារីស៊ីម្នាក់ដែលគ្មានការភ័យខ្លាច ហើយគាត់មុតមាំលើសាសនាយូដា។ បន្ទាប់ពីការបញ្ចុះសព*លោកស្ទេផាន* *លោកសូល*បានចាប់ផ្តើមបំផ្លាញក្រុមជំនុំដោយគាត់ចូលទៅគ្រប់ផ្ទះហើយចាប់បង្ខំមនុស្សដែលជឿលើព្រះយេស៊ូទាំងប្រុសទាំងស្រីទៅដាក់ក្នុងគុក *កិច្ចការ ៨:១-៤* ។ ប៉ុន្តែបន្ទាប់ពីយើងអានអំពីការផ្លាស់ប្រែរបស់*លោកសូល* ចំពោះព្រះគ្រិស្តនៅលើផ្លូវទៅទីក្រុង*ដាម៉ាស* នៅក្នុងគម្ពីរ *កិច្ចការ៩:១-១៦* ។ ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់*លោកអាណាណាស* អំពី*លោកសូលថា* *"សូលគឺត្រូវបានជ្រើសរើសអោយទៅប្រាប់ប្រជាជាតិ និងស្តេចព្រមទាំងជនជាតិអ៊ីស្រាអែលអោយស្គាល់ឈ្មោះខ្ញុំ " កិច្ចការ ៩:១៥* ។

ដូច្នេះ*លោកសូល*ត្រូវបានជ្រើសរើស ដើម្បីនាំយកព្រះនាមព្រះអម្ចាស់ទៅក្នុងចំណោមសាសន៍ដទៃ ស្តេច និងកូនចៅអ៊ីស្រាអែល។ *លោកសូល* ត្រូវបានជ្រើសរើសអោយរងទុក្ខលំបាក ដើម្បីព្រះនាមព្រះអម្ចាស់ ប៉ុន្តែក្រោយមកគាត់បានសរសេរថាគាត់បានទទួលអភ័យឯកសិទ្ធិមួយ ដើម្បីឈឺចាប់សំរាប់ជាប្រយោជន៍របស់ព្រះគ្រីស្ទ *ភីលីព១:១៩* ។

ភ្លាមនោះ*លោកសូល* បានចាប់ផ្តើមចែកចាយពីព្រះគ្រីស្ទនៅក្នុងសាលាប្រជុំនានាប្រាប់ ពួកយូដាថាព្រះយេស៊ូជាបុត្រានៃការសន្យារបស់ព្រះជាម្ចាស់។ អស់អ្នកដែលបានលឺអំពីគាត់មានការងឿងឆ្ងល់ជាខ្លាំង*កិច្ចការ ៩:២០-២២*។ ប៉ុន្តែពួកយូដាដែលគ្មានជំនឿមិនបានទទួលទីបន្ទាល់របស់សាវ័កថ្មីម្នាក់នេះ ជាការពិតប៉ុន្មានថ្ងៃក្រោយមកពួកយូដាបានសមគំនិតគ្នាដើម្បីសម្លាប់គាត់។ តែទោះបីយ៉ាងណាក៏ដោយគំរោងរបស់ពួកគេបានដឹងដល់*លោកសូល* ទោះបីពួកយូដាបានចាំនៅទ្វារក្រុងទាំងយប់ទាំងថ្ងៃដើម្បីសម្លាប់លោក។ ប៉ុន្តែនៅពេលយប់ពួកសិស្សរបស់លោកបានដាក់លោកក្នុងជាលមួយសំរូតចុះទៅខាងក្រៅកំពែងក្រុង ហើយគាត់ក៏បានផុតពីគ្រោះថ្នាក់ទៅ*កិច្ចការ៩:២៣-២៥* ។

*លោកសូល* បានប្រញាប់ប្រញាលទៅ *អារ៉ាប់* ជាច្រើនឆ្នាំគេមិនបានលឺដំណឹងពីគាត់ឡើយ ។ ប៉ុន្តែគាត់ប្រាប់យើងថាអំឡុងពេលនោះគាត់បានទទួលការបង្ហាញជាបន្តបន្ទាប់ពីព្រះយេស៊ូគ្រិស្តអំពីដំណឹងល្អថ្មី ដែលគាត់បានប្រកាស *កាឡាទី ១:១១-១៧*។ *លោកសូល* ជាសាវ័កថ្មីហើយព្រះជាម្ចាស់ទ្រង់បង្ហាញព្រះបន្ទូលជាពិសេសនិងកិច្ចការថ្មីសំរាប់គាត់ធ្វើ ។ ចាប់តាំងពីព្រះបន្ទូលនេះជាប់ ទាក់ទងការសង្គ្រោះសាសន៍ដទៃ ដែលនៅទីនេះនៅលើផែនទីបង្ហាញថា *ផ្លូវនៃសាសន៍ដទៃ* ភ្ជាប់និង ចូលរួមជាមួយ *ផ្លូវធំនៃរាជាណាចក្រ*។

តើអ្នកធ្លាប់ជាន់ដែកគោលរឺបន្លារឺទេ? តើវាមានអារម្មណ៍យ៉ាងណាដែរ? អ្នកជាន់កាន់ តែខ្លាំងគឺវាឈឺចាប់កាន់តែខ្លាំង ។ នោះជាបទពិសោធន៍របស់*លោកសូល* នៅពេលគាត់ប្រឆាំងព្រះគ្រិស្ត ហើយបដិសេធមិនស្តាប់ព្រះបន្ទូលរបស់ទ្រង់ ។ មានមនុស្សជាច្រើនដូច*លោកសូល* សព្វថ្ងៃនេះ ទោះបីជាពួកគេប្រកាន់លើសាសនាខ្លាំងយ៉ាងណាដូច *លោកសូល* ធ្លាប់ធ្វើក៏ដោយ ប៉ុន្តែពួកគេកំពុងដើរនៅក្នុងផ្លូវរបស់ពួកគេហើយមិនមែនជាផ្លូវនៃជំនឿទៅលើព្រះអម្ចាស់ទេ ។

អ្នកខ្លះបានទទួលព្រះយេស៊ូជាព្រះសង្គ្រោះ ប៉ុន្តែពួកគេនៅតែប្រឆាំងការត្រាស់ហៅរបស់ព្រះជាម្ចាស់ដើម្បីបំរើទ្រង់ដោយអស់ពីចិត្ត និងជីវិតរបស់គេ ។ អ្នកខ្លះត្រូវបានត្រាស់ហៅអោយធ្វើជាបេសកជន រឺអ្នកអធិប្បាយ រឺជាគ្រូគង្វាល ប៉ុន្តែពួកគេមិនចង់ថ្វាយជីវិតរបស់គេដល់ព្រះគ្រិស្តទេ ព្រោះពួកគេខ្លាចការរងទុក្ខលំបាក ។ ប៉ុន្តែពួកគេនឹងមិនដែលសប្បាយរហូតដល់ពួកគេប្រគល់ជីវិតទាំងមូលទៅទ្រង់ ដូចជាព្រឹត្តិការណ៍ដែលកើតឡើង ចំពោះ*លោកសូល* នៅលើផ្លូវទៅ*ក្រុងដាម៉ាស*។ ព្រះជាម្ចាស់ចង់អោយយើងម្នាក់ៗក្លាយជាទូតសំរាប់ទ្រង់ *២កូរិនថូស ៥:២០* ។

**ខគម្ពីរចងចាំ** ២កូរិនថូស៥:២០ : " ដូច្នេះយើងជាទូតរបស់ព្រះគ្រិស្តគឺដូចជាព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូនតាមរយៈយើងដែរ ។ យើងសូមអង្វរបងប្អូនក្នុងព្រះនាមព្រះគ្រិស្តថាទុកអោយព្រះជាម្ចាស់សំរុះសំរួលបងប្អូនអោយជានានឹងព្រះអង្គវិញទៅ " ។

## <u>សំនួរត្រិះរិះ មេរៀនទី២១</u>

១. បន្ទាប់ពីទៅប៉មបាបិលបានហៅថាជ្រុងនៃការភាន់ច្រឡំនៅលើ ផែនទីរបស់យើងអ្វីមួយបានកើតចំពោះសាសន៍ដទៃ ពីព្រោះពួកគេបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ។ ស្វែងរកតាម រយៈការមើលខគម្ពីរៈ

រ៉ូម១:២៤............................................................................... ។

រ៉ូម១:២៦............................................................................... ។

រ៉ូម១:២៨............................................................................... ។

២.*លោកស្ទេផាន* បាននិយាយថាអ៊ីស្រាអែលបានធ្វើកំហុសបី តើកំហុសទាំងនោះជាអ្វី? *កិច្ចការ៧:៥១-៥២:* អ្នកតែងតែ..................................................................................អ្នក ......................................................... ..................ដែលប្រកាសទុកជាមុននៃការយាងមករបស់ព្រះដ៏សុចរិត ។ ឥលូវពួកគេគឺជា................. ................ ...............................ហើយ.......... ...............................................................................ព្រះគ្រិស្ត ។

៣.អ៊ីស្រាអែលភ្លាមៗក្លាយជាអាក្រក់ដូចសាសន៍ដទៃ ដូច្នេះព្រះជាម្ចាស់រៀបចំធ្វើអ្វីមួយថ្មី។ ជំហានដំបូងរបស់ទ្រង់គឺបញ្ចប់ រឺបិត............................................................................................ ទាំងអស់ដែលអាចនឹង ..........................................................................................ទាំងអស់ *រ៉ូម១១:៣១, ៣២*។

៤.បុរសដែលឈរក្បែរសំលៀកបំពាក់ ខណៈពេលពួកគេបានគប់ដុំថ្មសម្លាប់លោកស្ទេផានគឺលោក.................. ............................................. *កិច្ចការ៧:៥៨*។

៥.ព្រះជាម្ចាស់បានប្រាប់ទៅ*លោកសូល* ថាគាត់នឹងទទួលអំរែកនៃទុក្ខលំបាកក្នុងព្រះនាមព្រះអម្ចាស់ចំពោះមនុស្សបីក្រុម។ ចូររៀបរាប់ : ឈ្មោះពួកគេ *កិច្ចការ៩:១៥-១៦*........................................................................ ........................................................................................................................................ .........................................................................................................................................។

៦.ផ្លូវនៃសាសន៍ដទៃភ្ជាប់ និងចូលរួមជាមួយផ្លូវធំនៃរាជាណាចក្រនៅទីនេះពីព្រោះព្រះជាម្ចាស់ជ្រើសរើស*លោកសូល*រឺហៅថាលោកប៉ូលជាសាវ័កនៃ ............................................................................ *រ៉ូម១១:១៣* ។

៧.ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកសូលពីឋានសួគ៌។ តើទ្រង់មានព្រះបន្ទូលចំពោះយើងដែលរស់នៅព្រលាននៃព្រះគុណដូចម្តេច? រ៉ូម១០:១៧,យ៉ូហាន២០:៣១.............................................................................. ........................................................................................................................................ .........................................................................................................................................។

៨.តើពាក្យ *ទូត* គឺជាអ្វី? ចូរមើលពាក្យនេះនៅក្នុងវចនានុក្រម រឺសួរអ្នកណាម្នាក់ដែល ដឹងឱ្យគេពន្យល់អ្នក។ ហើយសរសេរអត្ថន័យសង្ខេប អំពីពាក្យនេះ.............................................................................................. ........................................................................................................................................ ........................................................................................................................................ .........................................................................................................................................។

៩.យោងទៅតាម*២កូរិនថូស ៥:២០* តើអ្វីដែលយើងគួរតែធ្វើ?......................................................... ........................................................................................................................................ .........................................................................................................................................។

១០.សរសេរខគម្ពីរចងចាំ:*២កូរិនថូស៥:២០*

........................................................................................................................................ ........................................................................................................................................ .........................................................................................................................................។

**មេរៀនទី ២២: លោកពេត្រុសឆ្លងចូលផ្លូវសាសន៍ដទៃ**

**កិច្ចការ ១០**

**គំនិតសំខាន់: ដើម្បីបង្ហាញភាពខុសគ្នា និងស្រដៀងគ្នានៅក្នុងដំណើងល្អរបស់លោកពេត្រុស និង លោកប៉ូល**

ប្រសិនបើអ្នកមើលទៅផ្លែក្រូច រឺផ្លែស្វាយ តើមានរបៀបប៉ុន្មានយ៉ាង ដែលអ្នកអាចរៀបរាប់ភាពខុសប្លែកគ្នានៃផ្លែឈើនេះ? អំពីពណ៌? អំពីរសជាតិ? អំពីរូបរាង? តើមានប៉ុន្មានរបៀបដែលបង្ហាញថាផ្លែឈើនេះស្រដៀងគ្នា? ផ្លែទាំងពីរនោះមានរាងមូលជាប្រភេទផ្លែឈើមានប្រយោជន៍សំរាប់ហូប ។ល ។ នៅក្នុងមេរៀននេះ យើងកំពុងមើលពីភាពខុសគ្នានៃដំណើងល្អរបស់លោកពេត្រុស និងលោកប៉ូល ។ យើងក៏នឹងឃើញផងដែរ ថាពួកគាត់មានភាពដូចគ្នាត្រង់ចំនុចខ្លះ ។

លោកពេត្រុសនៅតែមានការពេញចិត្តនឹងមុខងារជាអ្នកគ្រប់គ្រងមាគ៌ានៃរាជាណាចក្រ ប៉ុន្តែលោកពេត្រុសស្ថិតនៅក្រោមក្រឹត្យវិន័យ និងដឹកនាំតែជនជាតិមួយតែប៉ុណ្ណោះទៅកាន់រាជាណាចក្រគឺយូដា ។ នៅ*កិច្ចការ ២១:២០* និង *កិច្ចការ ១៥:១*។ គាត់បានបង្ហាញអំណាចរបស់គាត់តាមរយៈទីសំគាល់ និងការអស្ចារ្យ ។ លោកពេត្រុសបានសំណាក់នៅផ្ទះរបស់*លោកស៊ីម៉ូន* ក្រុងយ៉ុបប៉េក្បែរមាត់សមុទ្រជាអ្នកសំលាប់ស្បែក ។ នៅទីក្រុងសេសារេមាននាយទាហានកងវរសេនាតូចរ៉ូមាំងម្នាក់ឈ្មោះ*កូនេលាស* បានអធិដ្ឋាន និងមានបំណងចិត្តចង់ស្គាល់ពីព្រះនៃអ៊ីស្រាអែល ដូចនេះព្រះអង្គទ្រង់ក៏ចាត់លោកពេត្រុសទៅកាន់*លោកកូនេលាស*។ យើងអានពីព្រឹត្តិការណ៍ទាំងនេះនៅក្នុងកណ្ឌគម្ពីរ *កិច្ចការ ១០:១-៣៣*។

ដោយសារ*លោកកូនេលាស* បណ្តាលអោយ*លោកពេត្រុស* ឆ្លងចូលផ្លូវសាសន៍ដទៃ។ ព្រះអង្គបានផ្តល់ឱកាសដល់លោកពេត្រុស ដើម្បីប្រើកូនសោរនៃរាជាណាចក្រសំរាប់សាសន៍ដទៃ ដូចសាសន៍យូដាដែរ ។ *លោកពេត្រុស* បានចែកចាយព្រះបន្ទូលដល់*លោកកូនេលាស*។ គាត់បានពន្យល់រៀបរាប់ពីរបៀបដែលព្រះជាម្ចាស់រាប់មនុស្សមិនរើសមុខឡើយ ក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មានអ្នកណាក៏ដោយអោយតែគោរពកោតខ្លាចព្រះអង្គ និងប្រព្រឹត្តិអំពើសុចរិតព្រះអង្គមុខជាគាប់ព្រះហឫទ័យនឹងអ្នកនោះមិនខាន ហើយនិងទទួលព្រះពរតាមព្រះបន្ទូលដែលចាត់តាមកូនចៅអ៊ីស្រាអែល *កិច្ចការ ១០:៣៤-៣៦*។

ព្រះបន្ទូលរបស់លោកពេត្រុស គឺព្រះយេស៊ូជាព្រះសំរាប់គ្រប់ជាតិសាសន៍ដែលលោកយ៉ូហានបានបង្ហាញពីព្រះយេស៊ូតាមរយៈពិធីជ្រមុជទឹក ។ ចំនែកព្រះយេស៊ូក៏បង្ហាញអង្គទ្រង់ថាជាព្រះតាមទីសំគាល់អស្ចារ្យដែលទ្រង់បានធ្វើបន្ទាប់មកទ្រង់ត្រូវគេឆ្កាង ហើយរស់ឡើងវិញនៅថ្ងៃទី៣ ។ ព្រះអង្គបង្ហាញអង្គទ្រង់ទាំងបើកចំហរដើម្បីជ្រើសរើសម្នាក់ៗ និងបង្គាប់ពួកគេអោយចែកចាយដល់មនុស្សថាទ្រង់ជាអ្នកវិនិច្ឆ័យអស់អ្នកដែលរស់ និងស្លាប់អ្នកណាដែលជឿលើអង្គទ្រង់នឹងអោយរួចផុត ពីបាបរបស់ពួកគេ *កិច្ចការ១០:៣២-៤៣*។

ពេលដែលលោកពេត្រុសកំពុងចែកចាយទៅកាន់ក្រុមគ្រួសាររបស់*លោកកូនេលាស* ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើពួកអ្នកដែលស្តាប់ព្រះបន្ទូល ។ សាសន៍យូដាមានការងឿងឆ្ងល់ដោយព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណ

ដ៏វិសុទ្ធប្រទានអោយសាសន៍ដទៃដែលនិយាយភាសាចំឡែកអស្ចារ្យ និងលើកតំកើងព្រះជាម្ចាស់ផង។ លោកពេត្រុសក៏បង្គាប់ពួកគេអោយធ្វើពិធីជ្រមុជទឹក។ ព្រះអង្គបានប្រើលោកពេត្រុសបើកទ្វារដើម្បីអោយសាវ័កដទៃទៀតដឹងថា ឥឡូវនេះព្រះអង្គបានយល់ព្រមចាត់ដំណឹងល្អទៅកាន់សាសន៍ដទៃហើយ។

សព្វថ្ងៃយើងរស់នៅក្នុងព្រលាននៃព្រះគុណ យើងដឹងថាមានចំនុចខុសប្លែកគ្នាខ្លះៗនៅក្នុងព្រះបន្ទូលរបស់លោកពេត្រុស និងលោកប៉ូល។ ព្រះអង្គប្រាប់យើងថាយើងមើលភាពខុសគ្នា រឺកំនត់ សំគាល់ចំនុចដែលខុសគ្នា *ភីលីព ១:១០*។ យើងក៏ត្រូវបានប្រាប់អោយបែងចែកព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ *.២ធីម៉ូថេ ២:១៥*។

## ភាពខុសប្លែកគ្នា

១- *លោកពេត្រុស* ត្រូវបានចាត់អោយទៅកាន់*លោកកូនេលាស* ដោយសារ *លោកកូនេលាស* បានប្រព្រឹត្តិអំពើសុចរិត និងធ្វើល្អទៅកាន់សាសន៍យូដា *កិច្ចការ ១០:២,៣៥*។ ប៉ុន្តែលោកប៉ូលត្រូវបានផ្តល់អោយនាំព្រះបន្ទូលនៃព្រះគុណទៅកាន់សាសន៍ដទៃពីព្រោះយើងជាមនុស្សបាបគ្មានក្តីសង្ឃឹម*រ៉ូម. ៣:១០-១៨, រ៉ូម.៥:៨,១០*។

២- អស់អ្នកដែលទទួលការសង្គ្រោះដោយព្រះបន្ទូលតាមរយៈ *លោកពេត្រុស* បាននិយាយភាសាចំឡែកដែលផ្តល់នូវទីសំគាល់ ។ *លោកប៉ូល* មានប្រសាសន៍ថាភាសាចំឡែកនឹងត្រូវបាត់បង់ . *១កូរិនថូស ១៣:៨*។

៣- *លោកពេត្រុស* ធ្វើពិធីជ្រមុជទឹកដើម្បីទទួលការសង្គ្រោះ *ម៉ាកុស ១៦:១៥-១៦*។ *លោកប៉ូល* មានប្រសាសន៍ថា "ព្រះយេស៊ូមិនបានចាត់ខ្ញុំអោយមកធ្វើពិធីជ្រមុជទឹកទេ" *១កូរិនថូស ១:១៧*។ ពិធីជ្រមុជរបស់យើងសព្វថ្ងៃនេះគឺជាទំរង់ដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងក្លាយជាសមាជិកនៃរូបកាយព្រះគ្រីស្ត *១កូរិនថូស១២:១៣*។

៤- លោកពេត្រុសបានចែកចាយអំពីក្រឹត្យវិន័យ តែលោកប៉ូលចែកចាយទៅកាន់សាសន៍ដទៃ ថាពួកគេមិនស្ថិតនៅក្រោមក្រឹត្យវិន័យទេ តែស្ថិតនៅក្រោមព្រះគុណវិញ *រ៉ូម៦:១៤*។

## ចំនុចស្រដៀងគ្នា

១-ទាំង*លោកពេត្រុស*និង*លោកប៉ូល* ចែកចាយពីការអត់ទោសបាបតាមរយៈសេចក្តី ជំនឿក្នុងព្រះគ្រិស្ត*កិច្ចការ១០:៤៣, រ៉ូម ៣:២២*។

២-លោកទាំងពីរបានធ្វើបេសកកម្មទូទាំងពិភពលោក។ បេសកកម្ម*លោកពេត្រុស* សំរាប់ការបង្កើតរាជាណាចក្រ ចំណែក*លោកប៉ូល* សំរាប់ការត្រាស់ហៅនៃរូបកាយព្រះគ្រិស្ត។ *កិច្ចការ១:៨ និង ២កូរិនថូស ៥:១៩*។

៣- លោកទាំងពីរទទួលការសន្យាសំរាប់ការយាងមកនៃព្រះគ្រិស្ត : *លោកពេត្រុស* ប្រាប់ពីការយាងមករបស់ទ្រង់ជាស្តេចនៅលើផែនដី រីឯ*លោកប៉ូល* ប្រាប់យើងពីការយាងមករបស់ទ្រង់ក្នុងលំហរអាកាសដើម្បីប្រមូលរូកាយនៃព្រះគ្រិស្តទៅកាន់អង្គទ្រង់ *កិច្ចការ ៣:២០ និង ១ថេស្សាឡូនិក ៤:១៦-១៧*។

លោកពេត្រុសមិនចែកចាយទៅកាន់អ្នកណាទៀតទេ តែទៅកាន់តែយូដាមួយប៉ុណ្ណោះរហូតដល់ទ្រង់បង្ហាញថាគ្រប់គ្នាមានតំលៃស្មើគ្នា។ កិច្ចការនេះត្រូវបានផ្តល់ដល់ប៉ូលនូវសេចក្តីពិតយ៉ាងពេញលេញដើម្បីបំបាត់ភាពខុសគ្នា *អេភេសូ ២:១៤*។ ឥលូវព្រះអង្គអោយយើងឃើញមនុស្សគ្រប់ពណ៌សម្បុរគ្រប់ជាតិសាសន៍ត្រូវការការសង្គ្រោះដោយសេចក្តីជំនឿក្នុងអង្គព្រះគ្រិស្តមិនដោយសារការគោរពតាមសាសនាឡើយ។

**ខព្រះគម្ពីរចងចាំ:** *២ធីម៉ូថេ២:១៥* ចូរខំធ្វើយ៉ាងណាអោយបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងចូលមកជិតព្រះអង្គក្នុងឋានៈជាកម្មករ ដែលគ្មានអ្វីនាំអោយអៀនខ្មាស់ ព្រោះខ្លួនបានចែកផ្សាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ ។

## សំនួរត្រិះរិះ មេរៀនទី២២

លោកពេត្រុសចែកចាយពីដំណឹងល្អនៃរាជាណាចក្រ ប៉ុន្តែលោកប៉ូលត្រូវបានត្រាស់ហៅ ដើម្បីចែកចាយពីដំណឹងល្អនៃរូបកាយព្រះគ្រិស្ត ។ គោលបំណងនៅក្នុងមេរៀននេះ គឺដើម្បីបង្ហាញភាព ខុសនិងស្រដៀងគ្នានៃព្រះបន្ទូលទាំងពីរនេះ ។ ចូរបំពេញនៅក្នុងសេចក្ដីប្រៀងដែលបានផ្ដល់អោយ ហើយអ្នកនឹងឃើញពីភាពខុសគ្នា ។ មេរៀននេះបង្ហាញពីខគម្ពីរចងចាំ ដែលប្រាប់យើងអោយបែង ចែកព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ ។

### ភាពខុសប្លែកគ្នា

| លោក ពេត្រុស | លោក ប៉ូល |
| --- | --- |
| ១-២.ត្រូវចាត់ទៅកូនេលាសព្រោះគាត់ | ត្រូវចាត់ទៅសាសន៍ដទៃព្រោះពួកគេ |
| ................................................ | ................................................ |
| "កិច្ចការ១០:៣៥" | "រ៉ូម ៥:៨" |
| ៣-៤. អ្នកទទួលការសង្គ្រោះនិយាយ | មានប្រសាសន៍ថាភាសាចំឡែកនឹង |
| ............................................ | ................................................ |
| "កិច្ចការ១០:៤៦" | "១កូរិនថូស.១៣:៨" |
| ៥-៦. ធ្វើពិធីជ្រមុជជាមួយ | មានប្រសាសន៍ថាគាត់មិនត្រូវបាន ចាត់អោយមកដើម្បី |
| ............................................ | ................................................ |
| "កិច្ចការ១០:៤៧" | ១កូរិនថូស.១:១៧" |

### ភាពដូចគ្នា

៧-៨. ចូរបំពេញចន្លោះខាងក្រោមហើយអ្នកនឹងឃើញថាព្រះបន្ទូលដែលចែកចាយតាមរយៈ លោក ពេត្រុស និង លោកប៉ូលដូចគ្នាក្នុងចំនុចជាច្រើន ។

លោកទាំងពីរចែកចាយពីការអត់ទោសបាបតាមរយៈ................................................................................

.............................នៅក្នុងព្រះគ្រីស្ដយេស៊ូ *កិច្ចការ១០:៤៣,រ៉ូម៣:២២*។

លោកទាំពីរមានបេសកកម្មសំរាប់គ្រប់...............................................................*កិច្ចការ១:៨ ២កូរិន.៥:១៩* លោកពេត្រុសសំរាប់ការបង្កើតរាជាណាចក្រ លោកប៉ូលសំរាប់ការត្រាស់ហៅរូបកាយ ព្រះគ្រិស្ត ។

លោកទាំងពីរមានការសន្យាពី.......................................................... នៃព្រះគ្រីស្ទ *កិច្ចការ ៣:២០, ១ថេស្សាឡូនិក៤:១៦-១៧* លោកពេត្រុសប្រាប់ពីការយាងមកនៃព្រះគ្រីស្ទជាស្តេច រីឯលោកប៉ូលប្រាប់ពីការយាងមករបស់ព្រះគ្រិស្ទជាសិរសានៃរូបកាយព្រះគ្រីស្ទ ។

៩-បើអ្នកជាទូតរបស់ព្រះគ្រីស្ទ តើអ្នកនឹងប្រាប់មនុស្សយ៉ាងណាដើម្បីអោយពួកគេទទួលបានការសង្គ្រោះ? ចូរសរសេរពីខគម្ពីរដែលអ្នកនឹងប្រើ:

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................។

១០ . សរសេរខគម្ពីរចងចាំ ២ធីម៉ូថេ២:១៥ :

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................។

## មេរៀនទី ២៣ : ផ្លូវឆ្លោះមកពីផ្លូវនៃសាសន៍ដទៃទៅដល់មាគ៌ានៃព្រះគុណ

**កិច្ចការ១៣-២៨**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញថាការបដិសេធពន្លឺរបស់ព្រះជាម្ចាស់នឹងនាំទៅរកភាពងងឹត**

តើអ្នកដឹងទេថាពាក្យ " បែកចេញ " មានន័យយ៉ាងដូចម្តេច? មនុស្សពីរនាក់អាចមានមិត្តភាពល្អ ប៉ុន្តែពួកគេអាចបែកគ្នាទៅកាន់សាលាការងារ រឺក៏ទីកន្លែងផ្សេងៗគ្នា និយាយម្យ៉ាងទៀតពួកគេបែកគ្នា។ ព្រះអង្គទ្រង់ញែកទាំងវត្ថុ និងមនុស្សដើម្បីគោលបំណងពិសេសផ្សេងៗរបស់ទ្រង់។ ប្រជាជនអ៊ីស្រាអែលត្រូវបានញែកសំរាប់គោលបំណងជាសក្ខីភាពពីព្រះដ៏មានព្រះជន្មរស់ទៅកាន់ពិភពលោក។ មេរៀននេះយើងនឹងសិក្សាពីរបៀបដែលអ៊ីស្រាអែលធ្លាក់ចុះ និងរបៀបដែលលោកសូលត្រូវបានព្រះជាម្ចាស់ញែកសំរាប់ធ្វើកិច្ចការក្នុងគោលបំណងថ្មីរបស់ទ្រង់។

បន្ទាប់ពីការផ្លាស់ប្រែរបស់លោកប៉ូលបានធ្វើដំណើរទៅស្រុកអារ៉ាប់ បន្ទាប់មកលោកក៏ធ្វើដំណើរមកក្រុងដាម៉ាកូសវិញ។ បីឆ្នាំក្រោយមកគាត់វិលត្រលប់ទៅទីក្រុងយេរូសាឡឹមវិញរួចទៅតំបន់ស៊ីរី។ ប៉ុន្មានឆ្នាំក្រោយមកបន្ទាប់ពីលោកផ្លាស់ប្រែចិត្តគំនិតលោកបានធ្វើបេសកកម្មជាមួយ *លោកបាណាបាស* និងអ្នកដទៃទៀតនៅក្រុមជំនុំអង់ទីយ៉ូកនៃស្រុកស៊ីរី *កាឡាទី ១:១៧-១៨, កិច្ចការ ១៣:១*។

នៅពេលអ្នកដឹកនាំនៃបេសកកម្មតមអាហារព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា "ចូរញែកបាណាបាស និងសូលដោយឡែក ត្បិតយើងបានហៅអ្នកទាំងពីរមក"។ ភ្លាមៗនោះពួកគេចេញដំណើរទៅកំពង់ផែ ហើយជិះទូកក្តោងពីទីនោះទៅកោះគីប្រុស។ នៅក្រុងប៉ាផូសពួកគេបានជួបគ្រូមន្ត អាគមក្លែងក្លាយជាតិយូដាដែលមានឈ្មោះថា *បារយេស៊ូ* ដែលជាតំណាងនៃ*លោកស៊ើគាសប៉ូឡូស* ដែលយើងអាចអាននៅ *កិច្ចការ ១៣:៦-១២*។ **ចំណាំ** : *លោកបារយេស៊ូ* "ជារូបភាពស្តីពីអ៊ីស្រាអែល" ព្យាយាមពង្វេង *លោកស៊ើគាសប៉ូឡូស* "តំណាងអោយសាសន៍ដទៃ" ងាកចេញពីព្រះបន្ទូល។ *លោកប៉ូល* ហៅគ្រូមន្តអាគមថាកូនរបស់មារកំណាច ហើយធ្វើអោយគាត់ខ្វាក់ភ្នែក" ជារូបភាពមួយស្តីពីការងងឹតរបស់អ៊ីស្រាអែលមួយរយៈ"។ *រ៉ូម១១:២៥* នៅពេលលោកប្រតិភូបានឃើញការអស្ចារ្យ ដែលកើតឡើងគាត់ក៏ទទួលជឿ ដូចនេះសាសន៍ដទៃទទួលការសង្គ្រោះតាមរយៈការធ្លាក់ចុះនៃសាសន៍អ៊ីស្រាអែល។ ឈ្មោះរបស់លោក*សូល* បានផ្លាស់ទៅជា*ប៉ូល*។

ពួកគាត់បានបន្តដំណើរទៅក្រុងពើកា និងក្រុងអន់ទីយ៉ូកនៃស្រុកពីស៊ីឌា។ តាមទំលាប់របស់ពួកគេដំបូងពួកគេបានទៅចូលរួមនៅក្នុងសាលាប្រជុំ ដែលជាកន្លែងជួបជុំគ្នារបស់សាសន៍យូដា។ ពួកគេចែកចាយពីភាពសុចរិត ដោយសារសេចក្តីជំនឿ។ នៅពេលសាសន៍ដទៃមានបំណងចិត្តចង់ទទួលព្រះបន្ទូលនេះ សាសន៍យូដាពោរពេញទៅដោយសេចក្តីច្រណែន និងអំនួត ហើយនិយាយជំទាស់នឹងអ្វីដែល*លោកប៉ូល*មានប្រសាសន៍ ហើយពួកយូដានិយាយប្រឆាំងនិងប្រមាថលោក។ បន្ទាប់មក*លោកប៉ូល* និង *លោកបាណាបាស* ក៏មានប្រសាសន៍ទៅគេដោយចិត្តអង់អាចថា "មុនដំបូងយើងខ្ញុំត្រូវតែប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅដល់បងប្អូន។ ប៉ុន្តែដោយបងប្អូនបដិសេធមិនព្រមទទួលព្រះបន្ទូលនេះ ហើយដោយបងប្អូនយល់ឃើញថាខ្លួនមិនសមនិងទទួលជីវិតអស់កល្បជានិច្ចទេ នោះយើងខ្ញុំនឹងងាកទៅប្រកាសដល់

សាសន៍ដទៃវិញ” *កិច្ចការ១៣:១៤-៤៩*។ ដោយប្រយោគនេះ នៅលើផ្លូវភ្លោះ *លោកប៉ូល* ឆ្លងកាត់ពីផ្លូវរបស់យូដាទៅកាន់ផ្លូវរបស់សាសន៍ដទៃ។

នៅទីក្រុងកូរិនថូសលោកប៉ូលបានទៅរកយូដាម្តងទៀត ហើយពន្យល់នូវមូលហេតុនៅក្នុងព្រះវិហារ។ លោកបង្ហាញថាព្រះយេស៊ូគឺជាព្រះគ្រិស្តដែលត្រូវយាងមក។ ពួកយូដាចេះតែប្រឆាំងនឹងលោកហើយជេរប្រមាថលោកទៀតផងនោះ លោកក៏រលាស់ធូលីដីចេញពីសំលៀកបំពាក់របស់លោកទាំងមានប្រសាសន៍ថា “បើអ្នករាល់គ្នាវិនាសបាត់បង់នោះគឺមកពីកំហុសរបស់អ្នករាល់គ្នាផ្ទាល់ប៉ុណ្ណោះ គ្មានជាប់ជំពាក់អ្វីជាមួយខ្ញុំទេចាប់ពីពេលនេះខ្ញុំនឹងទៅរកសាសន៍ដទៃវិញ”*កិច្ចការ១៨:១-៦*។ *លោកប៉ូល* បានឆ្លងម្តងទៀតទៅកាន់សាសន៍ដទៃលើផ្លូវភ្លោះ។

ចុងបញ្ចប់*លោកប៉ូល*បានមកដល់រាជធានីរ៉ូម។ នៅពេល*លោកប៉ូល*បានចែកចាយទៅកាន់ សាសន៍យូដាពីព្រះយេស៊ូ ប៉ុន្តែគាត់ត្រូវបានគេបដិសេធម្តងទៀត*កិច្ចការ ២៨:២៣-២៤*។ ក្នុងចំណោមអ្នកទាំងនោះមានខ្លះបានទទួលជឿ និងភាគច្រើនមិនជឿ។ ពេលពួកគេបដិសេធចំពោះខ្លួនគេ ដូចនេះ*លោកប៉ូល*មានប្រសាសន៍ថា “ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលតាមព្យាការីអេសាយពិតជាត្រូវមែន.... ហេតុនេះសូមបងប្អូនជ្រាបថាព្រះជាម្ចាស់បានប្រទានព្រះបន្ទូលស្តីពីការសង្គ្រោះអោយសាសន៍ដទៃវិញព្រោះគេមុខជាស្តាប់មិនខាន” *កិច្ចការ ២៨:២៥-២៨*។ ដោយការប្រកាសជា លើកទីបីនេះ វាជាផ្លាកសញ្ញាបញ្ជាក់យ៉ាងធំនៅលើមាគ៌ានៃរាជាណាចក្រ។ អ៊ីស្រាអែលបានបដិសេធព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ឥលូវអ៊ីស្រាអែលនឹងងងឹតភ្នែកមួយរយៈ។ ផែនការនៃរាជាណាចក្រត្រូវបានផ្អាកខណៈពេលដែលទ្រង់ធ្វើការបំពេញនូវគោលបំណងអាថ៌កំបាំងថ្មីរបស់ទ្រង់។

ដូចនេះយើងឃើញរបៀប ដែលជាតិសាសន៍ទាំងមូលជ្រើសរើសភាពងងឹតជំនួសពន្លឺ។ តើអោយពិភពលោកទទួលព្រះពរយ៉ាងម្តេចបើអ៊ីស្រាអែលដែលជាទីបញ្ចេញព្រះពរខ្វាក់ងងឹតដូចនេះ? ទោះជាយ៉ាងណាក៏ដោយប្រសិនបើយើងមើលយ៉ាងប្រុងប្រយ័ត្នលើផែនទីយើងនឹងឃើញថាមានការបត់នៅផ្នែកខាងចុង *នៃផ្លូវភ្លោះ* ជាកន្លែងដែលយើងចូលទៅក្នុង *មាគ៌ានៃជីវិត* មួយដែលពោរពេញដោយសិរីរុងរឿង។ យើងហៅថាមាគ៌ានៃព្រះគុណ។ ព្រះគុណមានន័យថាសេចក្តីមេត្តាដែលមិនសមនឹងទទួល ឬអំណោយនៃសេចក្តីស្រលាញ់ដែលព្រះជាម្ចាស់ផ្តល់អោយទាំងសាសន៍យូដា និងសាសន៍ដទៃដែលជាអ្នកមិនសមនឹងទទួលអ្វីសោះព្រោះពួកគេបានបោះបង់ព្រះជាម្ចាស់។

អ្វីផ្សេងទៀតដែលយើងសង្កេតឃើញនៅទីនេះ គឺលទ្ធផលដ៏អាក្រក់នៃការបដិសេធព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើថ្ងៃនេះអ្នកបដិសេធព្រះបន្ទូលព្រះអង្គដែរឬទេ? ពេលណាអ្នកមិនស្តាប់បង្គាប់ព្រះបន្ទូល គឺអ្នកបដិសេធព្រះបន្ទូល។ ការបន្តបដិសេធទទួលយកពន្លឺនិងនាំទៅរកភាពងងឹត។ ពិភពលោកសព្វថ្ងៃត្រូវតែត្រលប់ទៅរកពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។ យើងសរសើរតំកើងព្រះជាម្ចាស់ចំពោះព្រះប្រាជ្ញាញាណ និងចំណេះដឹងរបស់ទ្រង់ដែលយើងអាចទូលអង្វរសុំជំនួយដើម្បីអោយយើងបានលឺ និងស្តាប់បង្គាប់ព្រះសូរសៀងព្រះវិញ្ញាណដ៏វិសុទ្ធ។

**ខគម្ពីរចងចាំ** : ១ថែស្សាឡូនិក៥:១៨-១៩

ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ត្បិតព្រះអង្គសព្វព្រះហឫទ័យអោយបងប្អូនដែលរួមជាមួយព្រះគ្រិស្តយេស៊ូធ្វើដូច្នេះឯងកុំរារាំងសកម្មភាពរបស់ព្រះវិញ្ញាណឡើយ ។

# សំនួររត្រិះរិះ មេរៀនទី២៣

១-តើលោកសូលនៅឯណាពេលព្រះវិញ្ញាណដ៏វិសុទ្ធត្រាស់ហៅ "ញែកបាណាបាស និងសូលដោយឡែកសំរាប់កិច្ចការដែលយើងត្រាស់ហៅពួកគេ " *កិច្ចការ១៣:២*.........................................................................................................

..................................................................................................................................................................

.. .............................................................................................................................................។

២-តើពួកគេធ្វើដំណើរទៅកាន់កោះណា? *កិច្ចការ១៣:៤*.............................................................................

.............................................................................................................................................................។

៣- តើគ្រូមន្តអាគមទាំងពីរដែលនៅទីក្រុងប៉ាផូសឈ្មោះអ្វី? *កិច្ចការ ១៣: ៦, កិច្ចការ ១៣:៨*......................

..................................................................................................................................................................

.............................................................................................................................................................។

៤-៦. បង្ហាញថាបទពិសោធន៏របស់លោកប៉ូលជាមួយបារយេស៊ូ ជារូបភាពនៃការដោះស្រាយរបស់ព្រះជាម្ចាស់ជាមួយអ៊ីស្រាអែលសព្វថ្ងៃ ចូរអាន*កិច្ចការ១៣:៧-១១*និងបំពេញចន្លោះខាងក្រោម។

- បារយេស៊ូធ្វើ.......................................................................ពួកគាត់ "ប៉ូល និងបាណាបាស" *កិច្ចការ១៣:៨*។

-អ៊ីស្រាអែល"យូដា"ពោរពេញដោយសេចក្តីច្រណែននិង.................................................................................

..........................នឹងអ្វីដែលលោកប៉ូលមានប្រសាសន៏។ *កិច្ចការ១៣:៤៥*។

-បារយេស៊ូព្យាយាម.........................................................................................................................................

............................................ប្រតិភូពីសេចក្តីជំនឿ *កិច្ចការ១៣:៨*។

-អ៊ីស្រាអែលព្យាយាមរារាំងលោកប៉ូលមិនអោយ.................................................................................................

..................................ទៅកាន់សាសន៏ដទៃ *១ថេស្សាឡូនិក២:១៥-១៦*។

-បារយេស៊ូត្រូវ..................................................................................................................................................

..........................................................................មួយរយៈ *កិច្ចកា១៣:១១*។

-អ៊ីស្រាអែលនឹង ...............................................................................................................................................

រហូតដល់ពេលសាសន៏ដទៃទាំងអស់បានទទួលការសង្គ្រោះ *រ៉ូម១១:២៥*។

-បន្ទាប់មកប្រតិភូស៊ើគាស-ប៉ូឡូស...................................................................................................................

.................................................................................... កិច្ចការ១៣:១២។

-សាសន៏ដទៃនឹង...............................................................................................................................................

......................................ព្រះបន្ទូលនៃការសង្គ្រោះ. កិច្ចការ ២៨:២៨។

៧-៨ សរសេរខគម្ពីរខាងក្រោមបង្ហាញថា លោកប៉ូលមានប្រសាសន៍បីដងពេលគាត់ឆ្លងកាត់ នៅលើផ្លូវភ្លោះពីមាតិនៃរាជាណាចក្រទៅមាតិនៃសាសន៍ដទៃ : *កិច្ចការ ១៣:៤៦*..........................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................។

*កិច្ចការ១៨:៦*...............................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................។

*កិច្ចការ២៨:២៨*.............................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................។

៩- យោងទៅតាម ២ថេស្សាឡូនិក ២:១០, ១២ តើមានអ្វីកើតឡើងចំពោះអ្នកដែលបដិសេធសេចក្តីពិត?

..........................................................................................................................

..........................................................................................................................។

១០-សរសេរខគម្ពីរចងចាំ ១ថេស្សាឡូនិក៥:១៨-១៩

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................។

**មេរៀនទី២៤ :** **លោកប៉ុលជាអ្នកបើកយន្តហោះនៃសេចក្តីសង្គ្រោះ**

**លិខិតឧទ្ទិសទាំងអស់របស់លោកប៉ុល**

**អេភេសូ ៣:៩**

**គំនិតសំខាន់ :** **ដើម្បីបង្ហាញពីទំនួលខុសត្រូវរបស់អ្នកជឿក្នុងសម័យនេះ**

**ដើម្បីអោយគ្រប់គ្នាយល់ច្បាស់ថាតើសម័យកាលអាថិកំបាំងគឺជាអ្វី?**

ពេលមុនយើងបានចាកចេញពីផ្លាកសញ្ញាយ៉ាងធំដែលសរសេរថា "ឈប់ " ដាក់យាំងយើងមិនអោយចូលទៅ *មាគ៌ានៃរាជាណាចក្រ* ដែលយើងងាកចូលទៅក្នុង *មាគ៌ានៃព្រះគុណ*។ តើអ្វីដែលធ្វើអោយមាគ៌ានៃព្រះគុណខុសប្លែកពីមាគ៌ាដទៃទៀតនៅក្នុងមាគ៌ានៃជីវិត? លោកប៉ុលត្រូវបានជ្រើសរើស ដើម្បីសរសេរអំពីអាថិកំបាំងនេះជាអាថិកំបាំងដែលព្រះជាម្ចាស់បង្ហាញដល់លោក។ សំបុត្ររបស់លោកត្រូវបានហៅថា "លិខិតឧទ្ទិស"។ លិខិតទាំងនេះត្រូវបានដាក់ឈ្មោះទៅតាមឈ្មោះទីក្រុងនៃអ្នកជឿដែលលោកប៉ុលធ្វើបេសកកម្ម រឺក៏ឈ្មោះអ្នកជឿដែលលោកប៉ុលសរសេរទៅកាន់។

ថ្ងៃមួយមានបុរសម្នាក់ឈ្មោះ ទីឃីគូសបានយកសំបុត្រដែលសរសេរដោយសាវ័កប៉ុលផ្ញើរជូនអ្នកជឿនៅក្រុមជំនុំក្នុងទីក្រុងអេភេសូ ដែលលោកប៉ុលកំពុងជាប់ឃុំឃាំងនៅឡើយ។ នៅពេលពួកគេអានលិខិតឧទ្ទិសនេះ ពួកគេរកឃើញការបង្ហាញថ្មី និងសេចក្តីពិតដ៏អស្ចារ្យជាច្រើននៅក្នុងលិខិតនោះ។ នៅជំពូកទី៤ លោកប៉ុលសរសេរអំពី *មួយទាំងប្រាំពីរ* ដែលមានសារសំខាន់ណាស់សំរាប់គ្រីស្តបរិស័ទ្ធទាំងអស់ដឹង។ យើងត្រូវបានជំរុញអោយចងចាំ *មួយទាំងប្រាំពីរ* នេះទាំងអស់ដែលយើង ឃើញមាននៅក្នុង *អេភេសូ៤:៣-៦*។

១-*ព្រះកាយមានតែមួយ* សាសន៍យូដាមិនមែនជាជនជាតិទីមួយទៀតទេ ប៉ុន្តែឥលូវទាំងសាសន៍ដទៃ និងអ៊ីស្រាអែលក្លាយជាសមាជិកនៃក្រុមជំនុំតែមួយជាមួយព្រះយេស៊ូជាសិរសា(ក្បាល) នៅពេលពួកគេទទួលការសង្គ្រោះ។ នៅលើផែនទីអ្នកឃើញរូបកាយនៃព្រះគ្រិស្តនៅស្ថានសួគ៌ជា កន្លែងដែលព្រះគ្រិស្តគ្រងរាជ្យនៅពេលយើងក្លាយជាផ្នែកមួយនៃរូបកាយព្រះគ្រិស្ត យើងនឹងអង្គុយលើបល្ល័ង្កនៅស្ថានបរមសុខជាមួយទ្រង់ដែរ *អេភេសូ ២:៦,១៣-១៦*។

២-*ព្រះវិញ្ញាណតែមួយ* ព្រះវិញ្ញាណជ្រមុជយើងរាល់គ្នាទៅក្នុងការសុគតរបស់ព្រះយេស៊ូនៅពេលដែលយើងជឿ។ ទ្រង់លើកយើងឡើង ដើម្បីអង្គុយទៅស្ថានបរមសុខជាមួយព្រះគ្រិស្ត ហើយព្រះអង្គបានដាក់ព្រះវិញ្ញាណដ៏វិសុទ្ធទុកជាសញ្ញាដៅសំគាល់យើងនៅក្នុងព្រះគ្រិស្ត ដូចនេះគ្មានអ្វីអាចបំបែកយើងពីទ្រង់បានឡើយ *រ៉ូម៦:៣-៤ អេភេសូ ១:១៣*។ យើងត្រូវយល់ថាព្រះពរផ្នែកខាងវិញ្ញាណពីស្ថានបរមសុខនេះព្រះអង្គបានរៀបចំទុកជា ស្រេចទៅហើយទោះបីរូបកាយយើងនៅលើផែនដីនេះនៅឡើយក៏ដោយ។

៣-*ការត្រាស់ហៅអោយមានសេចក្តីសង្ឃឹមតែមួយ* ព្រះពរនៃសេចក្តីសង្ឃឹម គឺថាព្រះអង្គទ្រង់ផ្ទាល់នឹងត្រាស់ហៅសមាជិកនៃព្រះកាយទ្រង់ក្នុងកំឡុងពេលមួយទោះបីស្លាប់ ឬរស់ដើម្បីនៅជាមួយទ្រង់អស់កល្ប។ យើងប្រើយន្តហោះនៅព្រលាននៃព្រះគុណដើម្បីតំណាងរូបកាយព្រះគ្រិស្តដែល ថ្ងៃណាមួយនឹងត្រូវលើកឡើងទៅស្ថានបរមសុខជាមួយព្រះ

គ្រិស្ត។ នៅក្នុងកំឡុងពេលមួយប៉ព្រិច ភ្នែករូបកាយយើងនឹងត្រូវប្តូរដូចជារូបកាយព្រះគ្រិស្តដែលពោរពេញដោយសិរីរុងរឿង។ *១ថេស្សាឡូនិក៤:១៣-១៧, ទីតុស២:១៣, ១កូរិនថូស១៥: ៥១-៥៤*។

៤-*ព្រះអម្ចាស់តែមួយ* ព្រះអម្ចាស់យេស៊ូគ្រិស្តជាព្រះដែលស្រលាញ់យើង និងបានលះបង់អង្គទ្រង់ផ្ទាល់សំរាប់យើងដែលឥលូវទ្រង់កំពុងអធិដ្ឋាន និងសំរុះសំរួលយើងជាមួយព្រះដែលយើងចង់ ថ្វាយសិរីរុងរឿងក្នុងគ្រប់កិច្ចការទាំងអស់*កូឡុស ១:១៨*។

៥-*សេចក្តីជំនឿតែមួយ* នេះជារូបកាយនៃសេចក្តីពិតដែលត្រូវបានផ្តល់ដល់*លោកប៉ូល* ដោយព្រះគ្រិស្តយេស៊ូសំរាប់ក្រុមជំនុំនៃព្រះជាម្ចាស់ដែលជារូបកាយនៃព្រះគ្រិស្ត *អេភេសូ៣:២-១០, ២ធីម៉ូថេ៤:៧*។

៦-*ពិធីជ្រមុជតែមួយ* នេះគឺជាការជ្រមុជនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលជ្រមុជយើងរាល់គ្នា ចូលក្នុងរូបកាយនៃព្រះគ្រិស្ត *១កូរិនថូស១២:១៣*។ ព្រះយេស៊ូគ្រិស្តមានសមាជិកជាច្រើននៅក្នុង *រូបកាយរបស់ទ្រង់* ដូចជាយើងរាល់គ្នាដែលមានដៃជើងច្រើនផ្នែក ប៉ុន្តែគ្រប់ផ្នែកដំណើរការទៅក្នុង គោលដៅមួយដែលមានព្រះគ្រិស្តជាសិរសា។

៧-*ព្រះជាម្ចាស់តែមួយជាព្រះបិតានៃមនុស្សទាំងអស់* ព្រះជាម្ចាស់ជាព្រះបិតានៃយើងរាល់គ្នាព្រោះយើងរួមតែមួយជាមួយព្រះគ្រិស្តយេស៊ូជាព្រះបុត្រា។ យើងក៏រួមទទួលមរតកជាមួយទ្រង់ដែរ *អេភេសូ ១:១១, ៣:៦*។

តើឥលូវអ្នកឃើញទេថា ហេតុអ្វីនេះជាផ្នែកមួយដ៏សំខាន់នៅក្នុងមាគ៌ានៃជីវិត? ដើម្បីរួមជាមួយព្រះគ្រិស្ត និងក្លាយជាផ្នែកមួយនៃទ្រង់ដោយសារតែព្រះគុណដែលមិនដែលបង្ហាញ នៅក្នុងសម័យកាលណាផ្សេងទៀតឡើយ *អេភេសូ ៣:៥*។

តើអ្នកគិតថាមនុស្សគ្រប់គ្នា ដែលជាបុត្រធីតារបស់ព្រះជាម្ចាស់គួរតែមានសកម្មភាពយ៉ាងណានៅក្នុងព្រះគ្រិស្ត? លោកប៉ូលប្រាប់យើងថាយើងគួរតែប្រតិបត្តិដូចប្រជាជនដ៏វិសុទ្ធ*អេភេសូ៣:៥*។ យើងផ្តោតគំនិត និងបំណងប្រាថ្នាទៅលើអ្វីៗនៅស្ថានបរមសុខ ទោះបីដំណើរជីវិតយើងស្ថិតនៅលើផែនដីនេះក៏ដោយ។ នៅក្នុង*អេភេសូ៤* និង*កូឡុស៣* យើងត្រូវបានបង្រៀនអំពីរបៀបដែលយើងគួរតែប្រព្រឹត្ត។

ចំនុច*មួយទាំងប្រាំពីរ* នេះបានស្ថិតនៅជាការអាថិកំបាំងរហូតដល់ទ្រង់បង្ហាញទៅកាន់ លោកប៉ូល។ សព្វថ្ងៃយូដា និងសាសន៍ដទៃ គឺដូចគ្នាហើយត្រូវតែចូលទៅក្នុងការប្រកបគ្នាតែមួយក្នុងព្រះជាម្ចាស់គ្មានភាពខុសគ្នាឡើយ។ សេចក្តីសង្គ្រោះអាចទទួលឥតបង់ថ្លៃឡើយ ហើយអាចទទួលតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះនៃអំពើបាបតែមួយ។ បន្ទាប់ពីយើងបានជឿ និងទទួលព្រះយេស៊ូជាព្រះសង្គ្រោះភ្លាមៗនោះយើងនឹងត្រូវបានជ្រមុជដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីក្លាយជាសមាជិកនៃរូបកាយព្រះគ្រិស្ត។

**ខគម្ពីរចងចាំ:** ព្រះអង្គសង្គ្រោះបងប្អូនដោយសារព្រះគុណតាមរយៈជំនឿ។ ការសង្គ្រោះមិនមែនមកពី បងប្អូនទេ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ ហើយក៏មិនមែនមកពីមនុស្សប្រព្រឹត្តអំពើល្អដែរ ដើម្បីកុំអោយនរណាម្នាក់អួតខ្លួនបាន .អេភេសូ ២:៨-៩។

## <u>សំនួរត្រិះរិះ    មេរៀនទី២៤</u>

១-៣.សូមសង្ខេបពីការធ្វើដំណើរលើមាគ៌ានៃជីវិតដែលយើងបានធ្វើដំណើររួចមកហើយ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

...................................................................................... ។

៤-៦. តើមួយទាំងប្រាំពីរមានអ្វីខ្លះដែលជាលក្ខណៈរបស់អ្នកជឿនៅសព្វថ្ងៃនេះ? *អេភេសូ៤: ៤-៦*......................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................... ។

៧-៩. សូមបំពេញចំនុចទាំង៦នៅក្នុង*កូឡុសជំពូក៣* ដែលគ្រិស្តបរិស័ទ្ធត្រូវបានប្រាប់អោយធ្វើប្រសិនបើគាត់/នាងរស់នៅក្នុងភាពជាអ្នកដែលនឹងត្រូវលើកឡើងជាមួយព្រះគ្រិស្ត..............................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................... ។

១០-សូមសរសេរខគម្ពីរចងចាំ *អេភេសូ ២:៨-៩*..........................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

....................................................................................................................... ។

## មេរៀនទី២៥ : ការឆ្លងកាត់គ្រោះទុក្ខលំបាកទៅកាន់រាជាណាចក្រ

វិវរណៈ

**គំនិតសំខាន់ :** ដើម្បីបង្ហាញពីព្រឹត្តិការណ៍ខាងមុខនៃថ្ងៃមុនការយាងត្រឡប់របស់ព្រះគ្រិស្ត

-ដើម្បីបង្កើតរាជាណាចក្រនៃស្ថានសួគ៌នៅលើផែនដី

ពិភពលោកនឹងភ្ញាក់ឡើងនៅព្រឹកមួយ ហើយនឹងឃើញថាបាត់អ្នកជឿពិតប្រាកដក្នុងព្រះគ្រិស្តពីផែនដី។ ហេតុអ្វី? រូបកាយនៃព្រះគ្រីស្តនៅលើផែនដី "តំណាងដោយខ្សែបន្ទាត់នៃការសង្គ្រោះនៅលើផែនទី " ត្រូវបានបំពេញ និងត្រាស់ហៅទៅជាមួយព្រះគ្រីស្តអស់កល្បរៀងទៅ។ គោលបំណងអាថ៌កំបាំងរបស់ព្រះជាម្ចាស់ត្រូវបានបំពេញគ្រប់សព្វ។ បន្ទាប់មកមហាពិធីនៃរាជាណាចក្រ និងបើកម្តងទៀត។ អ្នកចងចាំថាព្យាការីបានឃើញកំពូលភ្នំនៃទំនាយពីរ *គឺភ្នំកាល់វ៉ារី* ជាកន្លែងព្រះយេស៊ូត្រូវបានឆ្កាង និងភ្នំមួយទៀតជា *ភ្នំនៃរាជាណាចក្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់* ដែលនឹងបង្កើតរាជ្យបល្ល័ង្កស្តេចដាវីឌអស់កល្បលើអ៊ីស្រាអែល និងជាកន្លែងដែលព្រះពរចាក់បង្ហូរទៅគ្រប់ជាតិសាសន៍។ របៀបនៃការសង្គ្រោះនឹងមិនងាយស្រួលដូចសម័យព្រះគុណនេះឡើយ។ ព្រោះវាមិនមែន "ដោយព្រះគុណយើងទទួលការសង្គ្រោះតាមសេចក្តីជំនឿ " ទៀតឡើយតែដោយ " ការស៊ូទ្រាំរហូត ដល់ទីបញ្ចប់វិញ " គឺការស៊ូទ្រាំក្នុងភាពឈឺចាប់នៃ *គ្រោះទុក្ខវេទនា*។

កំឡុងពេលនោះផែនដីនឹងស្ថិតក្នុងភាពធម្មតាមួយរយៈ ដែលយើងអាចនិយាយថា "សន្តិភាព និងសុវត្ថិភាព" *១ថែស្សាឡូនិក៥:៣*។ ជនជាតិអ៊ីស្រាអែលនឹងចាប់ផ្តើមត្រលប់ទៅប្រទេសផាលេស្ទីនពីគ្រប់តំបន់នៃពិភពលោក ដើម្បីបង្កើតប្រាសាទជាកន្លែងសំរាប់ថ្វាយបង្គំ ប៉ុន្តែវានឹងសាងសង់ប្រាសាទបានរួចរាល់ក្នុងភាពគ្មានសេចក្តីជំនឿ *២ថែស្សាឡូនិក២:៤, ដានីយ៉ែល៩:២៤-២៧*។

ស្តេចដ៏ខ្លាំងម្នាក់នឹងសោយរាជ្យជាអ្នកដែលមានមេត្រីភាពជាមួយយូដា ហើយនឹងបង្កើតសម្ព័ន្ធមេត្រីជាមួយពួកគេ។ ប៉ុន្តែភ្លាមៗនោះស្តេចនោះនឹងបំផ្លាញសម្ព័ន្ធមេត្រីវិញ។ បន្ទាប់មកនឹងកើតមានទុក្ខលំបាកដ៏សែនវេទនាប្រាំពីរឆ្នាំដែលមិនធ្លាប់កើតមាននៅលើផែនដីនេះដែលហៅថា "ទុក្ខវេទនាដ៏ខ្លាំង" *វិវរណៈ ៧:១៤. ម៉ាថាយ២៤:២១*។ ទូទាំងពិភពលោកនឹងឆ្លងកាត់ផ្លូវមួយនេះ មនុស្សជាច្រើនត្រូវបានគេសំលាប់មុន និងទៅដល់ខ្លោងទ្វារនៃរាជាណាចក្រ។

ស្តេចដ៏ខ្លាំងខ្លានេះនឹងត្រូវគេហៅថាសត្វតិរច្ឆាន *វិវរណៈ១៣:*។ នឹងមានព្យាការីក្លែងក្លាយដែលហៅថាសត្វតិរច្ឆានដែរ*វិវរណៈ១៣:១១*។ ស្តេចនោះនឹងដាក់រូបចំលាក់នៃសត្វតិរច្ឆានទី១ នៅក្នុងព្រះវិហារនៃពួកយូដា ហើយបង្ខំគ្រប់គ្នាអោយថ្វាយបង្គំរូបចំលាក់នោះ។ អ្នកណាដែលជំទាស់នឹងត្រូវធ្វើទារុណកម្ម និងសំលាប់។ សាតាំងនឹងដាក់ទោសប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានរណ្តួយដី គ្រោះរាំងស្ងួតធ្លាក់ព្រិល រន្ទះផ្គរ គ្រោះកាច កំដៅក្តៅហែង។ នៅកំឡុងពេលនោះអ៊ីស្រាអែលនឹងស្រែកអង្វររកព្រះជាម្ចាស់។ ជនជាតិអ៊ីស្រាអែលដែលមានជំនឿរឹងមាំនឹងមិនថ្វាយបង្គំរូបចំលាក់នោះឡើយ *វិវរណៈ៧:៣-១៧*។ មានសាសន៍ដទៃជាច្រើននឹងទទួលការសង្គ្រោះនៅកំឡុងពេលរងទុក្ខវេទនានោះហើយប្រជាជនបរិសុទ្ធ *ស្លាប់ដោយសារជឿលើ* ព្រះយេស៊ូ*ដែលសំលៀកបំពាក់របស់ពួកគេត្រូវបានសំអាតដោយព្រះលោហិតរបស់*

*ទ្រង់* "។ ថ្ងៃចុងបញ្ចប់នឹងមកដល់នៅពេលដែលព្រះយេស៊ូអង្គទ្រង់ផ្ទាល់នឹងយាងមកពីស្ថានសួគ៌ដោយជិះសេះពណ៌ស *វិវរណៈ១៩*។

សត្វតិរច្ឆាន និងស្តេចនៃផែនដីនឹងផ្តុំគ្នាប្រឆាំងនឹងព្រះយេស៊ូគ្រិស្ត *វិវរណៈ ១៩:១៩*។ សង្គ្រាមរវាងព្រះគ្រីស្ទ និងពួកអ្នកប្រឆាំងនឹងផ្ទុះឡើង(សង្គ្រាមនេះហៅថាសមរភូមិអើម៉ាគេដូន) ហើយឈាមនឹងហូរដល់បង្ហៀរសេះ។ សត្វតិរច្ឆាន និងព្យាការីក្លែងក្លាយនឹងត្រូវបោះចូលទៅក្នុងបឹងភ្លើង *វិវរណៈ ១៩:១៧-២០*។ សាតាំងនឹងត្រូវបោះចូលទៅក្នុងនរកអវិចី ១000ឆ្នាំ *វិវរណៈ ២០:៣*។

បន្ទាប់មកអស់អ្នកដែលមានជ័យជំនះ ដោយឆ្លងកាត់ជ្រលងទុក្ខលំបាកនឹងចូលទៅក្នុងរាជាណាចក្រនៃព្រះជាម្ចាស់។ អ្នកដែលបានស្លាប់ដោយមានជំនឿនឹងរស់ឡើងវិញ ហើយសោយសុខជាមួយព្រះគ្រីស្តរយៈ១000ឆ្នាំ។ នេះហៅថារាជាណាចក្រ១000ឆ្នាំ។ រាជាណាចក្រនៃការសន្យា ប្រកបដោយសិរីរុងរឿងនឹងលេចឡើងឯសាសន៍ដទៃនឹងទៅកាន់ទីក្រុងយេរូសាឡឹម ដើម្បីថ្វាយបង្គំ និងស្ញប់ស្ញែង *អេសាយ១១:១០ សាការី៨:២០-២២ សាការី១៤:១៦-១៧*។ សត្វនឹងលែងកាចសាហាវ សត្វតោ និងកូនចៀមដេកជាមួយគ្នា។ គ្រប់គ្នានឹងថ្វាយបង្គំព្រះយេហូវ៉ា សូម្បីតែកណ្តឹងនៅកសេះក៏សរសេរថាព្រះដ៏វិសុទ្ធ "ញែកថ្វាយព្រះអម្ចាស់" *សាការី១៤:២០*។

អ្នកប្រហែលជានឹងសួរថាក្នុងពេលនោះអ្នកនៅឯណា ប្រសិនបើអ្នកទទួលការសង្គ្រោះ ហើយស្ថិតក្នុងគ្រួសារនៃព្រះជាម្ចាស់អ្នកនឹងបាននៅជាមួយព្រះយេស៊ូនៅស្ថានបរមសុខរួចទៅហើយ ព្រោះអ្នកគឺជាផ្នែកនៃរូបកាយទ្រង់។ ព្រះអង្គនឹងសោយរាជ្យលើស្ថានបរមសុខ និងផែនដីអ្នកក៏នឹងសោយរាជ្យជាមួយទ្រង់នៅស្ថានបរមសុខដែរ។ ប៉ុន្តែប្រសិនបើអ្នកមិនបានទទួលការសង្គ្រោះនៅកំឡុងពេលនោះអ្នកពិតជាទទួលលទ្ធផលអាក្រក់ជាមិនខាន។ ទីចុងបញ្ចប់សំរាប់អ្នកគឺការវិនិច្ឆ័យការថ្កោលទោស និងការឃ្លាតឆ្ងាយពីព្រះជាម្ចាស់អស់កល្បជានិច្ច។ អ្នកនឹងវិនាសជាមួយសាតាំងនៅក្នុងភ្លើងដែលឆេះក្នុងនរកអស់កល្ប ប្រសិនបើអ្នកមិនទទួលព្រះយេស៊ូជាព្រះសង្គ្រោះមុនពេលនោះ។

ការសិក្សាពីមាគ៌ានៃជីវិតរបស់យើងនៅលើផែនដីនេះត្រូវបានបញ្ចប់។ យើងចាប់ផ្តើមជាមួយអដាំដំបូងបង្អស់ ហើយយើងបានបញ្ចប់ជាមួយនឹងអដាំចុងក្រោយដែលជាស្តេចលើសអស់ទាំងស្តេច ព្រះលើសអស់ទាំងព្រះ *ទំនុកតំកើង ២៤:៧-៨*។ ចរាចរណ៍ធ្វើចលនាក្នុងទិសដៅតែមួយ ប៉ុណ្ណោះគឺទៅមុខត្រង់។ *វាគឺជាផ្លូវមួយទៅត្រង់*។ នឹងលែងមានឱកាសទៀតហើយសំរាប់ការសង្គ្រោះបន្ទាប់ពីស្លាប់។ សព្វថ្ងៃនេះគឺជាសម័យនៃព្រះគុណសម័យកាលនៃការសង្គ្រោះដោយការទទួលព្រះយេស៊ូជាព្រះសង្គ្រោះដោយជឿថាទ្រង់បានសុគត ហើយសពទ្រង់បានកប់ក្នុងផ្នូរ និងរស់ឡើងវិញ ដើម្បីសង្គ្រោះអ្នកពីអំពើបាប។

ប្រសិនបើក្នុងកំឡុងពេលអ្នកសិក្សាពីមាគ៌ានៃជីវិតអ្នកបានសំរេចចិត្ត "ការសំរេចចិត្តសំរាប់ភាពអស់កល្ប" ដើម្បីទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។ សូមបំពេញក្នុងចន្លោះខាងក្រោម។

ថ្ងៃទី....................ខែ.......................ឆ្នាំ.............................

នៅថ្ងៃនេះខ្ញុំសូមសារភាពចំពោះព្រះដ៏យុត្តិធម៌ និងបរិសុទ្ធពីអំពើបាបខ្ញុំ និងភាពគ្មានតំលៃចំពោះទ្រង់។ ខ្ញុំជឿជាក់ថាទ្រង់បានបង់ថ្លៃយ៉ាងពេញលេញចំពោះអំពើបាបរបស់ខ្ញុំ និងរៀបចំកន្លែងសំរាប់ខ្ញុំជាកន្លែងមួយនៅជាមួយទ្រង់ ឯស្ថានបរមសុខ ហើយខ្ញុំទទួលស្គាល់ថាព្រះយេស៊ូជាព្រះសង្គ្រោះផ្ទាល់របស់ខ្ញុំ។

សូមសរសេរឈ្មោះរបស់អ្នកខាងក្រោម

.................................................

**ខគម្ពីរចងចាំ:** ទំនុកតំកើង ២៤:៧-៨

ឱទ្វារទាំងឡាយអើយ ចូរបើកចំហ! ខ្លោងទ្វារដ៏នៅស្ថិតស្ថេរអស់កល្បជានិច្ចអើយ ចូរចំហអោយធំ ដើម្បីអោយព្រះមហាក្សត្រប្រកបដោយសិរីរុងរឿងយាងចូលមក! តើព្រះមហាក្សត្រប្រកបដោយសិរីរុងរឿងនេះជានរណា? ព្រះអម្ចាស់ប្រកបដោយព្រះចេស្តាដ៏ខ្លាំងពូកែ ព្រះអម្ចាស់ជាអ្នកចំបាំងដ៏ជំនាញ។

## <u>សំនួរត្រិះរិះ មេរៀនទី២៥</u>

បន្ទាប់ពីរូបកាយនៃព្រះគ្រិស្តត្រូវបានយកចេញពីផែនដីនេះព្រះអង្គនឹង បន្តទំនាក់ទំនងជាមួយអ៊ីស្រាអែលម្តងទៀត។ កណ្ឌគម្ពីរវិវរណៈអោយយើងឃើញមួយភ្លែតពីព្រឹត្តិការណ៍ដែលនឹងមានក្នុងរយៈពេល៧ឆ្នាំ ដែលហៅថាទុក្ខលំបាកដ៏ខ្លាំងដែលតំណាងអោយជ្រោះនៃទុក្ខលំបាកនៅលើតារាង។ សូមមើលនៅលើឯកសារយើងដើម្បីឆ្លើយនឹងសំនួរខាងក្រោមបំពេញចន្លោះ។

១- វិវរណៈប្រាប់យើងពីបុរសពីរនាក់ដែលហៅថាសត្វតិរច្ឆានដែលស្អប់ប្រជារាស្ត្រព្រះជាម្ចាស់ហើយនឹងប្រមាថព្រះនាមទ្រង់។ សត្វតិរច្ឆានទីពីរនឹងបង្កើតរូបចំលាក់ដំបូងហើយដាក់នៅក្នុងព្រះវិហារ។ តើសត្វតិរច្ឆាននោះនឹងអោយមនុស្សធ្វើដូចម្តេច? *វិវរណៈ១៣:១៤-១៥*

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

............................................................................................................................................ ។

២- រៀបរាប់ពីការវិនិច្ឆ័យទាំងបួនដែលនឹងកើតមាននៅលើផែនដី *វិវរណៈ១៦:២,៣,៨,១០*........................

.............................................................................................................................

.............................................................................................................................

.......................................................................................................................................................

.................................................................................................................................................. ។

៣- តើទេវទូតនឹងធ្វើដូចម្ដេចដើម្បីការពារអ្នកដែលមានជំនឿ ។ *វិវរណៈ ៧:២-៣*.........................................

....................................................................................................................................................................

.......................................................................................................................................................................

.......................................................................................................................................................................

.................................................................................................................................................................... ។

៤- បកស្រាយទស្សនៈលោកយ៉ូហានដែលលោកឃើញព្រះយេស៊ូយាងមកពីស្ថានបរមសុខ។ *វិវរណៈ១៩:១១-១៦* ព្រះអង្គមានព្រះនាម ...........................................................................និង.....................................

...........................................ព្រះអង្គមានព្រះនេត្រា. ...............................................................................

នៅលើព្រះសិរសាមាន.............................................................................ព្រះអង្គមានសំលៀកបំពាក់........................

..................ចេញពីព្រះឱសរបស់ព្រះអង្គមាន...........................................នៅលើព្រះភូសាព្រះអង្គមានសរសេរថា.

.......................................... ។

៥-តើសត្វតិរច្ឆាននិងព្យាការីក្លែងក្លាយទាំងអស់នឹងធ្វើអ្វី? *វិវរណៈ១៩:១៩*...................................................

.......................................................................................................................................................................

................................................................................................................................................................. ។

៦-តើពួកគេនឹងត្រូវបោះចូលទៅណា? *វិវរណៈ១៩:២០*..........................................................................

......................................................................................................................................................................

................................................................................................................................................................. ។

៧-តើនឹងមានអ្វីកើតឡើងចំពោះសាតាំង? *វិវរណៈ២០:២*..........................................................................

......................................................................................................................................................................

................................................................................................................................................................. ។

៨- តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលមានជំនឿនឹងអ្នក ដែលឆ្លងកាត់ទុក្ខលំបាកដ៏ខ្លាំង? *វិវរណៈ២០:៤*.......

.......................................................................................................................................................................

................................................................................................................................................................. ។

៩-កិច្ចការនេះនាំយើងដើម្បីបញ្ចប់មាគ៌ានៃជីវិតនៅលើផែនដី តើនឹងមានអ្វីកើតឡើងនៅចុងបញ្ចប់ពីការសោយរាជ្យនៃព្រះគ្រីស្ដនៅលើផែនដីនៃរាជ្យ១000ឆ្នាំ? *វិវរណៈ២១:១*....................................................................

......................................................................................................................................................................

.......................................................................................................................................................

..................................................................................................................................... ។

១០-សូមសរសេរខគម្ពីរចងចាំ *ទំនុកតំកើង២៨:៧-៨*.........................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

............................. ។

**<u>សូមបំពេញឈ្មោះ និង អាស័យដ្ឋានរបស់ខាងក្រោម</u>**

**ឈ្មោះ................................................................. អាយុ...................**

**អាស័យដ្ឋាន...........................................................................................................................**

**.......................................................................................................................................**

**......................................................................... ។**

**ពិន្ទុសរុប................................................................**

**អរគុណ!**

សូមព្រះជាអង្គម្ចាស់ដែលប្រកបដោយព្រះគុណ

ប្រទានពរដល់បងប្អូនគ្រប់គ្នា!